ក្រសួងអប់រំ យុវជន និងកីឡា

# ភាសាខ្មែរ

សម្រាប់លក់

# អាន-សរសេរ




២

ក្រសួងអប់រំ យុវជន និងកីឡា

# ភាសាខ្មែរ

# អាន-សរសេរ

## ថ្នាក់ទី ២

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ៣៩៤ អយក.ប្រក. ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ២០១២ ដើម្បីប្រើប្រាស់នៅតាមសាលារៀន។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

បោះពុម្ពឆ្នាំ២០១៦

ISBN 9-789-995-001-681

www.elibraryofcambodia.org

## គណៈកម្មការគ្រប់គ្រងកម្មវិធី

ឯកឧត្តម អ៊ឹម សិទ្ធី

ឯកឧត្តម ណាត ប៊ុនរឿន
លោកជំទាវ ទន់ សាអ៊ឹម
ឯកឧត្តម ថោង ប៊ូរ៉ាន់
ឯកឧត្តម អ៊ឹម កុច
ឯកឧត្តម សំ សេរីរតន៍
លោក ចាន់ សុភា

## គណៈកម្មការនិពន្ធ

លោក យិន ស៊ីដា

លោក យិន ធី
លោក មួង ចាន់ទូច
លោកស្រី ម៉ៅ តាន់ណារី
លោកស្រី ផាន់ សុជាតា
លោក ហោ សុខៈ
លោកស្រី ម៉េង ផាន់ណូរ៉ា
លោក យ៉ង់ កំស៊ាន
លោក ឈឹម ចន្ទតារា
លោក សុខ បូរេត
លោក អ៊ុយ សាន
លោក ជិន រិត
លោក ជិន សុតារា
លោកស្រី ឈឹន ស៊ីវឡេង
លោកស្រី លី សាខុន
លោក យិត សុភ័ក្ត្រ
លោក ជិន សុកហេង
លោក វ៉ើន ថុល
លោកស្រី ណែត ពេជ្រថិន្តា

## គណៈកម្មការរៀបរៀង វិចិត្រករ និងរចនាទំព័រ

លោក យិន ស៊ីដា
លោក ស្ងួ ស៊ីផុន
លោក ញេប ប៊ុនស្រេង
លោក ហុង ពិដោរ
លោក រ័ត្ន ប៊ុណ្ណា
លោក ឡុង សុវណ្ណ(វិចិត្រករ)

## គណៈកម្មការពិនិត្យ

លោក ចាន់ សុភា

លោក លាង សេងហាក់
លោក ជុំ សុផល
លោក អេង គីមលី
លោក កាន់ កាល់
លោក ហ៊ិន ស៊ីមហួន
លោក កែវ សារ៉ាត់

www.elibraryofcambodia.org

# អារម្ភកថា

សៀវភៅភាសាខ្មែរថ្នាក់ទី ២ "អាន-សរសេរ" នេះត្រូវបានរៀបចំឡើងដោយគណៈកម្មការនិពន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានការចូលរួមសហការពីនាយកដ្ឋានបឋមសិក្សា នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងអ្នកពាក់ព័ន្ធមួយចំនួនដែលស្ថិតនៅក្រោមគម្រោងកម្មវិធីសកម្មភាពពង្រីកការគាំទ្រវិស័យអប់រំនៅកម្ពុជា (ESSSUAP/GPE) ។

សៀវភៅនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងសម្រួលដល់ការរៀនអក្សររបស់សិស្សថ្នាក់ទី ២ ដោយមានការផ្សារភ្ជាប់មេរៀនមួយចំនួនពីថ្នាក់ទី ១ ។ ខ្លឹមសារសំខាន់ៗនៃឯកសារនេះ មានការរៀបចំតាមលំដាប់ពីតិចទៅច្រើន ពីងាយទៅលំបាក ដើម្បីជួយដល់ការរៀនអក្សររបស់សិស្សឱ្យចេះអាន (ចេះប្រកប)និងចេះសរសេរបានត្រឹមត្រូវដោយចាប់ផ្តើមដំបូង គឺរំឭកឡើងវិញ អំពីស្រៈ ព្យញ្ជនៈ ព្យញ្ជនៈផ្សំស្រៈ ប្រកប ស្រៈពេញតួ និងមេរៀនមួយចំនួនទៀតសម្រាប់តភ្ជាប់ពីមេរៀនផ្ញើជើង ព្យាង្គតម្រួត អមដោយកថាខណ្ឌខ្លីៗដែលសិស្សមិនទាន់ចេះស្ទាត់ពីថ្នាក់ទី ១ ព្រមទាំងខ្លឹមសារសៀវភៅថ្នាក់ទី ២ ដែលកំពុងដំណើរការរៀននិងបង្រៀនតាមរយៈការហាត់អាន សរសេរ និងធ្វើកិច្ចការផ្ទះ។ ពិសេស គឺផ្តោតទៅលើការពង្រឹងសមត្ថភាពអាននិងសរសេរដែលជាមូលដ្ឋានគ្រឹះសម្រាប់ជួយឱ្យសិស្សមានសមត្ថភាពលើការអាននិងសរសេរភាសាខ្មែរ ។

គណៈកម្មការនិពន្ធសង្ឃឹមថា ឯកសារនេះនឹងបានជាប្រយោជន៍ចំពោះសិស្សានុសិស្សថ្នាក់ទី ២ សហគមន៍ មាតាបិតា និងអ្នកអាណាព្យាបាលសិស្ស ក៏ដូចជាសាលារៀន គ្រូបង្រៀនក្នុងការជួយបង្រៀនកុមារឱ្យចេះអាន ចេះសរសេរបានគ្រប់គ្នា ហើយសិស្សមានសមត្ថភាពអាននិងសរសេររឹងមាំនឹងអាចបន្តការសិក្សាទៅថ្នាក់បន្ទាប់ទៀតបានប្រកបដោយគុណភាពពិតប្រាកដ ។

**គណៈកម្មការនិពន្ធ**

www.elibraryofcambodia.org

# មាតិកា


គណៈកម្មការគ្រប់គ្រងកម្មវិធី

លិខិតអនុញ្ញាត ..........

អារម្ភកថា ..........

មាតិកា ..........

សេចក្តីណែនាំ ..........

សេចក្តីផ្តើម .......... I

១. ការប្រើប្រាស់ម៉ោងសិក្សា .......... II

២. វិធីសាស្ត្របង្រៀន .......... VI

៣. ការប្រើប្រាស់សម្ភារឧបទេស .......... VI

៤. ការវាយតម្លៃ .......... VII

៥. ការដាក់កិច្ចការផ្ទះ .......... VII

៦. លំនាំបង្រៀន .......... VIII

- លំនាំបង្រៀនរំឭកស្រៈនិស្ស័យនិងព្យញ្ជនៈ .......... VIII
- លំនាំបង្រៀនរំឭកព្យញ្ជនៈពួក អ អ៊ ផ្សំនឹងស្រៈ .......... VIII
- លំនាំបង្រៀនរំឭក ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉ និង ប៊ ស៊ ហ៊ អ៊ .......... IX
- លំនាំបង្រៀនរំឭកពាក្យប្រកបពួក អ និងពួក អ៊ .......... XI
- លំនាំបង្រៀនរំឭកស្រៈពេញតួ .......... XII
- លំនាំបង្រៀនអាននិងសរសេរព្យញ្ជនៈផ្ញើជើងនិងព្យាង្គតម្រួត .......... XII
- លំនាំបង្រៀនអានអត្ថបទ .......... XIV
- លំនាំបង្រៀនសំណេរ .......... XVI
- លំនាំបង្រៀននិយាយ .......... XIX
- លំនាំបង្រៀនស្តាប់ .......... XX

មេរៀន ..........

- មេរៀនរំឭក(ស្រៈនិស្ស័យនិងព្យញ្ជនៈ ព្យញ្ជនៈផ្សំស្រៈ មូសិកទន្ត ត្រីសព្ទ ស្រៈពេញតួ ប្រកប) ០១
- មេរៀនព្យញ្ជនៈផ្ញើជើង ព្យាង្គតម្រួត .......... ០៩
- មេរៀន(អត្ថបទអំណាន សំណេរ ការស្តាប់ និងការនិយាយ) .......... ៣២

បទានុក្រម .......... ១៨១


www.elibraryofcambodia.org

# សេចក្ដីណែនាំ

## សេចក្ដីផ្ដើម

ផ្អែកតាមលទ្ធផលសិក្សារបស់សិស្សប៉ុន្មានឆ្នាំកន្លងមកនេះ យើងឃើញថា សិស្សបឋមសិក្សាមានមូលដ្ឋាននៃការអាននិងសរសេរនៅមានកម្រិតទាបគួរឱ្យបារម្ភ ។ ក្រសួងអប់រំ យុវជន និងកីឡា បានរិះរកយុទ្ធវិធី ដើម្បីពង្រឹងគុណភាពនៃការអាននិងសរសេរឱ្យបានកាន់តែប្រសើរ ដោយធ្វើការសម្របសម្រួលវិធីសាស្ត្រ និងកែលម្អឯកសារសម្រាប់បង្រៀនភាសាខ្មែរឱ្យឆាប់ចេះ ក្នុងទិសដៅឆ្លើយតបទៅនឹងគោលនយោបាយសម្រាប់អភិវឌ្ឍកម្មវិធីសិក្សានិងដើម្បីធ្វើឱ្យសម្រេចតាមស្តង់ដាកម្មវិធីសិក្សាថ្នាក់ទី ៣ ដែលបានចែងថា សិស្សថ្នាក់ទី ១ ដល់ទី ៣ ត្រូវមានបំណិនមូលដ្ឋានរឹងមាំផ្នែកភាសាខ្មែរនិងគណិតវិទ្យា ពោលគឺចេះអាន សរសេរ និងគិតលេខបានច្បាស់លាស់ ។

សៀវភៅសម្រាប់បង្រៀនអក្សរថ្នាក់ទី ២ថ្មីនេះ រៀបរៀងឡើងដើម្បីសម្រួលដល់ការរៀននិងការបង្រៀនភាសាខ្មែរដោយធ្វើបច្ចុប្បន្នភាពឱ្យស្របតាមបរិបទថ្មីៗ ដែលចាប់ផ្ដើមពី ការរំឭក និងរៀនមេរៀនតភ្ជាប់មួយចំនួនដែលសិស្សមិនទាន់បានរៀននៅថ្នាក់ទី ១ ការរៀនស្រៈ ព្យញ្ជនៈ ព្យញ្ជនៈផ្សំនឹងស្រៈ ប្រកប ព្យញ្ជនៈធ្វើជើងនិងមេរៀនព្យាង្គតម្រួតដើម្បីឱ្យសិស្សមានគ្រឹះរឹងមាំមុននឹងអានអត្ថបទ ។ យោងតាមលទ្ធផលនៃការសាកល្បងពេញមួយឆ្នាំសិក្សាប្រកបដោយជោគជ័យនៅតាមសាលាគោលដៅនៃរាជធានី ខេត្តមួយចំនួន ក្រសួងអប់រំ យុវជន និងកីឡាប្រើប្រាស់សៀវភៅនេះ ដើម្បីអនុវត្តនៅទូទាំងប្រទេស ។

ដើម្បីជាជំនួយដល់គ្រូក្នុងការប្រើប្រាស់សៀវភៅនេះបានត្រឹមត្រូវ គណៈកម្មការបានរៀបចំសេចក្ដីណែនាំអមក្នុងសៀវភៅ ដោយផ្ដោតលើខ្លឹមសារសំខាន់ៗមួយចំនួនដូចជា ៖

១. ការប្រើប្រាស់ម៉ោងសិក្សា

២. វិធីសាស្ត្រ

៣. ការប្រើប្រាស់សម្ភារឧបទេស

៤. ការវាយតម្លៃ

៥. ការដាក់កិច្ចការផ្ទះ

៦. លំនាំបង្រៀន ។



www.elibraryofcambodia.org

## ១ . ការប្រើប្រាស់ម៉ោងសិក្សា

កម្មវិធីសិក្សាថ្មី តម្រូវឱ្យសិស្សសិក្សាភាសាខ្មែរចំនួន ១៣ម៉ោងក្នុងមួយសប្តាហ៍ ហើយក្នុង១ម៉ោងសិក្សាមានរយៈពេល ៤០នាទី ។ ក្នុងមួយឆ្នាំសិក្សាសិស្សត្រូវរៀន ៣៨សប្តាហ៍ ។ ដូច្នេះ ម៉ោងសម្រាប់រៀនភាសាខ្មែរស្មើនឹង ៤៩៤ម៉ោងសិក្សា ។

ខាងក្រោមនេះជាកាលវិភាគសម្រាប់មុខវិជ្ជាភាសាខ្មែរក្នុង ១សប្តាហ៍ ៖

| ថ្ងៃ | ចំនួនម៉ោងសិក្សា |
|---|---|
| ចន្ទ | ០៣ម៉ោង |
| អង្គារ | ០២ម៉ោង |
| ពុធ | ០៣ម៉ោង |
| សុក្រ | ០២ម៉ោង |
| សៅរ៍ | ០៣ម៉ោង |
| សរុប | ១៣ម៉ោង |

ចំនួនម៉ោងបង្រៀននៅតាមទំព័រមេរៀននីមួយៗខុសៗគ្នា ។ ខ្លឹមសារមេរៀនខ្លះត្រូវបង្រៀន ៣ម៉ោង ខ្លះ ៤ម៉ោង ខ្លះ ៥ម៉ោងសិក្សា ខ្លះ ៦ម៉ោងសិក្សា ខ្លះ ៨ម៉ោងសិក្សាក៏មាន ។ អាស្រ័យហេតុនេះ មុនពេលរៀបចំការបង្រៀនអ្នកគ្រូ- លោកគ្រូគប្បីមើលតារាងបែងចែកម៉ោងសិក្សាខាងក្រោមជាមុនសិន ។

www.elibraryofcambodia.org

# តារាងបែងចែកម៉ោងសិក្សាសម្រាប់មេរៀន

| ល.រ | ខ្លឹមសារមេរៀន | ទំព័រ | ចំនួនម៉ោងសិក្សា | ល.រ | ខ្លឹមសារមេរៀន | ទំព័រ | ចំនួនម៉ោងសិក្សា |
|---|---|---|---|---|---|---|---|
| ១ | រំឭកស្រៈនិស្ស័យនិងព្យញ្ជនៈ | ១ | ០៥ ម៉ោង | ២ | រំឭកព្យញ្ជនៈពួក "អ" ពួក "អ៊" ផ្សំនិងស្រៈ | ២ | ១២ ម៉ោង |
| ៣ | រំឭកប្រកប | ៦ | ០៦ ម៉ោង | ៤ | រំឭកស្រៈពេញតួ | ៨ | ០៣ ម៉ោង |
| ៥ | ព្យញ្ជនៈផ្ញើជើង | ៩ | ៣៩ ម៉ោង | ៦ | ព្យាង្គតម្រួត | ២២ | ៣០ ម៉ោង |
| ៧ | អំណាននិងសំណេរ "បរវេសនកាល" | ៣២ | ០៨ ម៉ោង | ៨ | អំណាននិងសំណេរ "ពេលចេញលេង" | ៣៥ | ០៨ ម៉ោង |
| ៩ | មេសូត្រនិងសំណេរ "ឆ្មាចង់ទៅរៀន" | ៣៨ | ០៨ ម៉ោង | ១០ | ការនិយាយនិងសំណេរ "ការណែនាំមិត្តឱ្យស្គាល់គ្នា" | ៤១ | ០៦ ម៉ោង |
| ១១ | អំណាននិងសំណេរ "សត្វក្រសារ" | ៤៤ | ០៨ ម៉ោង | ១២ | អំណាននិងសំណេរ "ការខិតខំរៀនសូត្រ" | ៤៧ | ០៨ ម៉ោង |
| ១៣ | ការស្ដាប់រឿងនិទាននិងសំណេរ "រឿងក្អែកការកូន" | ៥០ | ០៦ ម៉ោង | ១៤ | ចម្រៀងនិងសំណេរ "យើងទៅសាលារៀន" | ៥២ | ០៨ ម៉ោង |
| ១៥ | អំណាននិងសំណេរ "ការធ្វេសប្រហែស" | ៥៥ | ០៨ ម៉ោង | | | | |

## សរុបម៉ោងក្នុងត្រីមាសទី ១

- ម៉ោងសរុប : ១៣ម៉ x ១៣សប្ដាហ៍ = ១៦៩ ម៉ោងសិក្សា
- ម៉ោងបង្រៀន : = ១៦៣ ម៉ោងសិក្សា
- ម៉ោងនៅសល់ : = ០៦ ម៉ោងសិក្សា

| ល.រ | ខ្លឹមសារមេរៀន | ទំព័រ | ចំនួនម៉ោងសិក្សា | ល.រ | ខ្លឹមសារមេរៀន | ទំព័រ | ចំនួនម៉ោងសិក្សា |
|---|---|---|---|---|---|---|---|
| ១៦ | មេសូត្រនិងសំណេរ "ម្ដាយឪពុកខ្ញុំ" | ៥៨ | ០៨ ម៉ោង | ១៧ | អំណាននិងសំណេរ "ពេលភ្ញៀវមកលេងផ្ទះ" | ៦១ | ០៨ ម៉ោង |



www.elibraryofcambodia.org

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៨ | ការនិយាយនិងសំណេរ "ការប្រើពាក្យរបស់ខ្ញុំ របស់ឯង របស់យើង" | ៦៤ | ០៦ ម៉ោង | ១៩ | អំណាននិងសំណេរ "ឪពុកនិងកូនជីកលាទៅលក់" | ៦៧ | ០៨ ម៉ោង |
| ២០ | អំណាននិងសំណេរ "មិត្តល្អរបស់កូនឆ្មាបូបូ" | ៧១ | ០៨ ម៉ោង | ២១ | អំណាននិងសំណេរ "ការរៀនអក្សរផ្ចង់" | ៧៤ | ០៨ ម៉ោង |
| ២២ | ការនិយាយនិងសំណេរ "ការរៀបរាប់សមាជិកក្នុងគ្រួសារ" | ៧៧ | ០៦ ម៉ោង | ២៣ | ការស្ដាប់និងសំណេរ "រឿងកញ្ជ្រោងនិងកូនពពែ" | ៧៩ | ០៦ ម៉ោង |
| ២៤ | អំណាននិងសំណេរ "រឿងកូនទន្សាយនិងកូនឆ្មា" | ៨១ | ០៨ ម៉ោង | ២៥ | ចម្រៀងនិងសំណេរ "គ្រួសាររីករាយ" | ៨៤ | ០៨ ម៉ោង |
| ២៦ | អំណាននិងសំណេរ "ចម្ការរបស់ជីតាខ្ញុំ" | ៨៧ | ០៨ ម៉ោង | ២៧ | អំណាននិងសំណេរ "មេមាន់និងកូន" | ៩១ | ០៨ ម៉ោង |
| ២៨ | ការនិយាយនិងសំណេរ "ការរៀបរាប់ពីរូបរាងក្លិនពណ៌ សូរសំឡេង និងរសជាតិ" | ៩៥ | ០៦ ម៉ោង | ២៩ | អំណាននិងសំណេរ "អាត្មោតគោខ្ញុំ" | ៩៨ | ០៨ ម៉ោង |
| ៣០ | អំណាន "ពាក្យបង្ហាញលក្ខណៈ វត្ថុ មនុស្ស សត្វ រុក្ខជាតិ" | ១០១ | ០៤ ម៉ោង | ៣១ | អំណាននិងសំណេរ "ទេសភាពវាលស្រែនៅរដូវវស្សា" | ១០២ | ០៨ ម៉ោង |
| ៣២ | អំណាននិងសំណេរ "អ្នកលក់មួកនិងសត្វស្វា" | ១០៥ | ០៨ ម៉ោង | ៣៣ | ចម្រៀងនិងសំណេរ "ការងារពុកម៉ែខ្ញុំ" | ១០៨ | ០៨ ម៉ោង |
| ៣៤ | អំណាននិងសំណេរ "មុខរបរអ្នកភូមិខ្ញុំ" | ១១២ | ០៨ ម៉ោង | ៣៥ | អំណាននិងសំណេរ "ដើមត្នោត" | ១១៥ | ០៨ ម៉ោង |
| ៣៦ | មេសូត្រនិងសំណេរ "កិច្ចការនៅសាលារៀន" | ១១៩ | ០៨ ម៉ោង | ៣៧ | អំណាននិងសំណេរ "រាជធានីភ្នំពេញ" | ១២២ | ០៨ ម៉ោង |



www.elibraryofcambodia.org

## សរុបម៉ោងក្នុងត្រីមាសទី ២

- ម៉ោងសរុប : ១៣ម៉ x ១៣សប្ដាហ៍ = ១៦៩ ម៉ោងសិក្សា
- ម៉ោងបង្រៀន : = ១៦៤ ម៉ោងសិក្សា
- ម៉ោងនៅសល់ : = ០៥ ម៉ោងសិក្សា

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣៨ | អំណាននិងសំណេរ "ភូមិរុងរឿង" | ១២៥ | ០៤ ម៉ោង | ៣៩ | អំណាននិងសំណេរ "ដីកទឹកកខ្វក់នាំឱ្យកើតជំងឺ" | ១២៨ | ០៤ ម៉ោង |
| ៤០ | អំណាននិងសំណេរ "សត្វលលកនិងស្រមោចខ្មៅ" | ១៣១ | ០៤ ម៉ោង | ៤១ | អំណាននិងសំណេរ "ចាបនិងដំរី" | ១៣៤ | ០៤ ម៉ោង |
| ៤២ | អំណាននិងសំណេរ "វត្ថុប្រើប្រាស់នៅក្នុងផ្ទះ" | ១៣៧ | ០៤ ម៉ោង | ៤៣ | ការស្ដាប់រឿងនិទាន "ដឹងសងដឹង អំបែងសងអំបែង" | ១៤១ | ០៣ ម៉ោង |
| ៤៤ | អំណាននិងសំណេរ "បឹងទន្លេសាប" | ១៤២ | ០៤ ម៉ោង | ៤៥ | អំណាននិងសំណេរ "សង្គ្រាមរវាងតឹង្គក់និងតាព្រហ្ម" | ១៤៥ | ០៤ ម៉ោង |
| ៤៦ | អំណាននិងសំណេរ "ដង្កូវនិងក្អែក" | ១៤៨ | ០៤ ម៉ោង | ៤៧ | មេសូត្រនិងសំណេរ "ច្បារដំណាំ" | ១៥២ | ០៤ ម៉ោង |
| ៤៨ | អំណាននិងសំណេរ "ផ្សារភូមិខ្ញុំ" | ១៥៥ | ០៤ ម៉ោង | ៤៩ | ការនិយាយនិងសំណេរ "ប្រៀបធៀបទីកន្លែងនិងវត្ថុ" | ១៥៨ | ០៦ ម៉ោង |
| ៥០ | អំណាននិងសំណេរ "មេក្រុចនិងពស់" | ១៦០ | ០៤ ម៉ោង | ៥១ | អំណាននិងសំណេរ "ក្មេងសុចរិត" | ១៦៣ | ០៤ ម៉ោង |
| ៥២ | អំណាននិងសំណេរ "ជីដូនជីតា" | ១៦៦ | ០៤ ម៉ោង | ៥៣ | អំណាននិងសំណេរ "សេចក្ដីជូនដំណឹង" | ១៦៩ | ០៦ ម៉ោង |
| ៥៤ | អំណាននិងសំណេរ "រឿងសត្វឆ្មាត" | ១៧២ | ០៤ ម៉ោង | ៥៥ | អំណាននិងសំណេរ "ថ្ងៃបុណ្យចូលឆ្នាំ" | ១៧៥ | ០៤ ម៉ោង |
| ៥៦ | អំណាននិងសំណេរ "បុណ្យភ្ជុំបិណ្ឌ" | ១៧៨ | ០៤ ម៉ោង | | | | |



www.elibraryofcambodia.org

| សរុបម៉ោងក្នុងត្រីមាសទី ៣ | | |
|---|---|---|
| - ម៉ោងសរុប | : ១៣ម៉ x ១២សប្តាហ៍ | = ១៥៦ ម៉ោងសិក្សា |
| - ម៉ោងបង្រៀន | : | = ១៤៣ ម៉ោងសិក្សា |
| - ម៉ោងនៅសល់ | : | = ១៣ ម៉ោងសិក្សា |
| **សរុបម៉ោងក្នុងមួយឆ្នាំសិក្សា** | | |
| - ម៉ោងសរុប | : ១៣ម៉ x ៣៨សប្តាហ៍ | = ៤៩៤ ម៉ោងសិក្សា |
| - ម៉ោងបង្រៀន | : | = ៤៧០ ម៉ោងសិក្សា |
| - ម៉ោងនៅសល់ | : | = ២៤ ម៉ោងសិក្សា |

ដូច្នេះ សូមអ្នកគ្រូ លោកគ្រូ គប្បីរៀបចំចំនួនម៉ោងសិក្សាដែលបានកំណត់ខាងលើឱ្យមានលក្ខណៈទន់ភ្លន់និងមានប្រសិទ្ធភាព ។

## ២ . វិធីសាស្ត្របង្រៀន

មុននឹងចាប់ផ្តើមបង្រៀនមេរៀននីមួយៗ អ្នកគ្រូ លោកគ្រូ គប្បីយល់ពីគោលបំណងនៃការបង្រៀន និងរៀននៅថ្នាក់ទី ២ ដែលសិស្សត្រូវមានសមត្ថភាពស្តាប់ និយាយ ពិសេសសង្កត់ធ្ងន់លើការអាន-សរសេរឱ្យបានត្រឹមត្រូវ ។ ដូច្នេះ ការបង្រៀនត្រូវយកចិត្តទុកដាក់ទៅលើការអនុវត្តរបស់សិស្សដោយផ្ទាល់ ចៀសវាងគ្រូអនុវត្តហើយសិស្សអង្គុយចាំមើល ពោលគឺត្រូវមានសកម្មភាពឆ្លើយតបគ្នារវាងគ្រូនិងសិស្ស ពិសេសត្រូវអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលជាប្រចាំ ដើម្បីទទួលបានលទ្ធផលល្អប្រសើរ ។ ក្នុងការបង្រៀន គ្រូត្រូវចេះលើកទឹកចិត្តសិស្សមិនត្រូវនិយាយបន្តុះបង្អាប់សិស្សទេ ។ គ្រូត្រូវមានឥរិយាបថទន់ភ្លន់តែម៉ឺងម៉ាត់ និងចេះយោគយល់ អធ្យាស្រ័យរាល់កំហុសដែលសិស្សប្រព្រឹត្តដោយចេតនាក្តី ឬអចេតនាក្តី ។ គ្រូត្រូវមានភាពច្បាស់លាស់ក្នុងតួនាទីរបស់ខ្លួន ដែលត្រូវគ្រប់គ្រងសិស្ស និងត្រូវសួរខ្លួនឯងថា ថ្ងៃនេះសិស្សរបស់ខ្លួនត្រូវទទួលបាននូវចំណេះអ្វីខ្លះ ?

## ៣ . ការប្រើប្រាស់សម្ភារឧបទេស

ការបង្រៀនត្រូវប្រើប្រាស់សម្ភារឧបទេស ដើម្បីបញ្ជាក់នូវន័យរបស់ពាក្យនីមួយៗ ។ លោកគ្រូអ្នកគ្រូត្រូវឱ្យសិស្សហាត់ប្រើសម្ភារៈដោយខ្លួនឯងទៅតាមខ្លឹមសារមេរៀន ដើម្បីឱ្យសិស្សកាន់តែចេះអានសរសេរ និងយល់ច្បាស់នូវខ្លឹមសារមេរៀនដែលបានបង្រៀនរួច ។ កត្តាសំខាន់ទៀតនោះ មុននឹង



www.elibraryofcambodia.org

បង្រៀន គ្រូត្រូវរៀបចំកិច្ចតែងការបង្រៀនដោយកំណត់វត្ថុបំណងមេរៀន ផ្សារភ្ជាប់ទៅនឹងសម្ភារៈគ្រប់គ្រាន់សម្រាប់បង្រៀន ដូចជាអក្សរចល័ត (ព្យញ្ជនៈ ឬស្រៈ) តារាងព្យញ្ជនៈទាំង ៣៣តួ និងជើង តារាងស្រៈនិស្ស័យ បណ្ណពាក្យ បណ្ណល្បះ ក្ដារខៀនថត ឬក្ដារខៀនតូច ដែលអាចបិទភ្ជាប់អក្សរចល័ត ឬរូបភាពបានសម្រាប់សកម្មភាពក្នុងថ្នាក់ ព្រមទាំងអត្ថបទដែលត្រូវយកមកបង្រៀន ដោយត្រូវបានសរសេររួចជាស្រេចលើផ្ទាំងក្រដាសធំ ហើយបិទទុកនៅក្ដារខៀន ។

ក្រៅពីនេះ គ្រូ សិស្សអាចប្រើកាយវិការជាក់ស្ដែងជាច្រើនទៀតតម្រូវទៅតាមពាក្យដែលត្រូវយកមកបង្រៀននិងរៀន ។

## ៤ . ការវាយតម្លៃ

នៅពេលបង្រៀនមេរៀនចប់ គ្រូត្រូវធ្វើការវាយតម្លៃ ដើម្បីវាស់ស្ទង់លទ្ធផលនៃការសិក្សារបស់សិស្ស ។ ការវាយតម្លៃ ត្រូវធ្វើជាប្រចាំតាមដំណាក់រហូតបញ្ចប់ និងការប្រឡងប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ។ ការវាយតម្លៃត្រូវឱ្យសមស្របទៅនឹងកម្រិតលទ្ធផលសិក្សាថ្នាក់ទី ២ ដូចជាការវាយតម្លៃអំណាន សិស្សត្រូវអានឱ្យបានត្រឹមត្រូវនិងយល់ន័យ ដោយចៀសវាងការប្រកបក្នុងពេលអានអត្ថបទ ។ ចំណែកការវាយតម្លៃសំណេរត្រូវឱ្យសិស្សសរសេរតាមអានចម្លង ដោយសរសេរអក្សរទាំងអស់នៃអក្ខរក្រម (ក ខ ...អ) សរសេរកន្សោមពាក្យងាយៗ និងសរសេរចំណងជើងរូបភាព ។ ល ។

## ៥ . ការដាក់កិច្ចការផ្ទះ

ការដាក់កិច្ចការផ្ទះ ជាមធ្យោបាយមួយសំខាន់ សម្រាប់ជួយសិស្សឱ្យឆាប់ចេះអាន សរសេរ និងជាទម្លាប់មួយឱ្យសិស្សចេះរៀនដោយខ្លួនឯង និងចូលចិត្តរៀន ។ គ្រូគប្បីដាក់កិច្ចការឱ្យសិស្សជាប្រចាំនិងរាល់ថ្ងៃ ។

កិច្ចការផ្ទះសម្រាប់សិស្សថ្នាក់ទី ២ ក្នុងមេរៀនថ្មីអាចធ្វើបានដូចជា ៖

- លំហាត់ដែលមាននៅបញ្ចប់មេរៀននីមួយៗ
- មុខវិជ្ជាអក្សរផ្ចង់ដែលគ្រូដាក់ឱ្យតាមលំដាប់ មានព្យញ្ជនៈ ស្រៈ ព្យាង្គ ពាក្យ និងល្បះ
- ឱ្យសិស្សរៀនមេរៀនថ្មីត្រៀមទុកជាមុន
- ពាក្យ ឬឃ្លាណាដែលគ្រូមិនបានបង្រៀននៅក្នុងថ្នាក់ គ្រូត្រូវដាក់កិច្ចការផ្ទះបន្ថែមឱ្យសិស្សធ្វើ តែគ្រូមិនត្រូវភ្លេចកែឡើងវិញនៅថ្ងៃរៀនបន្ទាប់នោះឡើយ ។ គ្រប់កិច្ចការទាំងអស់ដែលដាក់ឱ្យសិស្សធ្វើ គ្រូត្រូវត្រួតពិនិត្យនិងកែឱ្យបានទៀងទាត់ ។



www.elibraryofcambodia.org

## ៦ . លំនាំបង្រៀន

### ៦.១ លំនាំបង្រៀនរំឭកស្រៈនិស្ស័យ

- គ្រូលើកស្រៈចល័តបង្ហាញសិស្ស ហើយសួរសិស្ស តើនេះជាស្រៈអ្វី ? គ្រូសរសេរស្រៈលើក្ដារខៀន ។
- ឱ្យសិស្សអានស្រៈនោះទាំងអស់គ្នា ។ ចំពោះស្រៈផ្សេងទៀតគ្រូធ្វើដូចស្រៈទី ១ដែរ ដោយមិនគិតពីលំដាប់ ។
- គ្រូបិទតារាងស្រៈនិស្ស័យ រួចគ្រូចង្អុលស្រៈតាមលំដាប់ ហើយឱ្យសិស្សអានឱ្យបានច្បាស់ៗ ។ គ្រូចង្អុលបញ្ច្រាសមកវិញ ហើយឱ្យសិស្សអានពីស្រៈ ោះ ⟶ ា ។
- គ្រូហៅស្រៈមិនតាមលំដាប់ឱ្យសិស្សសរសេរលើក្ដារឆ្នួន ។
- គ្រូចែកសិស្សជាក្រុមតូចៗ ។ ឱ្យសិស្សអានស្រៈដោយប្រើសៀវភៅរបស់គេ តាមក្រុមដោយដំបូងអានរួមគ្នា ។ លើកទី ២ម្នាក់ចង្អុលឆ្លាស់ចុះឡើង អ្នកឯទៀតអាន រួចដូរវេនគ្នាចង្អុល ។

### ៦.២ លំនាំបង្រៀនរំឭកព្យញ្ជនៈ

- គ្រូលើកព្យញ្ជនៈចល័តបង្ហាញសិស្ស ហើយសួរ តើនេះជាអក្សរអ្វី ?
- ឱ្យសិស្សអានព្យញ្ជនៈនោះ រួចសរសេរលើក្ដារឆ្នួន ។ ចំពោះព្យញ្ជនៈផ្សេងទៀត គ្រូធ្វើដូចព្យញ្ជនៈទី ១ ដែរ ។
- គ្រូបិទតារាងព្យញ្ជនៈ ហើយគ្រូចង្អុលឱ្យសិស្សអានតាមលំដាប់ រួចបញ្ច្រាសមកវិញ ។
- ហៅព្យញ្ជនៈឆ្លាស់ចុះឡើងឱ្យសិស្សសរសេរលើក្ដារឆ្នួន ។
- ចែកសិស្សជាក្រុមតូចៗ ហើយឱ្យពួកគេអានសៀវភៅដោយម្នាក់ចង្អុលព្យញ្ជនៈឆ្លាស់ចុះឡើង អ្នកឯទៀតអាន រួចដូរវេនគ្នាចង្អុល ។

### ៦.៣ លំនាំបង្រៀនរំឭកព្យញ្ជនៈ ពួក អ ពួក អ៊ ផ្សំនឹងស្រៈ

- គ្រូលើកអក្សរចល័ត ក រួចសួរ តើនេះជាអក្សរអ្វី ? គ្រូបង្ហាញស្រៈ ា រួចសួរដូចមុន ។
- គ្រូយកស្រៈ ា ផ្សំនឹង ក ឱ្យសិស្សអាន ។ គ្រូសួរតើ "កា" មានអក្សរអ្វីខ្លះ ?
- គ្រូបង្ហាញរូបភាពកោះ រួចសួរសិស្ស តើនេះជារូបភាពអ្វី ? ឱ្យសិស្សថាពាក្យនោះ ៣-៤នាក់ រួចថាទាំងអស់គ្នា ។
- គ្រូបង្ហាញបណ្ណពាក្យរួចសរសេរពាក្យលើក្ដារខៀន ឱ្យសិស្សអាន ។



www.elibraryofcambodia.org

- គ្រូសួរសិស្ស ៖ តើពាក្យ "កោះ" មានព្យញ្ជនៈនិងស្រៈអ្វីខ្លះ ? គ្រូប្រើអក្សរចល័តបំបែកពាក្យ រួចផ្សំពាក្យឱ្យសិស្សអាន ។
- គ្រូអានពាក្យឱ្យសិស្សអានតាម ។ ចំពោះពាក្យផ្សេងទៀត ធ្វើតាមលំនាំបង្រៀនពាក្យ "កោះ" ដែរ តែគ្រូចង្អុលពាក្យឱ្យសិស្សអានជាក្រុមរួម រួចក្រុមតូចៗ ។
- គ្រូឱ្យសិស្សសរសេរពាក្យលើក្ដារឆ្នួន ។

បញ្ជាក់ : មេរៀននេះជាមេរៀនរំឭក គ្រូមិនគប្បីបង្រៀនព្យាង្គទៀតទេ ។ គ្រូគប្បីបង្រៀនតែពាក្យគន្លឹះមួយចំនួន ហើយឱ្យសិស្សហ្វឹកហាត់អានពាក្យ ល្បះ តែម្ដងមិនចាំបាច់បង្រៀនល្បះទេ ។

- គ្រូចែកសិស្សជាក្រុមតូចៗ ។ ឱ្យសិស្សហ្វឹកហាត់អានពាក្យ ល្បះក្នុងសៀវភៅតាមក្រុមដោយប្រើសៀវភៅអានរួមគ្នាសម្រាប់ក្រុមនីមួយៗ ។
- ឱ្យសិស្សអានសៀវភៅជាដៃគូ ដោយម្នាក់ចង្អុល ម្នាក់អាន រួចដូរវេនគ្នា ។
- ឱ្យសិស្សអានសៀវភៅជាបុគ្គល គ្រូដើរជួយសិស្សដែលជួបការលំបាក ។

## ៦.៤ លំនាំបង្រៀនរំឭក ង៉ ញ៉ ប៊ ម៉ យ៉ រ៉ វ៉

- គ្រូយកផ្ទាំងព្យញ្ជនៈដាក់ផ្ទូគ្នា រួចចង្អុលអក្សរ ង ញ ប ម យ រ វ ម្ដងមួយតួៗ រួចសួរសិស្ស ៖ តើនេះជាអក្សរអ្វី ?

| | |
|---|---|
| ង | ង៉ |
| ញ | ញ៉ |
| ប | ប៊ |
| ម | ម៉ |
| យ | យ៉ |
| រ | រ៉ |
| វ | វ៉ |



www.elibraryofcambodia.org

- គ្រូចង្អុលម្ដងមួយតួៗ ង ង៉ និងបញ្ចេញសំឡេងឱ្យសិស្សស្ដាប់ ។ គ្រូនិងសិស្សអានជាមួយគ្នា រួចសិស្សអានខ្លួនឯងជាក្រុមតូចៗ ។ *ឧទាហរណ៍ : ង ង៉...* ។
- គ្រូបង្រៀនពាក្យដោយធ្វើតាមលំនាំបង្រៀនពាក្យក្នុងមេរៀនព្យញ្ជនៈផ្សំស្រៈមុនៗដែរ ។
- គ្រូឱ្យសិស្សសរសេរពាក្យលើក្ដារខៀន ។
- ឱ្យសិស្សហ្វឹកហាត់អានសៀវភៅជាដៃគូ ដោយដំបូងអានរួមគ្នា បន្ទាប់មកអានម្ដងម្នាក់ៗ។
- ឱ្យសិស្សអានសៀវភៅជាបុគ្គល ។

*ចំណាំ :*

- មូសិកទន្ត ឬធ្មេញកណ្ដុរ (៉) ជាវណ្ណយុត្ត សម្រាប់ប្រើសម្លាប់បំបែរសំឡេងព្យញ្ជនៈ ពួក អ៊ ឱ្យទៅជាពួក អ ។
- ចំពោះស្រៈ ួ ឿ ៀ មិនចាំបាច់ប្រើសញ្ញាមូសិកទន្ត (៉)ទេ ព្រោះការប្រើសញ្ញានេះ ក៏សួរមិនដូរដែរ គឺដូចសំឡេងពួក អ៊ ជានិច្ច ។

## ៦.៥ លំនាំបង្រៀនវព្ជក ប៊ ស៊ ហ៊ អ៊

- គ្រូត្រូវយកផ្ទាំងព្យញ្ជនៈដាក់ផ្ទួគ្នា រួចចង្អុលអក្សរ ប ស ហ អ ម្ដងមួយតួ រួចសួរសិស្ស ៖ តើនេះជាអក្សរអ្វី ?

| | |
|---|---|
| ប | ប៊ |
| ស | ស៊ |
| ហ | ហ៊ |
| អ | អ៊ |

- គ្រូចង្អុលម្ដងមួយតួៗ (អ អ៊) និងបញ្ចេញសំឡេងឱ្យសិស្សស្ដាប់ ។ គ្រូនិងសិស្សអានជាមួយគ្នា រួចសិស្សអានខ្លួនឯងជាក្រុមតូចៗ ។ *ឧទាហរណ៍* ប ប៊ ។
- គ្រូបង្រៀនពាក្យ ដោយធ្វើតាមលំនាំបង្រៀនព្យញ្ជនៈពួក អ៊ ផ្សំស្រៈ ។
- គ្រូនាំសិស្សអានពាក្យ ៖ សាប៊ូ កៅស៊ូ ប៉ាហ៊ី ភាស៊ី ដោយប្រកប ។

  សា+ ប៊ អ៊ូ ប៊ូ សាប៊ូ  កៅ+ ស៊ អ៊ូ ស៊ូ កៅស៊ូ  ប៉ា+ ហ៊ អ៊ី ហ៊ី ប៉ាហ៊ី  ភា+ ស៊ អ៊ី ស៊ី ភាស៊ី
- គ្រូឱ្យសិស្សសរសេរពាក្យលើក្ដារខៀន បន្ទាប់មកអានដោយមិនបាច់ប្រកប ។
- ឱ្យសិស្សហ្វឹកហាត់អានជាដៃគូដោយប្រើសៀវភៅតែមួយរួមគ្នា រួចម្នាក់ចង្អុលម្នាក់អាន ហើយដូរវេនគ្នាចង្អុល ។ គ្រូតាមដាននិងជួយសិស្ស ។
- ឱ្យសិស្សអានសៀវភៅជាបុគ្គល ។ គ្រូគប្បីដើរជួយសិស្សជួបការលំបាក ។



www.elibraryofcambodia.org

*ចំណាំ ៖*

- ត្រីសព្ទ ឬសញ្ញាសក់ក ឬសញ្ញាអ៊ី (៊)ជាវណ្ណយុត្ត សម្រាប់ប្រើលើព្យញ្ជនៈ ៤តួគឺ ៖ ប ស ហ អ ឱ្យទៅជាពួក អ៊ី ។
- ចំពោះស្រៈ ុ ឿ ៀ មិនចាំបាច់ប្រើសញ្ញាត្រីសព្ទ (៊)ទេ ព្រោះការប្រើសញ្ញានេះ ក៏មិនបានធ្វើឱ្យសូរដូរដែរ ។

## ៦.៦ លំនាំបង្រៀនរំឭកពាក្យប្រកប ( ពួក អ និងពួក អ៊ី )

- គ្រូបង្ហាញរូបភាព ឬសម្ភារៈជាក់ស្តែង រួចសួរ តើនេះជាអ្វី ?
- គ្រូបង្ហាញបណ្ណពាក្យរួចសរសេរពាក្យលើក្តារខៀនឱ្យសិស្សអាន ។
- គ្រូសួរសិស្ស ៖ តើពាក្យ ... មានព្យញ្ជនៈនិងស្រៈអ្វីខ្លះ ? គ្រូប្រើអក្សរចល័តបំបែកផ្សំពាក្យខ្លះៗឱ្យសិស្សអាន ។ ចំពោះពាក្យផ្សេងទៀតធ្វើតាមលំនាំពាក្យទី ១ដែរ ប៉ុន្តែគ្រូមិនគប្បីបង្រៀនគ្រប់ពាក្យទេ តែគប្បីបង្រៀនពាក្យគន្លឹះដែលមានក្នុងល្បះ ដើម្បីឱ្យសិស្សអាចអានល្បះបាននៅពេលឱ្យគេហ្វឹកហាត់អានតាមក្រុម ។

  *ឧទាហរណ៍ ៖* កា មកផ្សំជាមួយនឹង ក រួចបញ្ចាក់ ៖

  - កា និង ក ⟶ កាក
  - ច និង ក ⟶ ចក
- គ្រូអានពាក្យទាំងអស់ដែលបានរៀនរួចឱ្យសិស្សអានតាម ។
- ឱ្យសិស្សអានពាក្យនីមួយៗឡើងវិញ ។
- ឱ្យសិស្សធ្វើអក្ខរវិញ្ញាស គ្រប់ពាក្យដែលបានរៀនរួច ។
- គ្រូឱ្យសិស្សសរសេរពាក្យលើក្តារឆ្នួន ។
- ឱ្យសិស្សហ្វឹកហាត់អានពាក្យ ល្បះតាមក្រុមតូចៗរួមគ្នា ដោយប្រើសៀវភៅតែមួយរួមគ្នា ។
- ឱ្យសិស្សអានសៀវភៅជាដៃគូដោយលើកទី ១ អានរួមគ្នា លើកទី ២ អានម្នាក់ម្តង ។
- ឱ្យសិស្សអានសៀវភៅជាបុគ្គល ។ គ្រូគប្បីដើរជួយសិស្សរៀនយឺត ។

  *កំណត់សម្គាល់ ៖*

  - គ្រូត្រូវចៀសវាងចំពោះការបណ្តោយឱ្យសិស្សថា ក អា កា នេះទៀត ពីព្រោះបើបង្រៀនមកដល់មេរៀននេះ សិស្សបានរៀនផ្សំព្យញ្ជនៈជាមួយនឹងស្រៈរួចស្រេចទៅហើយមិនចាំបាច់ថាម្តងទៀតទេ គឺទម្លាប់ឱ្យថា កា ចិ លោ រៀ ...តែម្តង (មានប្រយោជន៍ដល់ពេលអានអត្ថបទសិស្សមិនបាច់ប្រកបទៀត) ។



www.elibraryofcambodia.org

## ៦.៧ លំនាំបង្រៀនរំឭកស្រះពេញតួ

- គ្រូបង្ហាញស្រះពេញតួចល័តម្តងមួយៗ ដោយមិនតាមលំដាប់ រួចឱ្យសិស្សអានរហូតដល់គ្រប់ ១៥តួ ។ គ្រូបិទតារាងស្រះពេញតួ ឬសរសេរលើក្តារខៀន ។
- គ្រូចង្អុលស្រះពេញតួមិនតាមលំដាប់ រួចឱ្យសិស្សអាន រួចសរសេរលើក្តារឆ្នួន ។ គ្រូអានស្រះពេញតួតាមលំដាប់ឱ្យសិស្សអានតាម ។
- គ្រូបង្ហាញរូបឪពុក រួចសួរសិស្សថារូបអ្វី ? គ្រូអាចសាកល្បងឱ្យសិស្សម្នាក់ឡើងសរសេរពាក្យក្រោមរូបឪពុក សិស្សឯទៀតសរសេរលើក្តារឆ្នួន ។ បើសិស្សសរសេរមិនបានគ្រូសរសេរ ។ គ្រូអាចបិទរូបផ្សេងទៀត ប្រសិនបើមាន រួចធ្វើរបៀបនេះដដែល ។
- ឱ្យសិស្សបើកសៀវភៅអានពាក្យ ល្បះ តាមក្រុមតូចៗ ឬដៃគូ ។
- ហៅសិស្សរៀនយឺត អានពាក្យ ឬល្បះខ្លះៗដោយប្រើសៀវភៅរបស់គេ ។

## ៦.៨ លំនាំបង្រៀនអាននិងសរសេរព្យញ្ជនៈផ្ញើជើង

- គ្រូបង្ហាញអក្សរចល័ត ខ រួចសួរ ៖ តើនេះជាអក្សរអ្វី ? គ្រូបង្ហាញជើង ◌្ខ រួចសួរតើនេះជាជើងអក្សរអ្វី ? គ្រូយក ខ ដាក់លើជើង ◌្ខ រួចឱ្យសិស្សអាន ឬគ្រូអាន (ខ ◌្ខ ខ្ខ)ឱ្យសិស្សថាតាមទាំងអស់គ្នា ។ សិស្សថាតាមជាក្រុមតូចៗ ។
- គ្រូយកស្រះ ◌ា ◌ិ ◌ី ◌ឹ ◌ឺ មកផ្សំជាមួយ ខ្ខ ម្តងមួយៗ ហើយឱ្យសិស្សអានជាក្រុម ឬជាបុគ្គល ។

  **ចំពោះព្យញ្ជនៈ ខ ផ្សំនឹងជើងផ្សេងទៀត គ្រូគប្បីធ្វើដូច ខ ផ្សំនឹងជើង ◌្ខ ដែរ ។**

- គ្រូលើករូបភាព ឬសម្ភារៈជាក់ស្តែងបង្ហាញសិស្ស ដើម្បីបង្រៀនពាក្យ ខ្លាយ ។ ឱ្យសិស្សប្រាប់ឈ្មោះរូបភាព ឬវត្ថុនោះ ។
- គ្រូបង្ហាញបណ្ណពាក្យ និងអានពាក្យឱ្យសិស្សថាតាម ។
- នាំសិស្សវិភាគពាក្យដោយប្រើអក្សរចល័ត ហើយសួរថា ៖ តើពាក្យ ខ្លាយ មានអក្សរអ្វីខ្លះ ? គ្រូសរសេរពាក្យនៅលើក្តារខៀន ៖
- ឱ្យសិស្សសរសេរពាក្យ "ខ្លាយ"នៅលើក្តារឆ្នួន ។ ចំពោះពាក្យផ្សេងទៀត គ្រូត្រូវបង្រៀនដូចពាក្យ ខ្លាយ ដែរ ។ គ្រូគប្បីបង្រៀនពាក្យថ្មីដែលមានក្នុងល្បះ ហើយមិនបាច់បង្រៀនល្បះទេ ។
- គ្រូអានពាក្យឱ្យសិស្សអានតាម ។ គ្រូអានពាក្យ ឱ្យសិស្សចង្អុលពាក្យនៅក្នុងសៀវភៅរបស់ពួកគេ និងអានពាក្យនោះ ។



www.elibraryofcambodia.org

- ឱ្យសិស្សអានសៀវភៅតាមក្រុមតូចៗ ឬជាដៃគូ ។ (បើអានតាមក្រុម ត្រូវឱ្យសិស្សម្នាក់ចង្អុល អ្នកឯទៀតអាន រួចដូរគ្នាចង្អុល) ។ គ្រូតាមដាននិងជួយសិស្ស ។
- ឱ្យសិស្សអានសៀវភៅជាបុគ្គល ។ គ្រូជួយសិស្សជួបការលំបាក ។

## ៦.៩ លំនាំបង្រៀនអាននិងសរសេរពាក្យព្យាង្គតម្រួត

- គ្រូបង្ហាញសម្ភារៈជាក់ស្តែង ឬរូបភាពដើម្បីបំផុសរកពាក្យ ។
- គ្រូថាពាក្យឱ្យសិស្សថាតាមចំនួន ២-៣ដង ។ គ្រូបង្ហាញបណ្ណពាក្យ ហើយសួរថា តើនេះជាពាក្យអ្វី ?
- គ្រូសរសេរពាក្យនោះនៅក្តារខៀនដោយប្រើដីសពណ៌ ។ គ្រូអានពាក្យនោះឱ្យសិស្សថាតាមជាក្រុមតូចៗ ។
- គ្រូអានពាក្យ "កង្កែប" ដោយបំបែកជាពីរព្យាង្គយឺតៗ ។ *ឧទាហរណ៍* [ កង់-កែប ] ២-៣ដង ។ គ្រូសួរសិស្ស តើពាក្យ "កង្កែប" មានប៉ុន្មានម៉ាត់ ឬប៉ុន្មានព្យាង្គ ? អ្វីខ្លះ ? បើសិស្សមិនអាចឆ្លើយបាន គ្រូប្រាប់ថា "កង្កែប" មាន ២ព្យាង្គ គឺ [ កង់ ] និង [ កែប ] ។

  កង្កែប = [ កង់ ] [ កែប ] ព្យាង្គទី ១ កង់ , ព្យាង្គទី ២ កែប ,
- គ្រូនាំសិស្សអាន ក និង ង ត្រូវអានថា កង់ ជើង ្ក ត្រូវអានដូចជាព្យញ្ជនៈ ក ដែរ ។ ដូចនេះ កង្កែប ត្រូវអានថា ក និង ង កង់ ជើង ក ស្រៈ ែ◌ និង ប អានថា កែប ។ សួរសិស្សថា ៖ តើពាក្យ កង្កែប មានអក្សរអ្វីខ្លះ ? *ចម្លើយ :* កង្កែប មាន ក ង ជើង ្ក ស្រៈ ែ◌ និង ប ។
- ឱ្យសិស្សសរសេរពាក្យ កង្កែប នៅលើក្តារឆ្នួន ។
- គ្រូបន្តបង្រៀនពាក្យគន្លឹះផ្សេងទៀតដែលមាន ង្ខ ង្គ ង្ឃ មួយពាក្យៗដោយមិនចាំបាច់បង្រៀនគ្រប់ពាក្យដែលមានក្នុងសៀវភៅនោះទេ ។
- គ្រូអានពាក្យឱ្យសិស្សអានតាម ។
- គ្រូចង្អុលពាក្យឱ្យសិស្សអានជាក្រុមតូចៗ រួចអានទាំងអស់គ្នា ។
- គ្រូចែកសិស្សជាក្រុមតូចៗ ឬដៃគូ ។ ឱ្យសិស្សអានសៀវភៅនៅតាមក្រុម ដោយម្នាក់ចង្អុល អ្នកឯទៀតអានរួចដូរវេនគ្នា ។ គ្រូដើរមើល និងជួយសិស្សជួបការលំបាក ។
- គ្រូហៅពាក្យក្នុងសៀវភៅឱ្យសិស្សចង្អុលនិងអានពាក្យនោះ រួចសរសេរលើក្តារឆ្នួនម្តងមួយៗ ។ គ្រូហៅល្បះឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅដោយយឺតៗ រួចឱ្យសិស្សអានល្បះនោះឡើងវិញនៅពេលសរសេររួច ។



www.elibraryofcambodia.org

*ចំណាំ :*

- គ្រប់មេរៀនបើមានពាក្យ ឬឃ្លាច្រើន គ្រូមិនត្រូវបង្រៀនទាំងអស់នោះទេ គឺដកយកតែពាក្យគន្លឹះ ដូចជា ពាក្យមាន ង្ក ង្ខ ង្គ ង្ឃ មួយពាក្យៗ ហើយបន្ថែមពាក្យថ្មីក្នុងល្បះ ដើម្បីឱ្យសិស្សមានពេលហ្វឹកហាត់ ។ ពាក្យ ឬឃ្លានៅសល់ ត្រូវទុកឱ្យសិស្សហ្វឹកហាត់អានបន្ថែម ។
- គ្រប់មេរៀនមិនត្រូវបង្រៀនអាននិងសរសេរនៅថ្ងៃផ្សេងគ្នាទេ គឺត្រូវបង្រៀននៅថ្ងៃជាមួយគ្នា ។ គ្រូគប្បីបង្រៀនអាន រួចសរសេរពាក្យនោះតែម្ដង ។

  *សម្គាល់ :* ន្ត្រ ន្ទ្រ ត្រូវអានដូចខាងក្រោម ៖

  - ន ជើង ត ជើង រ  ន ជើង ទ ជើង រ ។
  - ទន្ទ្រាន = ទ និង ន ទន់ ទ ជើង ្រ ទ្រ ទ្រ អា ទ្រា និង ន ទ្រាន ⟶ ទន្ទ្រាន ។
  - កន្ត្រៃ = ក និង ន កន់ ត ជើង ្រ ត្រ ត្រ អៃ ត្រៃ ⟶ កន្ត្រៃ ។

## ៦.១០ លំនាំបង្រៀនអានអត្ថបទ

លំនាំបង្រៀនអានមានបំណងបណ្ដុះបណ្ដាលសិស្សលើបំណិនអាន ពាក្យ ឃ្លា ល្បះ រហូតដល់ការអានអត្ថបទបានត្រឹមត្រូវមិនទាក់ ឬរដាក់រដុបនិងដើម្បីជួយដល់ការសរសេរបានត្រឹមត្រូវច្បាស់លាស់ថែមទៀតផង ។

### ក. ការចាប់ផ្ដើមមេរៀន

- **ការប្រើសំណួរបំផុស :** គ្រូសួរសំណួរបំផុសមួយចំនួន ដើម្បីស្ទាបស្ទង់ចំណេះដឹងឬបទពិសោធរបស់សិស្សទាក់ទងនឹងមេរៀនថ្មី ។
- គ្រូឱ្យសិស្សមើលរូបភាព រួចគ្រូសួរសំណួរលើរូបភាព ។
- **ការអានលើកទី ១ :**
  - គ្រូឱ្យសិស្សអានអត្ថបទរៀងៗខ្លួនដោយស្ងៀមស្ងាត់ ។
  - គ្រូឱ្យសិស្សម្នាក់ៗរកពាក្យដែលគេមិនទាន់ចេះអាននិងពិបាកយល់ន័យ ហើយប្រាប់គ្រូឱ្យសរសេរពាក្យទាំងនោះនៅលើក្ដារខៀន ។
- **ការរៀនពាក្យ :** គ្រូនាំសិស្សរៀនពាក្យពិបាកក្នុងសៀវភៅសិស្សរួមមាន ៖
  - អំណានពាក្យ
  - ពន្យល់ពាក្យ
  - ពាក្យផ្ទុយ
  - ពាក្យន័យដូច



www.elibraryofcambodia.org

*បញ្ជាក់* : ចំពោះមេរៀនដំបូង នៅពេលសិក្សាពាក្យផ្ទុយ និងពាក្យន័យដូច គ្រូត្រូវប្រាប់បញ្ញត្តិពាក្យផ្ទុយ និងពាក្យន័យដូចទៅសិស្សជាមុន ៖

- ពាក្យផ្ទុយ គឺជាពាក្យដែលមានន័យផ្ទុយគ្នា ។
- ពាក្យន័យដូច គឺជាពាក្យដែលមានន័យដូចគ្នា តែសរសេរខុសគ្នា ។

- ក្នុងករណីមានពាក្យពិបាកផ្សេងទៀតនៅក្នុងអត្ថបទ ហើយមិនមានប្រាប់ក្នុងការរៀនពាក្យ គ្រូគប្បីបង្រៀនដោយអានពាក្យទាំងនោះឱ្យសិស្សស្ដាប់និងអានតាម ។
- គ្រូហៅពាក្យម្ដងមួយៗឱ្យសិស្សសរសេរលើក្ដារខៀន ។
- គ្រូពន្យល់ន័យរបស់ពាក្យ ដោយប្រើប្រាស់រូបភាព វត្ថុជាក់ស្ដែងជាជំនួយ លើកឧទាហរណ៍ ធ្វើការប្រៀបធៀប ឬធ្វើកាយវិការ ដើម្បីបញ្ជាក់ន័យរបស់ពាក្យទៅតាមប្រភេទពាក្យនីមួយៗ ។
- **ការអានលើកទី ២ :**
  - គ្រូអានអត្ថបទមួយចប់ដោយមានការលើកដាក់សំឡេងជាគំរូ ។ សិស្សម្នាក់ៗផ្ទៀងតាមដោយប្រើអត្ថបទនៅក្នុងសៀវភៅរបស់គេ ។
  - គ្រូនិងសិស្សអានអត្ថបទជាមួយគ្នា ។
  - ចែកសិស្សជាក្រុមតូចៗ ។ ឱ្យសិស្សតាមក្រុមអានរួមគ្នាដោយប្រើសៀវភៅតែមួយ ។
  - ឱ្យសិស្សអានសៀវភៅជាដៃគូរួមគ្នា ។
  - ឱ្យសិស្សអានសៀវភៅជាបុគ្គល ។
  - ឱ្យសិស្សអានសំណួរក្នុងសៀវភៅជាមុនសិន មុននឹងអានអត្ថបទ ។
  - ឱ្យសិស្សអានអត្ថបទដោយស្ងៀមស្ងាត់ម្ដងទៀត ដើម្បីយល់ខ្លឹមសារមេរៀន ។
  - ឱ្យសិស្សឆ្លើយសំណួរនៅក្នុងសៀវភៅ (ពេលឆ្លើយសំណួរត្រូវឱ្យសិស្សបិទសៀវភៅ) ។ បើសិស្សមិនអាចឆ្លើយនឹងសំណួរណាមួយបាន គ្រូត្រូវឱ្យសិស្សអានត្រង់វគ្គដែលទាក់ទងនឹងសំណួរទាំងនោះឡើងវិញដោយស្ងៀមស្ងាត់ ឬដោយឮៗ ដើម្បីយល់ន័យ ពាក្យនិងអាចឆ្លើយបាន ។
  - សួរសំណួរទាក់ទងបទពិសោធដែលសិស្សយល់បានពីខ្លឹមសារ និងន័យនៃអត្ថបទផ្សារភ្ជាប់នឹងការរស់នៅរបស់គេជាក់ស្ដែង ។



www.elibraryofcambodia.org

### ខ. ការបញ្ចប់មេរៀន

ហៅសិស្សរៀនយឺតអានបណ្ដាក់គ្នា ២-៣ល្បះម្នាក់ រួចគ្រូសរសើរលើកទឹកចិត្តសិស្ស ។

*បញ្ជាក់ :* ចំពោះមេសូត្រ និងចម្រៀង គ្រូច្រៀង ឬសូត្រឱ្យឮៗ តាមបែបបទនៃបទនីមួយៗជាគំរូ ។ គ្រូអាចឱ្យសិស្សដែលចេះសូត្រ ឬច្រៀង ឱ្យច្រៀង ឬសូត្រជាគំរូ សិស្សដទៃទៀតស្ដាប់តាមដោយស្ងៀមស្ងាត់ ។ គ្រូសូត្រ ឬច្រៀងមួយឃ្លាម្ដងៗ មួយវគ្គម្ដងៗ រួចឱ្យសិស្សថាតាមជាក្រុម ជាបុគ្គល ។

### គ .ការវាយតម្លៃ

- ឱ្យសិស្សហ្វឹកហាត់អានពាក្យដោយមិនបាច់ផ្ទៀងនិងប្រកប ឬធ្វើលំហាត់ផ្សេងទៀតក្នុងសៀវភៅតាមក្រុម ឬដៃគូ ។ គ្រូសម្របសម្រួលចម្លើយតាមក្រុមនីមួយៗ
- ហៅសិស្សរៀនយឺត ឬមធ្យមឱ្យអានអត្ថបទឡើងវិញ ។ សិស្សដទៃទៀតជួយកែលម្អ ។

## ៦.១១ លំនាំបង្រៀនសំណេរ

លំនាំបង្រៀនសំណេរ មានបំណងបណ្ដុះស្មារតីនិងការចងចាំក្នុងការសរសេរពាក្យ ចម្លងពាក្យ បំពេញល្បះនឹងពាក្យ តែងល្បះតាមរូបភាព សរសេរពាក្យតាមរូបភាព សំណេរបំពេញល្បះ សរសេរតាមអានរៀបចំ សរសេរតាមអានចម្លង សរសេរតាមអានត្រួតពិនិត្យ ដើម្បីឱ្យសិស្សមានបំណិនសំណេរយ៉ាងប៉ិនប្រសប់ ឈ្លាសវៃ មិនមានកំហុសអក្ខរាវិរុទ្ធ ។

## ៦.១២ លំនាំបង្រៀនអក្សរផ្ចង់

- គ្រូគូសបន្ទាត់ផ្ដេកនៅលើក្ដារខៀនតាមទម្រង់ ១/២ដូចគំរូខាងក្រោម ៖





www.elibraryofcambodia.org

- គ្រូណែនាំសិស្សអំពីរបៀបគូសបន្ទាត់តាមគំរូខាងលើ ។ នៅក្នុងសៀវភៅសិស្សមានក្រឡាបន្ទាត់ស្រេចហើយ គ្រូគ្រាន់តែនាំសិស្សគូសបន្ទាត់ទ្រេតតាមក្រឡាបន្ទាត់ក្នុងសៀវភៅសិស្សតែប៉ុណ្ណោះ ។
- គ្រូសរសេរគំរូនៅលើក្តារខៀនយឺតៗតាមចលនានីមួយៗឱ្យសិស្សសង្កេតតាម ។ ដំបូងគ្រូសរសេរអក្សរ "ឈ" ដោយកំណត់យកកម្ពស់ ៤/៤ ទទឹង ២/៣ជួរទី ១ បន្ទាប់មកសរសេរតួអក្សរ "ឈ" ដោយកំណត់យកកម្ពស់ ២/៤ ទទឹង ១/៣ ជួរទី ២ ។
- គ្រូឱ្យសិស្សហាត់សរសេរអក្សរនៅលើក្តារឆ្នួនតាមគំរូនៅលើក្តារខៀន ។ គ្រូត្រួតពិនិត្យនិងកែលម្អ ។
- គ្រូឱ្យសិស្សហាត់សរសេរអក្សរផ្ទង់នៅក្នុងសៀវភៅរៀងៗខ្លួន ។ គ្រូប្រមូលមកកែដាក់ពិន្ទុ ។

## ៦.១៣ លំនាំបង្រៀនបំពេញពាក្យក្នុងល្បះ

- គ្រូឱ្យសិស្សម្នាក់ៗអានល្បះក្នុងសៀវភៅឬគ្រូចម្លងលំហាត់ដាក់លើក្តារខៀន ឬបិទបណ្ណលំហាត់រួចឱ្យសិស្ស ២- ៣នាក់អាន ឯសិស្សដទៃទៀតតាមដានស្តាប់ដោយយកចិត្តទុកដាក់ ។ គ្រូគប្បីណែនាំសិស្សបន្ថែមពីរបៀបធ្វើលំហាត់បំពេញល្បះនឹងពាក្យ ។ បើលំហាត់នេះមានរូបភាពផងគ្រូត្រូវបង្ហាញ ឬបិទរូបភាពនៅលើក្តារខៀនពីលើល្បះនីមួយៗឱ្យសិស្សយល់ ។
- គ្រូឱ្យសិស្សអានល្បះទី ១ រួចសួរ ៖ តើអ្នកយល់ល្បះនេះឬទេ ? តើអ្នកធ្វើដូចម្តេចដើម្បីយល់ល្បះនេះ ? (ចម្លើយ ត្រូវបំពេញពាក្យក្នុងចន្លោះល្បះ) ។
- គ្រូឱ្យសិស្សម្នាក់អានពាក្យក្នុងប្រអប់មុននឹងបំពេញ ដើម្បីដឹងថាត្រូវជ្រើសរើសយកពាក្យណាមួយមកបំពេញឱ្យត្រូវន័យនៃល្បះនិងរូបភាពនីមួយៗនោះ ។
- គ្រូឱ្យសិស្សម្នាក់ឡើងសរសេរពាក្យនោះត្រង់ចន្លោះល្បះ រួចឱ្យសិស្សអានល្បះនោះឡើងវិញ ។
- គ្រូណែនាំសិស្សឱ្យបំពេញល្បះបន្តបន្ទាប់រហូតដល់ចប់តាមក្រុម ជាដៃគូ ឬជាបុគ្គល ដោយប្រើសៀវភៅរបស់គេ រួចដាក់ក្នុងសៀវភៅកិច្ចការ ។
- តំណាងក្រុមបង្ហាញចម្លើយដោយប្រាប់តែពាក្យតាមលំដាប់ល្បះនៅលើក្តារខៀន ។
- សិស្សទាំងអស់ចូលរួមវាយតម្លៃនិងជួយកែលម្អ ។
- គ្រូឱ្យសិស្សអានល្បះដែលបំពេញបានត្រឹមត្រូវឡើងវិញ រួចចម្លងល្បះដាក់ក្នុងសៀវភៅរៀងៗខ្លួន ។



www.elibraryofcambodia.org

## ៦.១៤ លំនាំបង្រៀនតែងល្បះតាមរូបភាព

- គ្រូឱ្យសិស្សអានការណែនាំធ្វើលំហាត់ក្នុងសៀវភៅ រួចគ្រូសួរ ៖ តើលំហាត់នេះតម្រូវឱ្យប្អូនធ្វើអ្វី ? (តែងល្បះតាមរូបភាព) ។ គ្រូពន្យល់សិស្សបន្ថែមអំពីរបៀបតែងល្បះតាមរូបភាព ដែលមានក្នុងលំហាត់នីមួយៗ ប្រសិនបើចាំបាច់ ។
- គ្រូឱ្យសិស្សសង្កេតរូបភាពនីមួយៗ រួចសួរ ៖ តើនេះជារូបអ្វី ?តើពាក្យនេះ ឬល្បះនេះមានន័យដូចម្ដេច ? បន្ទាប់មកឱ្យសិស្សធ្វើអក្ខរវិញ្ញាសនិងសរសេរលើក្ដារឆ្នួន ហើយឱ្យសិស្សឡើងសរសេរពាក្យនេះចំពីក្រោមរូបភាព ។
- គ្រូឱ្យសិស្សហាត់បង្កើតល្បះផ្សេងៗដោយមាត់ទទេ ទាក់ទងនឹងរូបភាពទី ១ ។ គ្រូកែលម្អខ្លឹមសារពាក្យពេចន៍ក្នុងល្បះនោះឱ្យបានត្រឹមត្រូវ ។
- គ្រូឱ្យសិស្សតាមក្រុម ជាដៃគូ តែងល្បះតាមរូបភាពដាក់ក្នុងសៀវភៅ ឬលើក្រដាស ។ តំណាងក្រុមឡើងបង្ហាញចម្លើយ ។ គ្រូកែលម្អកិច្ចការសិស្សតាមក្រុម ។
- គ្រូឱ្យសិស្សអានល្បះត្រឹមត្រូវឡើងវិញ រួចចម្លងដាក់ក្នុងសៀវភៅរៀងៗខ្លួន ។

## ៦.១៥ លំនាំបង្រៀនសរសេរតាមអាន

### ក. សរសេរតាមអានចម្លង(ពាក្យ កន្សោមពាក្យ ល្បះ និងអត្ថបទ)

- គ្រូឱ្យសិស្សម្នាក់ៗអានពាក្យក្នុងសៀវភៅ ឬគ្រូបិទបណ្ណពាក្យដែលត្រូវបង្រៀនដាក់លើក្ដារខៀន ។
- គ្រូអាននិងចង្អុលពាក្យម្ដងមួយឱ្យច្បាស់ៗ រួចសិស្សម្នាក់ៗចង្អុលនិងអានពាក្យនោះនៅក្នុងសៀវភៅសិស្ស ។
- គ្រូចង្អុលពាក្យទី ១ ហើយអានម្ដងទៀត ។ គ្រូឱ្យសិស្សថាតាម រួចធ្វើអក្ខរវិញ្ញាសពាក្យនោះ ។
- គ្រូឱ្យសិស្សសរសេរពាក្យនោះនៅលើក្ដារឆ្នួនទាំងអស់គ្នា ។ គ្រូពិនិត្យនិងកែតម្រូវសិស្សដែលសរសេរខុស ឱ្យកែឱ្យត្រូវឡើងវិញ ។
- គ្រូចង្អុលពាក្យទី ២ ទី ៣ រហូតគ្រប់ពាក្យ ដោយធ្វើតាមលំនាំបង្រៀនពាក្យទី ១ដែរ ។
- គ្រូហៅពាក្យឆ្លាស់គ្នាឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅរបស់គេ ។ គ្រូអានពាក្យទាំងនោះឡើងវិញ ឱ្យសិស្សផ្ទៀង ។ គ្រូទុកពេលសមល្មមឱ្យសិស្សពិនិត្យនិងកែកំហុស ។
- គ្រូប្រមូលសៀវភៅសិស្សកែដាក់ពិន្ទុ ឬឱ្យសិស្សប្ដូរគ្នាកែដោយផ្ទៀងជាមួយពាក្យក្នុងសៀវភៅ ។
- គ្រូណែនាំសិស្សឱ្យប្រគល់សៀវភៅទៅម្ចាស់ដើមវិញ ហើយឱ្យម្ចាស់សៀវភៅឆូតពាក្យខុសនឹងខ្មៅដៃ ហើយសរសេរពាក្យត្រូវនៅខាងលើពាក្យនោះវិញ ។
- គ្រូឱ្យសិស្សដែលសរសេរខុសលើសពីប្រាំពាក្យ ចម្លងពាក្យនោះឱ្យត្រូវទាំងអស់ឡើងវិញ ។



www.elibraryofcambodia.org

### ខ. សរសេរតាមអានរៀបចំ

- គ្រូបិទបណ្ណអត្ថបទដាក់លើក្ដារខៀន ។
- គ្រូអានពាក្យពិបាក ឬពាក្យគន្លឹះ រួចឱ្យសិស្សអានតាម ។
- គ្រូអានអត្ថបទដោយយឺតៗច្បាស់ៗ រួចឱ្យសិស្សអានឡើងវិញ ។
- គ្រូឱ្យសិស្សពន្យល់ពាក្យពិបាកៗ រួចឱ្យសិស្សធ្វើអក្ខរាវិរុទ្ធ ។
- គ្រូហៅពាក្យពិបាកៗឱ្យសិស្សសរសេរនៅលើក្ដារឆ្នួន ។
- គ្រូលាក់អត្ថបទ រួចហៅឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅមួយឃ្លាម្ដងៗ រហូតដល់ចប់ ។ បន្ទាប់មកហៅសំណួរឱ្យសិស្សសរសេរ ។
- គ្រូអានអត្ថបទឡើងវិញឱ្យសិស្សស្ដាប់និងផ្ទៀងផ្ទាត់ រួចទុកពេលឱ្យសិស្សពិនិត្យនិងកែ កំហុសរៀងៗខ្លួន ។
- គ្រូឱ្យសិស្សពន្យល់ពាក្យ រួចឆ្លើយនឹងសំណួរ ។
- គ្រូឱ្យសិស្សដូរសៀវភៅគ្នាកែតាមអត្ថបទបង្ហាញនៅលើក្ដារខៀន ។
- គ្រូប្រមូលសៀវភៅកិច្ចការសិស្សកែដាក់ពិន្ទុ ។

### គ. សរសេរតាមអានត្រួតពិនិត្យ

- គ្រូអានពាក្យ កន្សោមពាក្យ កថាខណ្ឌ ឬអត្ថបទឱ្យសិស្សស្ដាប់ ។
- គ្រូហៅពាក្យ កន្សោមពាក្យ ឃ្លាខ្លីៗចំនួនបីដងឱ្យសិស្សសរសេរតាមម្ដងមួយៗ រហូតដល់ចប់ ។
- គ្រូអាចឱ្យសិស្ស ២នាក់ថាតាមក្រោយពីគ្រូអាន ដោយសិស្សម្នាក់ថា មុននឹងខ្លួនសរសេរ ហើយម្នាក់ទៀតថាបន្ទាប់ពីខ្លួនសរសេររួច ។
- គ្រូអានឱ្យសិស្សស្ដាប់ឡើងវិញដោយយឺតៗនិងច្បាស់ៗ ដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់ និងទុកពេលឱ្យសិស្សកែកំហុស
- គ្រូប្រមូលកិច្ចការសិស្សកែដាក់ពិន្ទុ ។

## ៦.១៦ លំនាំបង្រៀននិយាយ

### ក. ការចាប់ផ្ដើមមេរៀន

- ការប្រើសំណួរបំផុស :

គ្រូសួរសំណួរបំផុសដើម្បីស្ទាបស្ទង់ចំណេះដឹងសិស្សដែលមានស្រាប់ ដោយឱ្យសិស្សនិយាយ ឬបង្ហាញពីអ្វីដែលពួកគេធ្លាប់ដឹងរួចមកហើយទាក់ទងនឹងមេរៀនថ្មី ។



www.elibraryofcambodia.org

ការបង្ហាញ :

- គ្រូឱ្យសិស្សពិនិត្យរូបភាពក្នុងសៀវភៅសិស្ស រួចនិយាយអំពីរូបភាពនោះទៅតាមសំណួររបស់គ្រូ ៖ តើប្អូនឃើញអ្វីខ្លះនៅលើរូបភាពនេះ ? តើនេះជារូបភាពអ្វី ? តើរូបភាពនេះបង្ហាញពីអ្វី ?
- គ្រូឱ្យសិស្សប្រាប់ពីស្ថានភាពនិងតួអង្គនៅក្នុងអត្ថបទសន្ទនា *ឧទាហរណ៍ :* អ្នកណាខ្លះកំពុងធ្វើអ្វីនៅឯណា ?
- គ្រូឱ្យសិស្សអានអត្ថបទពណ៌នា ឬអត្ថបទសន្ទនានៅក្នុងសៀវភៅសិស្សជាដៃគូឬបុគ្គល ។
- គ្រូឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្ស ដើម្បីបញ្ជាក់ការយល់ដឹងរបស់សិស្ស ។
- គ្រូសួរសំណួរទាក់ទងនឹងរបៀបនិយាយ ឬពាក្យ ឃ្លាចាំបាច់

(គ្រូគប្បីសរសេរពាក្យ ឬឃ្លាចាំបាច់មួយចំនួនសម្រាប់ប្រើក្នុងអត្ថបទដាក់លើក្ដារខៀន ដើម្បីឱ្យសិស្សចងចាំនិងងាយឆ្លើយនឹងសំណួរ ។)

### ខ. ការបញ្ចប់មេរៀន

- គ្រូឱ្យសិស្សបញ្ជាក់ឡើងវិញអំពីពាក្យ ឬឃ្លាដែលត្រូវប្រើ ឬនិយាយក្នុងអត្ថបទនោះ ។
- គ្រូឱ្យសិស្សហាត់និយាយតាមក្រុមតូចៗ ដោយប្រើឈ្មោះខ្លួនឯងនិងមិត្តភក្ដិ ។ គ្រូសម្របសម្រួលនិងសរសើរលើកទឹកចិត្តសិស្ស ។

### គ. ការវាយតម្លៃ

- គ្រូឱ្យសិស្សអានលំហាត់សន្ទនាក្នុងសៀវភៅសិស្សជាក្រុម ជាដៃគូ ជាបុគ្គល រួចត្រៀមគំនិតឡើងនិយាយ ។
- គ្រូឱ្យសិស្សឡើងនិយាយ ឬសន្ទនានៅមុខសិស្សឯទៀត ។ គ្រូសរសើរលើកទឹកចិត្តសិស្ស ។

## ៦.១៧ លំនាំបង្រៀនស្ដាប់

លំនាំបង្រៀនស្ដាប់មានបំណងបណ្ដុះស្មារតីសិស្សឱ្យយកចិត្តទុកដាក់ស្ដាប់ពាក្យពេចន៍ ឃ្លា ល្បះ និងខ្លឹមសារអត្ថបទ ហើយអាចឆ្លើយសំណួរ និទានរឿងឡើងវិញ ឬសំដែងតួតាមផ្នែកណាមួយនៃរឿងបានត្រឹមត្រូវ ពោលគឺសិស្សមានបំណិនក្នុងការស្ដាប់យល់ ។

### ក. ការចាប់ផ្ដើមមេរៀន

- ការប្រើសំណួរបំផុស :

- គ្រូឱ្យសិស្សឆ្លើយសំណួរបំផុសទាក់ទងពីអ្វីដែលពួកគេធ្លាប់ដឹង ។
- គ្រូឱ្យសិស្សមើលរូបភាព រួចគ្រូសួរសំណួរលើរូបភាព ។



www.elibraryofcambodia.org

- គ្រូឱ្យសិស្សអានចំណងជើងរឿង ពិនិត្យរូបភាព រួចឱ្យសិស្សទាយ ឬប៉ាន់ស្មានខ្លឹមសាររឿង ដោយគ្រូសួរថា តើអ្នកគិតថា រឿងនេះនិយាយពីអ្វី ?

- **ការស្ដាប់ :**

  - គ្រូឱ្យសិស្សអានសំណួរក្នុងសៀវភៅសិស្សជាមុនសិន ។
  - គ្រូនិទានរឿងឱ្យសិស្សស្ដាប់ដោយយឺតៗនិងប្រើសំឡេងច្បាស់ៗ ។

### ខ. ការបញ្ចប់មេរៀន

- គ្រូឱ្យសិស្សឆ្លើយសំណួរក្នុងសៀវភៅសិស្ស ។ បើសិស្សឆ្លើយសំណួរណាមួយមិនបាន គ្រូត្រូវនិទានរឿងត្រង់ផ្នែកនោះឡើងវិញ ដើម្បីឱ្យសិស្សស្ដាប់ឡើងវិញនិងអាចឆ្លើយបាន ។
- គ្រូសួរសំណួរថ្មីបន្ថែម ដើម្បីផ្សារភ្ជាប់បទពិសោធដែលសិស្សរៀនរួចទៅនឹងបទពិសោធជាក់ស្ដែងដែលសិស្សជួបប្រទះក្នុងការរស់នៅ ។

### គ. ការវាយតម្លៃ

- គ្រូឱ្យសិស្សនិទានរឿងតាមក្រុមតូចៗ ឬសំដែងតួតាមផ្នែកណាមួយនៃរឿង ឬគូររូបភាព ។
- គ្រូឱ្យសិស្សធ្វើលំហាត់ក្នុងសៀវភៅសិស្សតាមក្រុម ដៃគូ ឬបុគ្គល ។
- តំណាងក្រុមឡើងរាយការណ៍ចម្លើយ ។

## អត្ថបទស្ដាប់ : រឿង ក្អែកការកូន

មានសេចក្ដីតំណាលថា មានស្ដេចក្អែកមួយនៅអាស្រ័យលើចុងត្នោតយ៉ាងខ្ពស់ ។ ថ្ងៃមួយក្អែកនេះបានរៀបចំការកូនឱ្យមានគូស្រករ ។ ស្ដេចក្អែកបានចាត់ឱ្យពួកពលទៅអញ្ជើញភ្ញៀវមកស៊ីការ ។ លុះដល់ថ្ងៃកំណត់រៀបចំផ្សំផ្គុំកូនប្រុសស្រីទាំងពីរហើយ ពួកសត្វទាំងអស់ដែលក្អែកបានអញ្ជើញក៏បានមកជួបជុំ ផឹកស៊ីយ៉ាងគគ្រឹកគគ្រេង ។ និយាយពីស្ដេចអណ្ដើកដែលស្ដេចក្អែកអញ្ជើញមក ខំវារទៅនឹងគេដែរ តែដោយហេតុជើងវាខ្លីពេក ក៏មកដល់ក្រោយគេ ។ លុះទៅដល់ដើមត្នោត សត្វអណ្ដើកដក កមើលទៅខាងលើ ក៏ឃើញសត្វជាច្រើនកំពុងស៊ីផឹក ។ អណ្ដើកនឹកឃ្លានណាស់ តែមិនដឹងធ្វើដូចម្ដេចនឹងឡើងទៅលើចុងត្នោតបាន ។ ពេលនោះស្រាប់តែមានពស់មួយលូនមកដល់ ។ អណ្ដើកក៏សួរទៅពស់ ៖ "បងពស់ទៅណាដែរ ?" ពស់ឆ្លើយ ៖ "ខ្ញុំបម្រុងនឹងទៅស៊ីការកូនបងក្អែក ។ ចុះបងអណ្ដើកឯងមកទីនេះធ្វើអ្វីដែរ ?" ។ អណ្ដើកឆ្លើយ ៖ "ខ្ញុំបម្រុងទៅស៊ីការកូនបងក្អែកដែរ" ។ ពស់ប្រាប់អណ្ដើក ៖ "បើដូច្នោះសូមបងអណ្ដើកខាំកន្ទុយខ្ញុំមក ខ្ញុំនឹងលូនយោងឡើងទៅលើ តែសូមប្រយ័ត្នមាត់បន្តិច" ។ អណ្ដើកត្រេកអរក៏ខាំកន្ទុយពស់ភ្លាម ពស់ក៏ឡើងទៅលើចុងត្នោត ។ លុះទៅដល់លើចុងត្នោត ស្ដេចក្អែកក្រឡេកឃើញអណ្ដើក ក៏ស្រែកសួរជាការគួរសម ៖ "យី! បងអណ្ដើកអញ្ជើញមកដែរ ? " ។ អណ្ដើកភ្លេចខ្លួនឆ្លើយទទួលពាក្យគួរសមនេះវិញ ៖ "បាទ!" ។ មួយរំពេចនោះ អណ្ដើកក៏របូតមាត់ពីកន្ទុយពស់ ធ្លាក់ខ្ទាកមកលើដី បណ្ដាលឱ្យស្រាំស្នូកនៅជាប់ស្នាម រហូតមកដល់សព្វថ្ងៃនេះឯង ។



www.elibraryofcambodia.org

## អត្ថបទស្តាប់ ៖ រឿង កញ្ជ្រោងនិងកូនពពែ

មានមេពពែមួយរស់នៅជាមួយនឹងកូនក្នុងផ្ទះមួយក្បែរមាត់ព្រៃ ។ រាល់ថ្ងៃមុននឹងចេញទៅរកចំណី មេពពែតែងតែផ្តែផ្តាំកូន ៖ "នៅពេលដែលម៉ែមិននៅផ្ទះ កូនកុំដើរលេងផ្តេសផ្តាសឱ្យសោះ ។ ម្យ៉ាងទៀត បើមាននរណាគោះទ្វារហៅកូនឱ្យបើកទ្វារ ចូរកូនកុំបើក ព្រោះនៅក្នុងព្រៃនេះមានសត្វសាហាវច្រើនណាស់ ។ នៅពេលម៉ែត្រឡប់មកវិញ ម៉ែនឹងគោះទ្វារហៅកូន រួចលូកជើងមុខចូលចន្លោះក្រោមទ្វារបង្ហាញកូនជាសញ្ញា" ។ មេពពែផ្តែផ្តាំកូនរួចហើយក៏ចេញទៅរកចំណីបាត់ទៅ ឯកូនពពែក៏បិទទ្វារជិតធ្វើតាមបណ្តាំមេ ។ ពេលនោះ ជាឱកាសល្អសម្រាប់កញ្ជ្រោងមួយ ដែលបានចូលលួចស្តាប់ការផ្តែផ្តាំរបស់មេពពែ ។ មួយសន្ទុះធំក្រោយមក កញ្ជ្រោងក៏ចូលទៅគោះទ្វារតុកៗ តុកៗ តុកៗ ។ កូនពពែក៏សួរ ៖ "នរណាហ្នឹង ? ម៉ែឬ ? " ។ កញ្ជ្រោងក៏ឆ្លើយធ្វើសំឡេងដូចមេពពែ ៖ "គឺម៉ែណាកូន ។ កូនបើកទ្វារឱ្យម៉ែផង ម៉ែមកវិញហើយ" ។ កូនពពែ ៖ "សូមម៉ែលូកជើងបង្ហាញកូនមក" ។ កញ្ជ្រោងក៏លូកជើងតាមចន្លោះក្រោមទ្វារបង្ហាញកូនពពែ ។ កូនពពែស្រែកឡើង ៖ "ទេៗ ទេៗ មិនមែនម៉ែខ្ញុំទេ ជើងធំខ្មៅព្រីកដូចនេះ ពិតជាជើងកញ្ជ្រោង" ។

## អត្ថបទស្តាប់ ៖ រឿង ដឹងសងដឹង អំបែងសងអំបែង

មាននិទានមួយថា មានបុរសប្តីប្រពន្ធ មានកូនប្រុសម្នាក់ ។ បុរសជាប្តីនោះទៅខ្ចីដឹងពីសេដ្ឋីម្នាក់យកទៅកាប់អុស ។ នៅពេលបុរសនោះលើកដឹងឡើងកាប់ ស្រាប់តែដឹងរង្គោះខ្ទាតទៅត្រូវប្រើសមួយ ហើយប្រើសនោះក៏បោលចូលក្នុងព្រៃបាត់ទៅ ។ បុរសនោះបានទៅអង្វរសេដ្ឋីសុំសងដឹងថ្មីមួយជាពីរ រហូតដល់ដប់ ក៏សេដ្ឋីនៅតែមិនព្រមយក ។ បុរសនិងប្រពន្ធបានព្រមព្រៀងគ្នាយកកូនកំលោះឱ្យទៅបម្រើសេដ្ឋីជាសំណងដឹងនោះ ទើបសេដ្ឋីព្រមទទួល ។

ថ្ងៃក្រោយមក បុរសបានរកឃើញដឹងនៅជាប់នឹងខ្លួនសត្វប្រើសមួយងាប់រលួយ ។ គាត់មានសេចក្តីត្រេកអរខ្លាំងណាស់ក៏យកផ្លែដឹងមកលាងទឹកឱ្យស្អាត រួចយកទៅឱ្យសេដ្ឋី ហើយសុំយកកូនប្រុសមកវិញ ។

ថ្ងៃមួយបុរសប្តីប្រពន្ធនាំគ្នាដាល់អំបុកហូប ។ កូនសេដ្ឋីធុំក្លិនអំបុក នឹកចង់ហូប ។ សេដ្ឋីក៏ទៅខ្ចីអំបែងបុរសនោះ ។ លុះដាល់អំបុករួច ស្រាប់តែមានឆ្កែប្រខាំគ្នាពារលើអំបែងនោះបែកខ្ទេចអស់ ។ សេដ្ឋីទៅប្រាប់បុរសនោះ បុរសនោះយំគក់ទ្រូង ទោះសេដ្ឋីសុំសងអំបែងថ្មីមួយជាដប់ ក៏ពុំព្រមយកដែរ ។ រឿងនេះមានការប្តឹងផ្តល់គ្នាដល់ព្រះមហាក្សត្រ ។ ព្រះអង្គក៏កាត់ក្តីឱ្យសេដ្ឋីយកកូនស្រីខ្លួនទៅនៅបម្រើគ្រួសារបុរសនោះវិញ ។



www.elibraryofcambodia.org

មេរៀនទី
១

# ស្រៈនិស្ស័យនិងព្យញ្ជនៈ

## ស្រៈនិស្ស័យ

ា ិ ី ឹ ឺ ុ ូ ួ

ើ ឿ ៀ េ ែ ៃ ោ ៅ

ុំ ំ ាំ ះ ុះ េះ ោះ។

## ព្យញ្ជនៈនិងជើងព្យញ្ជនៈ



| ព្យញ្ជនៈ ពួក អ | ព្យញ្ជនៈ ពួក អ៊ |
|---|---|
| ក្ក ខ្ខ | គ្គ ឃ្ឃ ង្ង |
| ច្ច ឆ្ឆ | ជ្ជ ឈ្ឈ ញ្ញ |
| ដ្ដ ឋ្ឋ ណ្ណ | ឌ្ឌ ឍ្ឍ |
| ត្ត ថ្ថ | ទ្ទ ធ្ធ ន្ន |
| ប្ប ផ្ផ | ព្ព ភ្ភ ម្ម |
| ស្ស ហ្ហ ឡ្ឡ អ្អ | យ្យ រ្រ ល្ល វ្វ |







www.elibraryofcambodia.org

# មេរៀនទី ២ រំឭកព្យញ្ជនៈផ្សំស្រៈ

ក ខ ច ឆ ដ ឋ ណ ត ថ ប ផ ស ហ ឡ អ

កោះ ខោ ចុះ ឆៅ ដេរ តោ តឿ ថា
ឋី បោ ផុះ សេះ ហើរ ហោះ ឡូ អុំ

កក្កូរ ខះក ចរចា ដំណាំ ចំណី តាខេ បបរ ដំបៅ
កាផា សរសេរ សរសើរ ហូរហែ កីឡា អាហារ

កុំឌីចំណីឆៅ ។
បងចំណានខំដេរខោ ។
ថៃអាំសរសើរបុប្ផាថា ចេះថែដំណាំ ។



ដាំ



បងចំណានខំដេរខោ ។



www.elibraryofcambodia.org

# មេរៀនទី ៣ រំឭកព្យញ្ជនៈផ្សំស្រៈ

**គ ឃ ង ជ ឈ ញ ឌ ឍ ទ ធ ន ព ភ ម យ រ ល វ**

គោ គោះ ឌឺ ឃុំ ងំ ជូរ ជោរ ឈឺ ឈើ ញី ទា ទំ

ធូរ ធំ នៅ ពោះ ភរ ភេ មេ យួរ យំ រៃ រាំ លី លើ វះ

គគីរ សាគរ ឃោរឃៅ គឃៀរ ជំងឺ ឈូងរ ញញួរ គោញី ណាមរា

ដំបៅងា ទទា ធានា ពុះពារ យោធា វេលា នាវា រទេះ រលំ ទីលំនៅ

គោញីតាឃុំឈឺ ។

ពូទីចុះពីលើនាវា ។

សេះចៅងីជាសេះដំបៅងា ។

តាឌីដើរសំដៅសាលាឃុំគគីរ ។



តាឌីដើរសំដៅសាលាឃុំគគីរ ។



ពូទីចុះពីលើនាវា ។



www.elibraryofcambodia.org

មេរៀនទី ៤

# រំឭក ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉

ង៉ា ញ៉ុាំ ប៊ី ប៉ះ ម៉ែ ម៉ុាំ ម៉ៅ យ៉ា យ៉ុាំ វ៉ា រ៉ែ វ៉ វ៉ៃ វ៉ែន

អាយ៉ៃ ឆៃយ៉ុាំ រយ៉ា ចំប៊ី មួម៉ៅ រ៉ុាំរ៉ៃ រ៉ែរ៉

ញ៉េះញ៉ោះ រយ៉ៃ ហោប៉ៅ រណារ៉ វ៉ែនតា

តាម៉ឺលីចាប៊ី ។

បូណាឈឺរ៉ុាំរ៉ៃ ។

ពូម៉ៅពូកែញ៉េះញ៉ោះ ។



បូណា ឈឺរ៉ុាំរ៉ៃ ។

## លំហាត់

ចូរសរសេរអក្សរផ្ទង់អំពីព្យញ្ជនៈ "ប" ។



www.elibraryofcambodia.org

# មេរៀនទី ៥ រំឭក ប៊ ស៊ ហ៊ អ៊

ប៊ ស៊ុំ ហ៊ូ ហ៊ោ អ៊ូ

សាប៊ូ ប៊ីដុង កៅស៊ូ ទ្រអ៊ូ ប៉ាហ៊ី

តៅហ៊ូ រអ៊ូ ហ៊ីហា អ៊ូអរ ភាស៊ី

ថៅស៊ូទះដៃហ៊ោ ។

អាវ៉ាញ៉ាំតៅហ៊ូ ។

តាហ៊ុលីកៅស៊ូ ។

ពូប៊ីថា ទីនេះអ៊ូអរ ។

អ៊ំៗមកាញឹកចៀរជ័រកៅស៊ូ ។



ទ្រអ៊ូ



អ៊ំៗមកាញឹកចៀរជ័រកៅស៊ូ ។



www.elibraryofcambodia.org

មេរៀនទី
៦

# រំឭកពាក្យប្រកបនឹង

## ក ខ គ ឃ ច ជ ត ថ ទ ព ប ស

កាច់ ទឹក ដេក មុខ រូប មេឃ នាច សាច់ ខូច ពូជ ជូត ប៉ោត ឆើត រត់ គូថ បាទ បិទ សេព ទាប ហើប គប់ ចាប់ រៀប លើស

អំណាច ទឹកកក ជដែក រោគា មេឃា នាគរាជ ងងឹត គំនិត សំប៉ែត កាំបិត របើក ជំនួស កំពីស សុភាព ឡិកឡក់

ចៅជុំផឹកទឹកកក ។

តាភាពជូតប៉ី ។

បងអ៊ុតដុតពោតហូប ។

មីងប៉ានរើសយកទៀបធំៗទៅទុកហូប ។



បងអ៊ុតដុតពោតហូប ។



តាភាពជូតប៉ី ។



www.elibraryofcambodia.org

# មេរៀនទី ៧ រំឭកពាក្យប្រកបនឹង

## ន ណ ង ញ ម យ ល វ

បាន ហ៊ាន កាន់ គុណ កង់ កោង រឹង ប៊ឹង ដូង ចេញ វេញ

ចាញ់ សូម រោម ហើយ វាយ ចាយ មើល ពេល កែវ

រលួយ ជំនួយ អំបិល រដូវ រំដួល សាវម៉ាវ រសៀល ងងឹត

ចំនួន ចំណេញ ននោង រុងរឿង ចំណាង ផាងដូង ឡិកឡក់

មីងពេញទិញននោង ។

ពូពយទិញភួយមួយ ។

កុមារជិះទោងនៅសាលារៀន ។

ពេលទំនេរ បងកែវទៅរៀនហែលទឹក ។



កុមារជិះទោងនៅសាលារៀន ។



www.elibraryofcambodia.org

មេរៀនទី ៨

# រំឭកស្រៈពេញតួ

## អ អា ឥ ឦ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ

អគារ អាហារ ឥសី ឧកញ៉ា ឪទីន

ឪពុក ឫស្សី រឭក ឱសថ ឰដ៏

ឪពុកឯងរស់នៅឯណា ?

ពូឱមដកក្រឡឹឈូកនៅឯបឹង ។

ឥឡូវនេះ ជំនោរបក់ពីទិសឦសាន ។



ពូឱមដកក្រឡឹឈូកនៅឯបឹង ។

## លំហាត់

ចូរសរសេរអក្សរផ្ដង់អំពីស្រៈពេញតួ “ឥ” ។



www.elibraryofcambodia.org

មេរៀនទី ៩

# ព្យញ្ជនៈផ្ញើជើង

## ខ្ជ ខ្ទ ខ្ព ឆ្ត ឆ្គ ឆ្ព

ខ្ជាយ ខ្ជាក់ ខ្ជិល ខ្ទះ ខ្ទម ខ្ទឹង ខ្ទឹម ខ្ពស់ ខ្ពើម ឆ្តោ ឆ្គង ឆ្ពិន ឆ្ពោះ

ខ្ជីខ្ជា ខ្ជាប់ខ្ជួន ខ្ទេចខ្ទី ឆ្គាំឆ្គង ខ្ពង់ខ្ពស់ ខ្ពង់រាប

សុភានិយាយមិនដែលឆ្គាំឆ្គង ។

ពូនួនដាំខ្ទឹមលើទួលខ្ពស់ ។

សុភីខំរៀនយ៉ាងខ្ជាប់ខ្ជួន ។

ត្រីឆ្ពិនហែលឆ្លេឆ្លា ពេលឃើញត្រីឆ្តោ ។



ខ្ទម



ត្រីឆ្ពិន

## លំហាត់

ចូរសរសេរអក្សរផ្ទង់អំពីព្យញ្ជនៈ “ខ” ។



www.elibraryofcambodia.org

មេរៀនទី
១០

# ព្យញ្ជនៈផ្ញើជើង

## ត្ន ត្ល ត្អ ថ្ក ថ្គ ថ្ន ថ្ព ថ្ម ថ្ល

ត្នោត ត្លុក ត្លុម ត្អូញ ត្អើក ថ្កូវ ថ្គាម ថ្នាំ ថ្នាល ថ្ពក់ ថ្ពាល់ ថ្មី ថ្លា ថ្លៃ

ដើមត្នោត ចាក់ត្លុក ត្អូញត្អែរ ថ្គាមខ្លា ថ្នាក់ថ្នម ថ្ពាល់ខួច ថ្លៃថ្លា

មីងសនថ្ពក់ផ្លែថ្កូវ ។
មុខសុខាមានរាងថ្គាមខ្លា ។
ក្មេងៗលោតចាក់ត្លុកក្បែរដើមត្នោត ។
ពូសឿនផឹកទឹកត្នោតជូររួចត្អូញថាឈឺពោះ ។



មុខសុខាមានរាងថ្គាមខ្លា ។



មីងសនថ្ពក់ផ្លែថ្កូវ ។



www.elibraryofcambodia.org

មេរៀនទី ១១

# ព្យញ្ជនៈផ្ញើជើង

## ធ្យ ធ្ល ធ្វ ផ្ក ផ្គ ផ្ដ ផ្ទ

ធ្យូង ធ្លា ធ្លាក់ ធ្លុះ ធ្វើ ធ្វេស ផ្កា ផ្កាយ ផ្គរ ផ្គាក់ ផ្គុំ ផ្ដិត ផ្ទី ផ្ទុះ

ទីធ្លា ធ្លុះធ្លាយ ធ្យូងថ្ម ផ្គូផ្គង ផ្គត់ផ្គង់ ផ្ដិតផ្ដង់ ផ្ទៀងផ្ទាត់ ផ្ទីថ្ម

បាវធ្យូងធ្លុះធ្លាយ ។

ឪពុកខ្ញុំខំរកប្រាក់ផ្គត់ផ្គង់គ្រួសារ ។

ផ្គរលាន់គ្រឹមៗផ្ដួនគ្នាសូរដូចគ្រាប់ផ្ទុះ ។

ក្មេងខ្លះធ្វើកិច្ចការនៅក្រោមដើមឈើក្នុងទីធ្លា ។



ផ្គាក់



ក្មេងខ្លះធ្វើកិច្ចការនៅក្រោមដើមឈើក្នុងទីធ្លា ។



www.elibraryofcambodia.org

មេរៀនទី ១២

# ព្យញ្ជនៈផ្ញើជើង

ផ្ង ផ្ញ ផ្ត ផ្ទ ផ្ន ផ្យ ផ្អ

ផ្ទារ ផ្ទូត ផ្ញើ ផ្ញៀវ ផ្ដើម ផ្ដាំ ផ្ទិល ផ្ទុក ផ្ទូរ

ផ្លិត ផ្លែ ផ្សាយ ផ្សារ ផ្សិត ផ្អាប់ ផ្អូម ផ្អែម

ផ្ដាំផ្ញើ ផ្លែផ្ដាំ ផ្ទុកខ្សាច់ ផ្លេកផ្លោះ ផ្សះផ្សា ផ្អៀងផ្អង

តាផ្លួយបេះផ្លែផ្ញៀវផ្ញើមកផ្ទះ ។

ចៅប៉ុនដើរផ្អៀងផ្អងក្បែរផ្ទុកខ្សាច់ ។

កុំផ្អាប់អាហារ នាំឱ្យជូរផ្អូម ។



ផ្សិត



ផ្ញៀវ

## លំហាត់

ចូរសរសេរអក្សរផ្គុំអំពីព្យញ្ជនៈ "ផ" ។



www.elibraryofcambodia.org

មេរៀនទី ១៣

# ព្យញ្ជនៈផ្ញើជើង

## ព្ន ព្យ ព្រ ភ្ជ ភ្ញ ភ្ន ភ្ល

ព្នង ព្នៅ ព្យួរ ព្យុះ ព្រឹក ព្រៃ ព្រួន ភ្ជួរ ភ្ជុំ
ភ្ញាក់ ភ្ញៀវ ភ្នែក ភ្នំ ភ្លាត់ ភ្លើង ភ្លៅ

ព្រៃព្រេច ព្យាយាម ភ្នំភ្លើង ភ្ជុំភ្ជួរ ផ្កាភ្ញី ភ្លេចភ្លាំង

មីងពៅភ្លេចពន្លត់ភ្នក់ភ្លើង ។
ការផឹកទឹកឆៅនាំឱ្យកើតព្រូន ។
ពូភុំទៅបេះព្នៅក្នុងព្រៃទាំងព្រឹក ។
អ៊ំឱុកភ្ញាក់ពីព្រលឹមទៅភ្ជួរដីក្បែរជើងភ្នំ ។



ភ្នំភ្លើង



ព្យុះ



www.elibraryofcambodia.org

# មេរៀនទី ១៤ មេរៀនសាឡើងវិញ ព្យញ្ជនៈផ្ញើជើង

ថ្គ ថ្ព ធ្យ ធ្ល ធ្វ ផ្គ ផ្ជ

ថ្គាម ថ្ពក់ ថ្ពាល់ ធ្យូង ធ្លា ធ្លាក់ ធ្វើ ធ្វេស ផ្គាក់ ផ្គាប់ ផ្ជឹម ផ្ជុយ

ថ្គាមខ្លា ថ្ពាល់ខ្ជួច ធ្យូងថ្ម ធ្លុះធ្លាយ ផ្គត់ផ្គង់ ផ្ទៀងផ្ទាត់ ឆ្គាំឆ្គង

ចាក់ត្លុក ត្អូញត្អែរ ទីធ្លា ផ្គូផ្គង ផ្ចិតផ្ចង់ ផ្ជឹផ្ជ

បាវធ្យូងធ្លុះធ្លាយ ។

ផ្ការលាន់គ្រឹមៗផ្ជួនគ្នាដូចគ្រាប់ផ្ទុះ ។

សុភានិយាយមិនដែលឆ្គាំឆ្គង ។

មុខសុខាមានរាងថ្គាមខ្លា ហើយថ្ពាល់ខ្ជួច ។

## លំហាត់

១. ចូរសរសេរពាក្យខាងក្រោមនេះឱ្យបានត្រឹមត្រូវ ។

ក. ឆ្គាំឆង : ..............  ខ. ត្អូញតែ : ..............

២. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| ផ្ជួន | ថ្គាម | ថ្ពាល់ |

ក. ផ្ការលាន់គ្រឹមៗ .......... គ្នាដូចគ្រាប់ផ្ទុះ ។

ខ. មុខសុខាមានរាង ...... ខ្លា ហើយ ...... ខ្ជួច ។



www.elibraryofcambodia.org

មេរៀនទី ១៥

# ព្យញ្ជនៈផ្ញើជើង

## ម្ក ម្ខ ម្ន ម្ឃ ម្ត ម្ដ ម្ន

ម្កាក់ ម្ខាង ម្នាស់ ម្ទុល ម្ជូរ ម្ដាយ ម្ដេច ម្ទុំ ម្ទេស ម្នាក់ ម្នាស់

ម្ដេចម្ដា ម្ទីម្នា ម្នាងសិលា ម្ចាស់ផែនដី

ណារីចូលចិត្តហូបម្ជូរ ។
តាស៊ូខំប្រឹងដាំម្ទេសនិងម្នាស់ ។
ម្ដាយស៊ីថាម្ទីម្នាទៅបេះផ្លែម្កាក់ ។


ម្នាស់


ម្ទេស

### លំហាត់

ចូរសរសេរអក្សរផ្គង់អំពីព្យញ្ជនៈ "ម" ។



www.elibraryofcambodia.org

មេរៀនទី ១៦

# ព្យញ្ជនៈផ្ញើជើង

## ម្យ ម្រ ម្ល ម្ស ម្ហ ម្អ

ម្យ៉ាង ម្រាម ម្រេច ម្រះ ម្លប់ ម្លេះ ម្លូ ម្សាញ់ ម្សិល ម្សៅ ម្ហូប ម្អម

ម្រាមដៃ ម្រះព្រៅ ម្លូព្រៃ ម្សិលមិញ ឆ្នាំម្សាញ់ ម្ហេមម្ហូប ម្អមក្ដាម

ក្មួយខ្ញុំកើតឆ្នាំម្សាញ់ ។
តាឪមដាំម្រះ ម្លូ និងម្រះព្រៅ ។
ត្រីឆ្អិនធ្វើមាត់ម្ហូបៗក្បែរគល់ម្អម ។
ម្សិលមិញម្ដាយខ្ញុំទិញត្បាល់កិនម្សៅ ។



ត្បាល់កិនម្សៅ



ម្រេច



www.elibraryofcambodia.org

មេរៀនទី ១៧

# ព្យញ្ជនៈផ្ញើជើង

## ល្ខ ល្វ ល្ប ល្ព ល្ម ល្ង ល្ហ ល្អ

ល្ខោន ល្វ ល្វាច ល្វង់ ល្បី ល្បែង ល្ពៅ

ល្មុត ល្មម ល្ងា ល្ងីង ល្ហុង ល្ហើយ ល្អី ល្អិត

ល្ងាចេក ល្ងីងល្ងើយ ល្ហល្ហាច ល្អិតល្អន់ ល្ខោនបាសាក់

ទឹកឡើងល្ហល្ហាចលិចដើមល្ហុង ។

ល្ខោនបាសាក់មានឈ្មោះល្បីល្បាញ ។

ពេលល្វាច មីងផានបេះល្ពៅ ល្មុត និងល្ហុងដាក់ក្នុងល្អី ។



ល្ខោនបាសាក់



ល្ពៅ

## លំហាត់

ចូរសរសេរអក្សរផ្ចង់អំពីព្យញ្ជនៈ "ល" ។



www.elibraryofcambodia.org

មេរៀនទី ១៨

# ព្យញ្ជនៈផ្ញើជើង

## ស្ក ស្គ ស្វ ស្ញ ស្ត

ស្ករ ស្ការ ស្គរ ស្គម ស្វាប ស្វៀម ស្ញើប ស្វែង ស្តាយ ស្តាំ

ស្ករស ស្គមស្គាំង ស្គុសស្គាយ ស្វាត់ស្វៀម ស្ងប់ស្ងែង សោកស្តាយ

ផ្ការីកស្គុសស្គាយនៅក្នុងសួនច្បារ ។
ប្រាសាទព្រះវិហារគួរឱ្យស្ញប់ស្ញែង ។
ពូស្តើងនៅស្ងៀមស្ងាត់ ព្រោះស្តាយស្គរ ។
មីងសានមានរាងស្គម តែចូលចិត្តហូបស្ករ ។



ប្រាសាទព្រះវិហារ



ស្គរ



www.elibraryofcambodia.org

មេរៀនទី ១៩

# ព្យញ្ជនៈផ្ញើជើង

## ស្ក ស្ច ស្ន ស្ប ស្ត

ស្ថិត ស្ទឹង ស្ងួច ស្ងួង ស្ងប់ ស្នែង ស្និត ស្បែក ស្បៃ ស្ពាន ស្តែ

ស្ថិតស្ថេរ ស្ងួចត្រី ស្នែងខ្ទឹង ស្និតចេក
ស្បែកជើង ស្បៃរឿង ស្តែក្តោប ស្ពានអាកាស

រាជធានីភ្នំពេញមានស្ពានអាកាស ។
ម្សិលមិញ ខ្ញុំស្ទុះស្ទាទៅស្ទូចត្រីឯស្ទឹងក្បែរស្ពានថ្ម ។
នារីកាន់ស្បៃ ពាក់ស្បែកជើង ទៅបេះស្បៃរឿង និងដកស្តែ ។



រាជធានីភ្នំពេញមានស្ពានអាកាស ។



ស្ទូង

### លំហាត់

ចូរសរសេរអក្សរផ្ទង់អំពីព្យញ្ជនៈ “ស” ។



www.elibraryofcambodia.org

មេរៀនទី
២០

# ព្យញ្ជនៈផ្ញើជើង

## ស្ម ស្រ ស្ល ស្វ ស្អ

ស្មា ស្មៅ ស្មោះ ស្រក់ ស្រែ ស្រេក ស្លាប ស្លូត

ស្លេក ស្វា ស្វាយ ស្វិត ស្អាត ស្អុយ ស្អែក

ស្មោះត្រង់ ស្រុកស្រែ ស្រេកឃ្លាន ស្លេកស្លាំង ស្លូតបូត

ស្វាហាប់ ស្វិតស្វាញ ស្អាតស្អំ ស្អុះស្អាប់

ស្វាស៊ីផ្លែស្វាយទុំ ។

ថ្ងៃនេះ មេឃក្តៅស្អុះស្អាប់ ។

អ៊ំស្មាញបោចស្មៅដាក់ក្នុងស្បោង ។

ថ្ងៃស្អែក ពូស្វិតទៅច្រូតស្រូវនៅឯស្រែ ។



ស្វា



ស្វាយ



www.elibraryofcambodia.org

# មេរៀនទី ២១ មេរៀនសាឡើងវិញព្យញ្ជនៈផ្ញើជើង

## ម្ស ម្ហ ម្អ ល្ង ល្ព ល្វ ស្គ ស្ញ ស្ន ស្ព

ម្សិល ម្សៅ ម្ហូប ម្អម ល្ងង់ ល្ងាច ល្ពៅ ល្មុត ល្មម ល្វីង ល្វា

ស្គរ ស្គម ស្ញើប ស្ញែង ស្នឹង ស្នូច ស្ពាន ស្ពៃ

ឆ្នាំម្សាញ់ ម្ហេបម្ហូប ម្អមក្តាម ល្ងង់ខ្លៅ ផ្លែល្ពៅ ល្មុតថ្ម ល្វាចេក

ស្គមស្គាំង ស្ញប់ស្ញែង ស្នុះស្នា ស្ពានអាកាស

ត្រីឆ្អិនធ្វើមាត់ម្ហបៗក្បែរគល់ម្អម ។

ប្រាសាទព្រះវិហារគួរឱ្យស្ញប់ស្ញែង ។

រាជធានីភ្នំពេញមានស្ពានអាកាស ។

ពេលល្ងាច សុខាដងទឹកស្រោចល្ពៅ និងកូនល្មុត ។

## លំហាត់

ចូរគូសសញ្ញាព្រួញភ្ជាប់ពាក្យទៅនឹងរូបភាព រួចអាន ។

ក្តាម

ល្ពៅ

ល្មុត

ស្ពៃក្តោប











www.elibraryofcambodia.org

មេរៀនទី ២២

# ព្យាង្គតម្រួត

## ង្ក ង្ខ ង្គ ង្ឃ

បង្កាត់ បង្កង កង្កែប អង្ករ អង្កាម ដង្ខៅ បង្ខិត បង្ខំ បង្ខូច

បង្គន់ គង្គា បង្គី គីង្គក់ អង្គុយ សង្ឃឹម មង្ឃុត សង្ឃរា

បង្កបង្កើត បង្ខិតបង្ខំ

ពូគីបង្ខំកូនឱ្យហូបមង្ឃុត ។

មីងយ៉ានកើបអង្ករ និងអង្កាម ។

ពូភោគចាប់គីង្គក់ និងកង្កែបដាក់ក្នុងបង្គី ។



កង្កែប



មង្ឃុត

## លំហាត់

ចូរសរសេរអក្សរផ្ចង់អំពីព្យញ្ជនៈ "ង" ។



www.elibraryofcambodia.org

មេរៀនទី
២៣

# ព្យាង្គតម្រួត

## ង្រ ង្វ ង្យ ង្ហ ង្អ

ពង្រីក បង្រួម អង្រួន ចង្វា ចង្វាក់ បង្វិល អង្វរ បង្វែរ
សង្យ័យ កង្ហារ បង្ហាញ សង្ហា ចង្អេរ ចង្អុល បង្អួច

ត្រីចង្វា ជ្រោយចង្វា ចង្អុលដៃ បង្រួបបង្រួម

សុខាអង្វរម្ដាយសុំទិញកង្ហារ ។
តាគង់ត្បាញចង្អេរក្រោមដើមពង្រ ។
មីងព្រឹមបង្ហាញអំពីរបៀបកាត់ត្រីចង្វា ។



កង្ហារ



ចង្អេរ



www.elibraryofcambodia.org

មេរៀនទី
២៤

# ព្យាង្គតម្រួត

## ញ្ច ញ្ឆ ញ្ជ ញ្ឈ ញ្ញ

កញ្ចែ ចិញ្ចឹម បញ្ចុក កញ្ឆែត បញ្ឆិត បញ្ឆោត កញ្ជើ អញ្ជើញ
ជញ្ជាត់ ជញ្ជាំង បញ្ឈរ បញ្ឈប់ បញ្ឈឺ កញ្ញា បញ្ញា សញ្ញា

កញ្ចាញ់ច្រាស នំបញ្ចុក បញ្ឆិតបញ្ឆៀង ភ្លើងសញ្ញា ជញ្ជាំងថ្ម ខែកញ្ញា

បញ្ញាបេះកញ្ឆែតដាក់កញ្ជើ ។
យើងគោរពភ្លើងសញ្ញាចរាចរណ៍ ។
កញ្ញាជញ្ជាត់បានត្រីកញ្ចាញ់ច្រាសដាក់ក្នុងកញ្ជើ ។


នំបញ្ចុក


សញ្ញាចរាចរណ៍



www.elibraryofcambodia.org

មេរៀនទី ២៥

# ព្យាង្គតម្រួត

## ណ្ដ ណ្ឌ ណ្ណ

កណ្ដាល កណ្ដាប់ បណ្ដូល កណ្ដៀត កណ្ដោល
អណ្ដើក សណ្ឋាន សណ្ឋិត បណ្ណាល័យ

កណ្ដៀតក្អម កណ្ដោចកណ្ដែង ឯកសណ្ឋាន សណ្ឋាគារ

កងទ័ពស្លៀកពាក់ឯកសណ្ឋាន ។
បណ្ដូលកំពុងអានសៀវភៅក្នុងបណ្ណាល័យ ។
តាជុំអង្គុយកណ្ដោចកណ្ដែងក្រោមដើមកណ្ដោល ។



បណ្ណាល័យ



សណ្ឋាគារ



www.elibraryofcambodia.org

# មេរៀនទី ២៦ មេរៀនសាឡើងវិញព្យាង្គតម្រួត

ង្ក ង្គ ង្រ ង្វ ង្ហ ង្ខ ញ្ច ញ្ឈ ញ្ជ ញ្ញ ណ្ត

បង្កង កង្កែប គីង្គក់ អង្គុយ ពង្រីក បង្រួម ចង្វា បង្វិល កង្ហារ បង្ហាញ

ចង្អេរ បង្អួច កញ្ចែ ចិញ្ចឹម កញ្ឆែត បញ្ឈិត ជញ្ជាត់ អញ្ជើញ បញ្ឈប់

កញ្ញា សញ្ញា កណ្តាប់ កណ្តៀត កណ្តោល អណ្តើក

បង្កបង្កើត បង្រួបបង្រួម ត្រីចង្វា ចង្អុលដៃ កញ្ចាញ់ច្រាស

បញ្ឈិតបញ្ឈៀង ភ្លើងសញ្ញា កណ្តោចកណ្តែង

ត្រីចង្វាហែលបង្វិលខ្លួនក្នុងគង្គា ។

យើងគោរពភ្លើងសញ្ញាចរាចរណ៍ ។

កញ្ញាជញ្ជាត់បានត្រីកញ្ចាញ់ច្រាសដាក់ក្នុងកញ្ជើ ។

តាជុំអង្គុយកណ្តោចកណ្តែងក្រោមដើមកណ្តោល ។

## លំហាត់

ចូរសរសេរពាក្យខាងក្រោមឱ្យបានត្រឹមត្រូវ ។

១. ....ង្កែប ៖ ..................

២. ចិញ្ច.... ៖ ..................

៣. ....ញ្ញ.... ៖ ..................



www.elibraryofcambodia.org

មេរៀនទី ២៧

# ព្យាង្គតម្រួត

## ន្ត ន្ថ ន្ទ ន្ធ ន្ល ន្ស

កន្តិប បន្ត បន្តិច កន្ថោរ បន្ថយ បន្ថែម កន្ទុយ បន្ទាត់ អន្ទង់ កន្ធាយ

បន្ធូរ សន្ធោ កន្លង់ ទន្លេ បន្លែ កន្សែង ទន្សាយ សន្សើម

បន្តិចបន្តួច ឋានន្តរ បន្ថែមបន្ថយ កន្ទុយអន្ទង់

សន្ធោសន្ធៅ បន្លែបង្ការ កន្ទុំរុយ

គេដាំបន្លែនៅតាមមាត់ទន្លេ ។

ទន្សាយផឹកទឹកសន្សើម ។

មីងខុមលក់កន្ទក់យកលុយទិញអន្ទង់ ។



អន្ទង់



ទន្សាយ

## លំហាត់

ចូរសរសេរអក្សរផ្ទង់អំពីព្យញ្ជនៈ “ន” ។



www.elibraryofcambodia.org

មេរៀនទី ២៨

# ព្យាង្គតម្រួត

## ម្ក ម្ វ ម្ង ម្ប ម្ព ម្ភ ម្ព

តម្កល់ ចម្ការ ចម្ងាយ ចម្ងល់ កម្ងាត់ កម្ងី សម្បក សម្បុរ សម្បូរ
សម្ពុក សម្បត្តិ សម្ពស្ស កម្សាន្ត កម្សត់ កម្ពុត ចម្អិន សម្អាត

ចម្ការល្ហុត ចម្ងាយផ្លូវ សម្បកចេក កម្ពាត់កម្ពាយ

សម្ពស្សទៅកម្សាន្តឯចម្ការ ។
នារីសម្អាតបន្ទប់រៀន ។
ប្រទេសយើងសម្បូរសម្បត្តិធម្មជាតិ ។


នារីសម្អាតបន្ទប់រៀន ។


ចម្ការ



www.elibraryofcambodia.org

មេរៀនទី ២៩

# ព្យាង្គតម្រួត

## ម្ត ម្ភ ម្ម ម្រ ម្ល

កម្ពុជា ជម្ពូ គម្ពីរ សម្ពាយ សម្ភារៈ សម្ភាស កម្មករ កម្រើក សម្រាក បម្រើ គម្រប កម្លាំង សម្ល សម្លាញ់ សម្លក់ ចម្លង ចម្លាក់

កម្សត់កម្រ សម្ពោងសម្ពាយ សម្លក់សម្លឹង សម្លកកូរ

ពេលថ្ងៃ កម្មករសម្រាកយកកម្លាំង ។

ពូឈុំយួរសម្ភារៈសម្ពោងសម្ពាយ ។

កែវ និងកន ជាសម្លាញ់កម្សត់កម្រនឹងគ្នា ។


ជម្ពូ


សម្លកកូរ

លំហាត់

ចូរសរសេរអក្សរផ្ចង់អំពីព្យញ្ជនៈ "ជ" ។



www.elibraryofcambodia.org

មេរៀនទី
៣០

# ព្យាង្គតម្រួត

## ង្ក្រ ង្គ្រ ញ្ច្រ ន្ត្រ ន្ទ្រ

ចង្ក្រង់ អង្ក្រង បង្ក្រាប សង្គ្រាម បង្គ្រប់ អង្គ្រង កញ្ច្រែង
បញ្ច្រក បញ្ច្រាស កញ្ជ្រឹល កញ្ជ្រូក កញ្ជ្រោង បញ្ជ្រាប
កន្ត្រប់ តន្ត្រី កន្ត្រៃ មន្ត្រី ឥន្ទ្រី ទន្ទ្រាន ចន្ទ្រា

ត្រីកន្ត្រប់ ទន្ទ្រានខេត្ត តន្ត្រីសម័យ ត្រីកន្ត្រងប្រេង

គេយកកុមារទៅចាក់ថ្នាំបង្ការជំងឺកញ្ជ្រឹល ។
ចន្ទ្រាកាប់ចិញ្ច្រាំដើមទន្ទ្រានខេត្តទុកធ្វើជី ។
កញ្ជ្រោងសង្គ្រប់ទន្សាយនៅក្រោមដើមអង្គ្រង ។
ត្រីកន្ត្រប់ហែលដេញត្រីកន្ត្រងប្រេងនិងត្រីកញ្ជ្រូក ។



កញ្ច្រែង



កញ្ជ្រោង



www.elibraryofcambodia.org

# មេរៀនទី ៣១ មេរៀនសាឡើងវិញព្យាង្គតម្រួត

## ន្ត ន្ថ ន្ទ ន្ធ ន្ល ន្ស ង្ក្រ ង្គ្រ ញ្ច្រ ញ្ជ្រ ន្ត្រ ន្ទ្រ

បន្ត បន្តិច កន្តោរ បន្ថែម អន្ទង់ បន្ធូរ

សន្លោ កន្លង់ បន្លែ កន្សែង ទន្សាយ

អង្ក្រង សង្គ្រាម បង្ក្រប់ កញ្ច្រែង កន្ត្រប់ មន្ត្រី ឥន្ទ្រី

ត្រីកន្ត្រប់ កន្ទុំរុយ ទន្ទ្រានខេត្ត តន្ត្រីសម័យ

បន្តិចបន្តួច បន្ថែមបន្ថយ កន្ទុយអន្ទង់ សន្លោសន្លៅ បន្លែបង្ការ

ទន្សាយផឹកទឹកសន្សើម ។

គេយកកុមារទៅចាក់ថ្នាំបង្ការជំងឺកញ្ជ្រិល ។

ត្រីកន្ត្រប់ហែលដេញត្រីកន្ត្រង់ប្រេងនិងត្រីកញ្ច្រូក ។

## លំហាត់

ក. ចូរសរសេរពាក្យពីក្រោមរូបភាពឱ្យបានត្រឹមត្រូវ ។

   

............... ............... ............... ...............

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោម ។

| | |
|---|---|
| កញ្ជ្រិល | កុមារ |

គេយក ............... ទៅចាក់ថ្នាំបង្ការជំងឺ ............... ។



www.elibraryofcambodia.org

# មេរៀនទី ៣២ បវេសនកាល

## អំណាន



ថ្ងៃនេះជាថ្ងៃចូលរៀនដំបូង ។

ព្រឹកនេះ ម្ដាយសុភីដាស់កូនពីព្រលឹម ។ គាត់ប្រាប់សុភីឱ្យរៀបចំខ្លួនទៅសាលារៀន ។ សុភីភ្ញាក់ពីដំណេក រួចងើបចេញពីគ្រែ ។ នាងនិយាយ ៖ អូ! ថ្ងៃនេះ ជាថ្ងៃបវេសនកាលផង ។ តើម៉ាក់អញ្ជើញទៅជាមួយកូនដែរឬទេ ? ទេកូន! ឆ្នាំនេះ កូនធំហើយ ។ កូនទៅជាមួយប្អូន ហើយមើលប្អូនផងណ៎ា! ។ សុភីនិងប្អូនទៅងូតទឹក រួចស្លៀកពាក់ រៀបចំកាតាប ទើបសំពះលាម្ដាយឪពុកទៅសាលារៀន ។

ពួកគេទៅសាលារៀនទាំងពីរនាក់ ដោយទឹកមុខរីករាយ ។



www.elibraryofcambodia.org

## ការរៀនពាក្យ

ក. អំណានពាក្យ

អញ្ជើញ អានថា អាញ់-ជើញ

បវេសនកាល អានថា ប៉ះ-វេ-សៈ-ន់ៈ-កាល

ខ. ពន្យល់ពាក្យ

បវេសនកាល : ថ្ងៃចូលរៀនដំបូងនៅដើមឆ្នាំសិក្សា ។

គ. ពាក្យន័យដូចនឹងពាក្យ "ម៉ាក់"

ម៉ាក់ ម៉ែ ម្ដាយ មាតា

ឃ. ពាក្យផ្ទុយ

បវេសនកាល ≠ វិស្សមកាល រីករាយ ≠ កើតទុក្ខ

## សំណួរ

១. តើនៅថ្ងៃបវេសនកាល សុភីទៅរៀនជាមួយនរណា ?

២. តើម្ដាយសុភីផ្ដាំសុភីឱ្យធ្វើអ្វី ?

៣. មុននឹងទៅសាលារៀន តើសុភីនិងប្អូនធ្វើអ្វីខ្លះ ?

## លំហាត់

ក. ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្ទួំនិងប្រកបឱ្យបានត្រឹមត្រូវ ។

ព្រលឹម សាលារៀន បវេសនកាល អញ្ជើញ ស្លៀកពាក់ ម្ដាយ ឪពុក

ខ. ចូរអានល្បះខាងក្រោមរួចប្រាប់ឈ្មោះមនុស្សនិងវត្ថុឱ្យបានត្រឹមត្រូវ ។

សុភីនិងប្អូន ទៅងូតទឹក រួចស្លៀកពាក់ រៀបចំកាតាប ទើបសំពះលាម្ដាយឪពុកទៅសាលារៀន ។



www.elibraryofcambodia.org

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យខាងក្រោម ។

| | | | | |
|---|---|---|---|---|
| ព្រលឹម | សាលារៀន | បវេសនកាល | អញ្ជើញ | គ្រែ |
| ប្រញាប់ | ស្លៀកពាក់ | ម្ដាយ | សំពះ | ឪពុក |

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោម ។

ធំៗ | ចម្រុះពណ៌ | ពណ៌ក្រហម

១. សាលារៀនខ្ញុំសង់អំពីឈើប្រក់ក្បឿង ................ ។

២. នៅជុំវិញសាលារៀន មានដើមឈើ ............ជាច្រើន ។

៣. នៅក្នុងសួនច្បារមានផ្កា ............................ ។

បក់រវិចៗ | ស | ខៀវ | ក្រហម | ទង់ជាតិ | ប្រាសាទ

១. នៅចំកណ្ដាលទីធ្លាសាលារៀន មានដង ............មួយខ្ពស់ ។

២. ទង់ជាតិ ............................នៅពេលត្រូវខ្យល់ ។

៣. ទង់ជាតិមានពណ៌ ........និង .......ហើយមានរូប ....ពណ៌ ....... ។

ធំ | ញញឹម | ខ្ពស់ | ស្លូតបូត

១. លោកគ្រូខ្ញុំឈ្មោះសារិន ។ គាត់មានមាឌ ......ហើយ ........ ។

២. លោកគ្រូមានទឹកមុខ ..........................ជានិច្ច ។

៣. គាត់ជាមនុស្ស ..............ហើយចិត្តល្អណាស់ ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ “សាលា”



www.elibraryofcambodia.org

# មេរៀនទី ៣៣ ពេលចេញលេង

## អំណាន



ម៉ឺង ! ម៉ឺង ! ម៉ឺង ជាស្គរជួងចេញលេង ។ សិស្សទាំងឡាយចេញពីបន្ទប់រៀនប្រកបដោយទឹកមុខរីករាយ ។

នៅក្នុងទីធ្លាដ៏ធំទូលាយ សិស្សានុសិស្សនាំគ្នាលេងល្បែងជាក្រុមៗ ។ ពួកគេលេងឃ្លី លេងមីក លោតអន្ទាក់ លេងត្រែះ លេងរែក លេងបាយខុំ លេងបាល់និងទាត់សី ។ សិស្សខ្លះ អង្គុយជជែកគ្នាក្រោមដើមឈើដែលមានម្លប់ត្រឈឹងត្រឈៃ ។ សិស្សខ្លះទៀត រត់ប្រឡែងគ្នាលេងយ៉ាងសប្បាយ ។ នៅក្នុងបណ្ណាល័យ មានសិស្សជាច្រើនកំពុងអានសៀវភៅ ។

កុមារា កុមារីទាំងឡាយ គួរលេងល្បែងណាដែលមានប្រយោជន៍និងមិនបណ្តាលឱ្យមានគ្រោះថ្នាក់ ។



www.elibraryofcambodia.org

## ការរៀនពាក្យ

ក. អំណានពាក្យ

សិស្សានុសិស្ស អានថា សឺស-សា-នុ-សឺស

ត្រែះ អានថា ត្រែស

បណ្ណាល័យ អានថា ប៊ុន-ណា-ឡៃ

ខ. ពន្យល់ពាក្យ

សិស្សានុសិស្ស : សិស្សទាំងឡាយ សិស្សតូចនិងសិស្សធំ ។

បណ្ណាល័យ : កន្លែងសម្រាប់តម្កល់ទុកសៀវភៅ គម្ពីរ ក្បួនច្បាប់ ។

ត្រែះ : ឈ្មោះល្បែងលេងដោយប្រើខ្នាច់ ចង្កឹះ ឬគ្រាប់អ្វីៗ ។

កុមារាកុមារី : ក្មេងប្រុសស្រី ។

គ. ពាក្យផ្ទុយ

ទូលាយ ≠ ចង្អៀត សប្បាយ ≠ កើតទុក្ខ

## សំណួរ

១. តើសិស្សមានទឹកមុខដូចម្ដេច នៅពេលចេញលេង ?

២. តើពួកគេលេងអ្វីខ្លះ នៅពេលចេញលេង ?

៣. តើនៅក្នុងបណ្ណាល័យ សិស្សកំពុងធ្វើអ្វី ?

៤. តើសិស្សគួរលេងល្បែងដូចម្ដេច ?

## លំហាត់

ក. ចូរអានអត្ថបទឡើងវិញដោយបណ្ដាក់គ្នា ។

ខ. ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្សំនិងប្រកបឱ្យបានត្រឹមត្រូវ ។

បណ្ណាល័យ ត្រែះ សិស្សានុសិស្ស កុមារាកុមារី អង្គុយ ប្រយោជន៍ ស្គរ ម្លប់



www.elibraryofcambodia.org

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យខាងក្រោម ។

បណ្ណាល័យ ក្រុម ម្លប់ កុមារា កុមារី ស្ទួរ សិស្សានុសិស្ស ត្រែះ អង្គុយ

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញល្បះខាងក្រោម ។

គ្រោះថ្នាក់ | រីករាយ | បណ្ណាល័យ | ប្រយោជន៍ | សិស្សានុសិស្ស

១. សិស្សទាំងឡាយ ចេញពីបន្ទប់រៀនប្រកបដោយទឹកមុខ .......... ។

២. នៅក្នុងទីធ្លាដ៏ធំទូលាយ ............ នាំគ្នាលេងល្បែងជាក្រុមៗ ។

៣. នៅក្នុង .................. មានសិស្សជាច្រើនកំពុងអានសៀវភៅ ។

៤. សិស្សានុសិស្សទាំងឡាយ គួរលេងល្បែងណាដែលមាន ........ និង មិនបណ្តាលឱ្យមាន ....... ដល់ខ្លួន ។

គ. ចូរបំពេញល្បះតាមរូបខាងក្រោមឱ្យបានត្រឹមត្រូវ ។



១. កុមារីកំពុង ........... ។



២. កុមារាកំពុង ........... ។



www.elibraryofcambodia.org

# មេរៀនទី ៣៤ ឆ្មាចង់ទៅរៀន

## មេសូត្រ



(បទកាកគតិ)

ពេលព្រឹកព្រលឹម
នារីញញឹម
រៀបចំកាយា
ស្លៀកពាក់ស្អាតបាត
ស្រស់ស្រូបអាហារ
នាងលាម៉ាក់ប៉ា
ទៅសាលារៀន ។

ឆ្មាឃើញនារី
លើកជើងមុខពីរ
ធ្វើឫកអៀនប្រៀន
ចង់សុំទៅដែរ
តែឆ្មាមិនហ៊ាន
រវល់តែអៀន
នាងទៅរៀនបាត់ ។



www.elibraryofcambodia.org

## ការរៀនពាក្យ

ក. អំណានពាក្យ

ឫកពា អានថា រឹក-ពា

កាយា អានថា កាយ-យ៉ា

ខ. ពន្យល់ពាក្យ

ឫកពា : បែបបទ សណ្ដាប់ធ្នាប់ ។

កាយា : រូប ខ្លួន ។

គ. ពាក្យន័យដូចនឹងពាក្យ "ស្រស់ស្រូប"

ស្រស់ស្រូប ទទួលទាន ហូប ពិសា ស៊ី ឆី ឆាន់ សោយ បរិភោគ

## សំណួរ

១. តើពេលព្រឹកព្រលឹមនរណារៀបចំខ្លួនទៅសាលារៀន ?

២. តើនារីធ្វើអ្វីខ្លះ មុនទៅសាលារៀន ?

៣. តើនរណាចង់ទៅរៀន ជាមួយនារី ?

៤. តើឆ្មាបានទៅរៀន ជាមួយនារីដែរឬទេ ? ព្រោះអ្វី ?

## លំហាត់

ក. ចូរអានពាក្យខាងក្រោម ដោយមិនបាច់ផ្ទាំនិងប្រកបឱ្យបានត្រឹមត្រូវ ។

ព្រលឹម ស្លៀកពាក់ កាយា អាហារ ស្អាតបាត ស្រស់ស្រូប
ហ៊ាន អៀនប្រៀន

ខ. ចូរសូត្រមេសូត្រខាងលើតាមគ្រូរបស់អ្នកឱ្យបានត្រឹមត្រូវ ។



www.elibraryofcambodia.org

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យខាងក្រោម ។

| | | | | |
|---|---|---|---|---|
| ព្រលឹម | កាយា | អាហារ | ស្អាត | ហ៊ាន |
| ឫក | ពីរ | រវល់ | ស្រស់ស្រូប | អៀនប្រៀន |

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោម ។

អៀនប្រៀន | អាហារ | ព្រលឹម | ញញឹម | ហ៊ាន

ពេលព្រឹក ........... នារី .............. រៀបចំកាយា ស្លៀកពាក់ស្អាតបាត ស្រស់ស្រូប ......... នាងលាម៉ាក់ប៉ា ទៅសាលារៀន ។

ឆ្មាឃើញនារី ចង់សុំទៅដែរ លើកជើងមុខពីរ តែឆ្មាមិន .......... ធ្វើឫក ............ រវល់តែអៀន នាងទៅរៀនបាត់ ។

គ. ចូរមើលរូប រួចបំពេញល្បះខាងក្រោម ដើម្បីពណ៌នាអំពីមនុស្ស វត្ថុ និងទីកន្លែងក្នុងរូបនីមួយៗ ។






១. តុនេះធ្វើអំពី................ ។
២. នៅលើតុមាន............... ។
៣. អ្នកគ្រូខ្ញុំឈ្មោះ ............ ។
៤. ខ្ញុំស្រឡាញ់...........ណាស់ ។
៥. សាលារៀនខ្ញុំឈ្មោះ ......... ។
៦. សាលារៀននេះ ....ហើយស្អាត ។



www.elibraryofcambodia.org

# មេរៀនទី ៣៥ ការណែនាំមិត្តឱ្យស្គាល់គ្នា

## ការនិយាយ

ខាងក្រោមនេះជាការសន្ទនា ណែនាំឱ្យស្គាល់មិត្តនៅពេលជួបគ្នាដំបូង ។




បូណា : សួស្ដីសុភី! នេះគឺតារា ។ គេជាមិត្តខ្ញុំ ។

សុភី : សួស្ដីតារា ! ខ្ញុំរីករាយណាស់ដោយបានស្គាល់មិត្ត !

តារា : សួស្ដីសុភី ! ខ្ញុំក៏រីករាយដូចមិត្តដែរ ។
តើសុភីរៀននៅថ្នាក់ណា ?

សុភី : ខ្ញុំរៀនថ្នាក់ទី ២ "ក" ។ តើឯងសុខសប្បាយឬទេ ?

តារា : អរគុណ ! ខ្ញុំសុខសប្បាយទេ ។



www.elibraryofcambodia.org

## សំណួរ

១. តើបូណាណែនាំនរណាឱ្យស្គាល់នរណា ?

២. តើតារាជាមិត្តរបស់អ្នកណា ?

៣. តើសុភីនិយាយដូចម្ដេចខ្លះទៅកាន់តារា ?

៤. តើសុភីសួរតារាដូចម្ដេច ?

## លំហាត់

ចូរនិយាយបំពេញសម្ដីសន្ទនាតាមរូបភាពខាងក្រោម ដោយប្រើឈ្មោះផ្ទាល់ខ្លួន ។



(ឈ្មោះ ...) ! នេះគឺ ........ ។ គេជាមិត្តរបស់ខ្ញុំ ។

សួស្ដី ..... ! ខ្ញុំរីករាយណាស់ដោយ ...... ។ តើ ..... រៀននៅថ្នាក់ណា ?

ខ្ញុំរៀន ........... ។

ខ្ញុំក៏ ........ ។



www.elibraryofcambodia.org

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យខាងក្រោម ។

| |
|---|
| សួស្តី មិត្ត រីករាយ ឯង ធម្មតា រៀន ស្គាល់ ថ្នាក់ សុខសប្បាយ អរគុណ |

ខ. ចូរអ្នកជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញសម្ភីសន្ទនារវាងអ្នកទាំងបីខាងក្រោម ។

| | | | | |
|---|---|---|---|---|
| ល្អណាស់ | រៀន | លោកអ៊ំ | អរគុណ | ជម្រាបសួរ |

សានបានណែនាំសុភីស្គាល់ឪពុកខ្លួន ។

បូណា : សុភី ! នេះឪពុករបស់ខ្ញុំ ។

សុភី : ............លោកអ៊ំ ។

ឪពុកបូណា : បាទ ! .......ក្មួយ ។ តើក្មួយ............ថ្នាក់ទីប៉ុន្មាន ?

សុភី : ចាស ! ......................ខ្ញុំរៀនថ្នាក់ទី ២ "ក"ជាមួយបូណាដែរ ។ តើលោកអ៊ំសុខសប្បាយឬទេ ?

ឪពុកបូណា : .....................! អ៊ំសុខសប្បាយទេ ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ " រីករាយ " ។



www.elibraryofcambodia.org

មេរៀនទី
៣៦

# សត្វក្រសារ

## អំណាន



មានសត្វក្រសារមួយ ឈរចាំចឹកត្រីនៅមាត់បឹង ។

ពេលនោះ មានត្រីចង្វាមួយបានហែលពីមុខវា ។ ក្រសារគិតថា ត្រីចង្វានេះតូចណាស់ ស៊ីក៏មិនឆ្អែតដែរ រង់ចាំត្រីធំៗ ចឹកស៊ីតែមួយពីរឆ្អែតតែម្តង ។ ត្រីចង្វាក៏ហែលបាត់ទៅ ។ បន្តិចមក មានកូនត្រីក្រាញ់មួយហែលមកទៀត វានៅតែមិនចឹកស៊ី ។ ក្រោយមក ក៏មានកូនត្រីផ្ទក់មួយហែលមកទៀត ក្រសារគិតថា បន្តិចទៀតនឹងបានជួបត្រីធំៗជាងនេះជាមិនខាន ។ ត្រីផ្ទក់ក៏ហែលទៅបាត់ទៀត ។ តាំងពីព្រឹកដល់ព្រលប់ ក្រសាររង់ចាំត្រីធំៗមិនឃើញសោះ ។

ក្រសារវិលរកទ្រនំវិញ ទាំងក្តីស្រេកឃ្លាន ។

## ការរៀនពាក្យ

ក. អំណានពាក្យ

ចង្វា អានថា ចង់-វ៉ា

បន្តិច អានថា បន់-តិច



www.elibraryofcambodia.org

ខ. ពន្យល់ពាក្យ

ចឹក : ខាំដោយចំពុះ ។

ទ្រនំ : ទីកន្លែងដែលសត្វស្លាបតែងទំ ។

គ. ពាក្យន័យដូចនឹងពាក្យ "ទ្រនំ"

ទ្រនំ សម្បុក លំនៅ

ឃ. ពាក្យផ្ទុយ

ធំ ≠ តូច ឃ្លាន ≠ ឆ្អែត

## សំណួរ

១. តើសត្វក្រសាររង់ចាំចឹកត្រីនៅឯណា ?

២. តើក្រសារឃើញត្រីអ្វី មុនដំបូងគេ ?

៣. តើក្រសារឃើញត្រីអ្វីខ្លះ ហែលពីមុខខ្លួន ?

៤. តើក្រសារចឹកត្រីទាំងនោះស៊ីដែរឬទេ ? ព្រោះអ្វី ?

## លំហាត់

ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្សំនិងប្រកបឱ្យបានត្រឹមត្រូវ ។

ត្រីចង្វា ត្រីក្រាញ់ ត្រីឆ្តោ ងងឹត ទ្រនំ ស្រេកឃ្លាន ក្រសារ ព្រលប់

## សំណេរ

ក. ចូរសរសេរតាមអានត្រួតពិនិត្យពាក្យខាងក្រោម ។

គិត ស៊ី ក្រោយ ក្រសារ ងងឹត ទ្រនំ ឆ្អែត ព្រលប់ បន្តិច ស្រេកឃ្លាន



www.elibraryofcambodia.org

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោម ។

| មាត់បឹង | តូច | ត្រីចង្វា | ហែល | ទ្រនំ | ស្រេកឃ្លាន |
|---|---|---|---|---|---|

១. មានក្រសារមួយឈរចាំចឹកត្រីនៅ ................ ។

២. ពេលនោះមាន .................តូចមួយបានហែលពីមុខវា ។

៣. សត្វក្រសារគិតថា ត្រីចង្វានេះ .........ណាស់ ស៊ីក៏មិនឆ្អែតដែរ ។

៤. ត្រីចង្វាក៏ ..........បាត់ទៅ ។

៥. ក្រសារវិលទៅរក ...........វិញ ទាំងក្តី ............ ។

គ. ចូរមើលរូប រួចបំពេញល្បះឱ្យបានត្រឹមត្រូវនិងបានសមស្របតាមរូប ។



១. នេះជាថ្ងៃ ......... ។ សាលារៀនមាន .,. ។

២. ខ្ញុំបាន ....................និង ....................ជាមួយមិត្តភក្តិខ្ញុំ ។



www.elibraryofcambodia.org

មេរៀនទី
៣៧

# ការខិតខំរៀនសូត្រ

## អំណាន



ការងារទីមួយរបស់កុមារ គឺការខិតខំសិក្សារៀនសូត្រ ។

កុមារត្រូវឆ្លៀតពេលខិតខំរៀនសូត្រឱ្យបានខ្ជាប់ខ្ជួន ។ ការរៀនសូត្របានល្អគឺដោយសារការព្យាយាម ។ បើការព្យាយាមនេះផ្តល់លទ្ធផលល្អ អ្នកដែលសប្បាយចិត្តជាងគេ គឺខ្លួនឯងផ្ទាល់ ។ លទ្ធផលល្អនេះ ក៏អាចចាត់ទុកថា ជាការតបស្នងសងគុណមាតាបិតានិងលោកគ្រូអ្នកគ្រូរបស់ខ្លួនផងដែរ ។

ការខិតខំរៀនសូត្រនឹងធ្វើឱ្យកុមារមានអនាគតភ្លឺស្វាង ។

## ការរៀនពាក្យ

ក. អំណានពាក្យ

លទ្ធផល អានថា ឡាត់-ធៈ-ផល

មាតាបិតា អានថា មា-ដា-បិ-ដា



www.elibraryofcambodia.org

អនាគត អានថា អៈ-ណា-គត់

ខ. ពន្យល់ពាក្យ

លទ្ធផល : ផលដែលសម្រេចបាន ។

តបស្នង : សងគុណ ។

អនាគត : ពេលខាងមុខ ។

គ. ពាក្យន័យដូចនឹងពាក្យ "ព្យាយាម"

ព្យាយាម ខិតខំ ប្រឹងប្រែង អំណត់

ឃ. ពាក្យផ្ទុយ

គុណ ≠ ទោស ភ្លឺស្វាង ≠ ងងឹតងងល់

## សំណួរ

១. តើការងារទីមួយរបស់កុមារគឺអ្វី ?

២. តើការសិក្សាទទួលបានលទ្ធផលល្អដោយសារអ្វី ?

៣. ដើម្បីតបស្នងសងគុណមាតាបិតានិងគ្រូ តើកុមារត្រូវធ្វើដូចម្តេច ?

៤. តើការខិតខំរៀនសូត្រនឹងធ្វើឱ្យកុមារមានអនាគតដូចម្តេច ?

## លំហាត់

ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្សំនិងប្រកបឱ្យបានត្រឹមត្រូវ ។

ក្មេងខ្ចី ការងារ ដូច្នេះ ខ្ជាប់ខ្ជួន ព្យាយាម លទ្ធផល
សប្បាយ មាតាបិតា អនាគត ភ្លឺស្វាង



www.elibraryofcambodia.org

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យនិងល្បះខាងក្រោម ។

ការងារ ខ្ជាប់ខ្ជួន លទ្ធផល មាតាបិតា ព្យាយាម

ការខិតខំរៀនសូត្រនឹងធ្វើឱ្យកុមារមានអនាគតភ្លឺស្វាង ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបាន ត្រឹមត្រូវ ។

| | | | |
|---|---|---|---|
| ភ្លឺស្វាង | រៀនសូត្រ | ជាងគេ | លោកគ្រូអ្នកគ្រូ |
| ការព្យាយាម | ចាត់ទុក | កុមារ | លទ្ធផល |

១. ការងារទីមួយរបស់ ........ គឺការខិតខំសិក្សារៀនសូត្រ ។

២. ដូច្នេះ កុមារត្រូវឆ្លៀតពេលខិតខំ ................ ឱ្យបានខ្ជាប់ខ្ជួន ។

៣. ការរៀនសូត្របានល្អគឺដោយសារ .................... ។

៤. បើការព្យាយាមនេះផ្ដល់នូវ .............. ល្អ អ្នកដែលសប្បាយចិត្ត ............... គឺខ្លួនឯងផ្ទាល់ ។

៥. លទ្ធផលល្អនេះ ក៏អាច .......... ថា ជាការតបស្នងសងគុណមាតាបិតា និង ...................... របស់ខ្លួនផងដែរ ។

៦. ការខិតខំរៀនសូត្រនឹងធ្វើឱ្យកុមារមានអនាគត ............. ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ "ខិតខំ" ។



www.elibraryofcambodia.org

# មេរៀនទី ៣៨ រឿងក្អែកការកូន

## ការស្ដាប់



## សំណួរ

១. តើស្ដេចក្អែករៀបការកូននៅកន្លែងណា ?

២. ហេតុអ្វីបានជាអណ្ដើកមកដល់ក្រោយគេ ?

៣. ហេតុអ្វីបានជាអណ្ដើកធ្លាក់ចុះមកដល់ដីវិញ ?

## លំហាត់

ចូររៀបលំដាប់ព្រឹត្តិការណ៍រឿងដោយបង់លេខតាមលំដាប់ក្នុងប្រអប់ខាងក្រោម ។

☐ មួយរំពេចនោះ អណ្ដើកក៏របូតមាត់ពីកន្ទុយពស់ ធ្លាក់ខ្ទោកមកលើដីបណ្ដាលឱ្យស្រាំស្នូកនៅជាប់ស្នាមរហូតមកដល់សព្វថ្ងៃនេះ ។

☐ មានស្ដេចក្អែកមួយចាត់ឱ្យពួកពលទៅអញ្ជើញភ្ញៀវទាំងអស់មកស៊ីការកូន ។

☐ ពេលនោះ ពស់ក៏ឱ្យស្ដេចអណ្ដើកខាំកន្ទុយ ហើយលូនយោងអណ្ដើកឡើងទៅលើ ។



បោះពុម្ពផ្សាយ ឆ្នាំ 2016 PDH

www.elibraryofcambodia.org

☐ ស្ដេចអណ្ដើកខំវារទៅនឹងគេដែរ តែទៅដល់ក្រោយគេក៏ប្រទះឃើញពស់លូនបម្រុងនឹងទៅស៊ីការកូនស្ដេចក្អែកដែរ ។

## សំណេរ

ក. ចូរសរសេរតាមអានត្រួតពិនិត្យពាក្យនិងល្បះខាងក្រោម ។

ភ្ញៀវ បម្រុង ផ្សំផ្គុំ អណ្ដើក កន្ទុយ

អណ្ដើករបូតមាត់ពីកន្ទុយពស់ធ្លាក់ខ្ទោកមកលើដី ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោម ។

កន្ទុយ | អណ្ដើក | ភ្ញៀវ | ស្លាម | ក្អែក | ហាម | ខំវារ | ឃើញ

១. មានស្ដេច ....មួយចាត់ឱ្យពួកពលហើរហៅ ...ទាំងអស់មកស៊ីការកូន ។

២. ស្ដេចអណ្ដើក ...........ទៅនឹងគេដែរ តែទៅដល់ក្រោយគេក៏ប្រទះ .........ពស់លូនបម្រុងនឹងទៅស៊ីការកូនស្ដេចក្អែកដែរ ។

៣. ពេលនោះ ពស់ក៏ឱ្យស្ដេច ...........ខាំកន្ទុយ ហើយលូនយោងឡើងទៅលើដោយ ............ឱ្យប្រយ័ត្នមាត់ ។

៤. មួយរំពេចនោះ អណ្ដើកក៏របូតមាត់ពី .......ពស់ធ្លាក់ ខ្ទោកមកលើដីបណ្ដាលឱ្យស្រាំស្នូកនៅជាប់ ............រហូតមកដល់សព្វថ្ងៃនេះ ។



១. ពស់កំពុង ............. ។



២. អណ្ដើកកំពុង ............. ។



www.elibraryofcambodia.org

មេរៀនទី
៣៩

# យើងទៅសាលារៀន

## ចម្រៀង



(លំនាំបទ ផ្កាយលើមេឃ)

មកមិត្តយើងអើយ កុំនៅកន្តើយទៅសាលារៀន
ដើរអែបខាងស្តាំតាមគ្រូបង្រៀន ទៅសាលារៀនឱ្យបានមុនគ្រូ ។(ពីរដង)
ដល់ពេលចេញលេង ពួកយើងក្មេងៗកុំបង្អង់យូរ
លេងល្បែងកម្សាន្តអារម្មណ៍បានធូរ កុំបង្អង់យូរលេងឱ្យសប្បាយ ។(ពីរដង)

## ការរៀនពាក្យ

ក. អំណានពាក្យ

អារម្មណ៍ អានថា អា-រ៉ម់



www.elibraryofcambodia.org

កន្ដើយ　　អានថា　កន់-តើយ

កម្សាន្ដ　　អានថា　កំ-សាន

ខ. ពន្យល់ពាក្យ

កន្ដើយ : ព្រងើយ មិនយកចិត្តទុកដាក់ ។

កម្សាន្ដ : សម្រាកចិត្ត ធ្វើចិត្តឱ្យស្រាកស្រាន្ដ ។

អារម្មណ៍ : គ្រឿងទាក់ទាញចិត្ត គំនិត ការដឹង ។

គ. ពាក្យន័យដូចនឹងពាក្យ "ដើរ"

ត្រាច់ យាង យាត្រា និមន្ដ ធ្វើដំណើរ ចរ លីលា ប្រព្រឹត្ត

ឃ. ពាក្យផ្ទុយ

មិត្ត ≠ សត្រូវ　　ធូរ ≠ តឹង　　យូរ ≠ ឆាប់

## សំណួរ

១. តើពួកគេនាំគ្នាទៅឯណា ?

២. តើគេប្រញាប់ទៅសាលារៀនឱ្យបានមុនអ្នកណា ?

៣. តើពេលចេញលេង ពួកគេនាំគ្នាធ្វើអ្វី ?

៤. តើអ្នកចូលចិត្តរៀនផង លេងកម្សាន្ដផងដែរឬទេ ? ព្រោះអ្វី ?

## លំហាត់

ក. ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្សំនិងប្រកបឱ្យបានត្រឹមត្រូវ ។

កម្សាន្ដ មិត្ត យើង អារម្មណ៍ ពាក្យ បង្រៀន កន្ដើយ សាលារៀន ស្ដាំ



www.elibraryofcambodia.org

ខ. ចូរប្រាប់ពាក្យចួនក្នុងបទចម្រៀង ឱ្យបានត្រឹមត្រូវ ។

១. ពាក្យ "អើយ" ចួននឹងពាក្យ ......................

២. ពាក្យ "សាលារៀន" ចួននឹងពាក្យ ....................

៣. ពាក្យ "យូរ" ចួននឹងពាក្យ...................

## សំណេរ

ក. ចូរសរសេរតាមអានត្រួតពិនិត្យពាក្យនិងល្បះខាងក្រោម ។

> ដើរ យូរ បង្រៀន បង្គង់ មិត្ត
>
> ល្បែងកម្សាន្ត ធ្វើឱ្យអារម្មណ៍យើងបានធូរ ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| យើង | លោកគ្រូ | ស្តាំ | អារម្មណ៍ | ល្បែង |
|---|---|---|---|---|

១. យើងត្រូវដើរអែបខាង ................ ។

២. យើងត្រូវទៅដល់ថ្នាក់រៀនឱ្យបានមុន ............ ។

៣. ពេលចេញលេង យើងនាំគ្នាលេង .................កម្សាន្ត ។

៤. ល្បែងកម្សាន្តធ្វើឱ្យ ...................យើងបានធូរ ។

៥. នៅសាលារៀន ............សប្បាយ ព្រោះបានរៀនផងលេងផង ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ "ពេល" ។



www.elibraryofcambodia.org

មេរៀនទី
៤០

# ការធ្វេសប្រហែស

## អំណាន



ថ្ងៃនេះ អ្នកគ្រូបង្រៀនមេរៀនភាសាខ្មែរ។ គាត់ប្រាប់ឱ្យសិស្សទាំងអស់បើកសៀវភៅអានមេរៀន។ ធីតាបើកកាតាបរកសៀវភៅមិនឃើញសោះ។ នាងងាកមើលឆ្វេងស្ដាំ រួចលូករាវចុះឡើងៗ។

ម៉ានី : ធីតា! តើឯងកំពុងរកអ្វី ?

ធីតា : ខ្ញុំកំពុងរកសៀវភៅពុម្ពភាសាខ្មែរ។

ម៉ានី : តើឯងទុកវានៅឯណា ?

ធីតា : ខ្ញុំទុកវានៅក្នុងកាតាប។ តើឯងមានឃើញវាទេ ?

ម៉ានី : ទេ! ខ្ញុំមិនឃើញវាទេ។ ឯងរកនឹកមើល តើឯងទុកវានៅឯណា ?



www.elibraryofcambodia.org

ធីតា : ខ្ញុំទុកវាលើទូនៅផ្ទះឯនោះ! ខ្ញុំភ្លេចដាក់វាចូលក្នុងកាតាប ។

ម៉ានី : បើអ៊ីចឹង! ឯងមើលសៀវភៅជាមួយខ្ញុំទៅ!

## ការរៀនពាក្យ

ក. អំណានពាក្យ

ពុម្ព អានថា ពុំ

ខ. ពន្យល់ពាក្យ

ធ្វេសប្រហែស : ធ្លោយ ប្រហែស ។

រាវ : ជ្រាវរកដោយដៃ ។

ពុម្ព : រូបតំណាង សំណាក ។

គ. ពាក្យន័យដូចនឹងពាក្យ "ឱ្យ"

ឱ្យ ជូន ប្រគេន ថ្វាយ ប្រទាន

ឃ. ពាក្យផ្ទុយ

ភ្លេច ≠ ចាំ

ប្រហែស ≠ ប្រយ័ត្ន

## សំណួរ

១. តើអ្នកគ្រូបង្រៀនមេរៀនអ្វី ?

២. តើធីតារកសៀវភៅអ្វី ?

៣. តើធីតាទុកសៀវភៅនៅឯណា ?

៤. តើប្អូនត្រូវធ្វើដូចម្ដេច ដើម្បីកុំឱ្យភ្លេចសៀវភៅ ?



www.elibraryofcambodia.org

## លំហាត់

ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្សំនិងប្រកបឱ្យបានត្រឹមត្រូវ ។

ថ្ងៃ មេរៀន ប្រាប់ សៀវភៅ ឆ្វេង ស្តាំ លួក រាវ អ៊ីចឹង គុម្ព

## សំណេរ

ក. ចូរសរសេរតាមអានចម្លងកន្សោមពាក្យនិងល្បះខាងក្រោម ។

ធ្វេសប្រហែស គ្រូបង្រៀន សៀវភៅពុម្ព ឆ្វេងស្តាំ

ខ្ញុំកំពុងរកសៀវភៅពុម្ពភាសាខ្មែរ ។ ខ្ញុំភ្លេចដាក់វាចូលក្នុងកាតាប ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

កាតាប | ភាសា | បង្រៀន | សៀវភៅ | ភ្លេច | លើ | ក្នុង

១. ថ្ងៃនេះអ្នកគ្រូ............មេរៀន.......................ខ្មែរ ។

២. ធីតាបើក..................រក...................មិនឃើញសោះ ។

៣. ខ្ញុំទុកវា .......ទូនៅផ្ទះឯនោះ ! ខ្ញុំ ......ដាក់វាចូល .......កាតាប ។

គ. ចូរមើលរូប រួចបំពេញសំណួរខាងក្រោម ។







១. តើ ... នៅឯណា? ២. តើ ... នៅឯណា ? ៣. តើ .... កំពុងរៀននៅឯណា ?



www.elibraryofcambodia.org

# មេរៀនទី ៤១ ម្តាយឪពុកខ្ញុំ

## មេសូត្រ



(បទកាកគតិ)

ខ្ញុំគោរពម៉ែ
ធ្វើការគ្មានល្ហែ
ថែទាំគ្រួសារ
ដេរប៉ះបោកគក់
ចម្អិនអាហារ
មើលសព្វកិច្ចការ
ក្នុងគេហដ្ឋាន ។

ខ្ញុំគោរពពុក
ទទួលមន្ទុក
គ្រួសារសុខសាន្ត
ធ្វើស្រែចម្ការ
ពុំគិតនឿយប្រាណ
រកប្រាក់កាសបាន
ចិញ្ចឹមកូនចៅ ។



www.elibraryofcambodia.org

## ការរៀនពាក្យ

ក. អំណានពាក្យ

គោរព អានថា គោ-រប់

ចម្អិន អានថា ចំ-អិន

សព្វ អានថា សប់

កិច្ចការ អានថា កិច-កា

គេហដ្ឋាន អានថា គេ-ហាត់-ថាន

ខ. ពន្យល់ពាក្យ

បន្ទុក : ភារៈ ឬកិច្ចការធុរៈសព្វបែបយ៉ាងដែលទទួល ។

កិច្ចការ : ការដែលត្រូវធ្វើ ការរវល់ ។

សព្វ : គ្រប់ គ្រប់យ៉ាង ទាំងអស់ ទាំងស្រុង ទាំងមូល ។

គ. ពាក្យន័យដូចនឹងពាក្យ "ប្រាណ"

ប្រាណ ខ្លួន កាយ ព្រះកាយ

ឃ. ពាក្យផ្ទុយ

នឿយ ≠ ស្រណុក

សុខសាន្ត ≠ ទុក្ខព្រួយ

## សំណួរ

១. តើអ្នកណាដេរប៉ះបោកគក់និងចម្អិនអាហារ ?

២. តើអ្នកណាជាអ្នកធ្វើស្រែចម្ការនិងរកប្រាស់កាស ?

៣. តើប្អូនគោរពឪពុកម្ដាយប្អូនឬទេ ? ព្រោះអ្វី ?



www.elibraryofcambodia.org

## លំហាត់

ក. ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្សំនិងប្រកបឱ្យបានត្រឹមត្រូវ ។

| | | | | | |
|---|---|---|---|---|---|
| គោរព | គ្រួសារ | ចម្អិន | អាហារ | សព្វ | កិច្ចការ |
| គេហដ្ឋាន | បន្ទុក | សុខសាន្ត | ចម្ការ | ចិញ្ចឹម | |

ខ. ចូរប្រាប់ពាក្យចួនក្នុងមេសូត្រ ។

១. ពាក្យ "ម៉ែ" ចួននឹងពាក្យ......................

២. ពាក្យ "អាហារ" ចួននឹងពាក្យ......................

៣. ពាក្យ "ពុក" ចួននឹងពាក្យ......................

៤. ពាក្យ "ប្រាណ" ចួននឹងពាក្យ......................

## សំណេរ

ក. ចូរសរសេរតាមអានត្រួតពិនិត្យពាក្យនិងល្បះខាងក្រោម ។

អាហារ    កិច្ចការ    គេហដ្ឋាន    សុខសាន្ត    ចម្ការ

យើងត្រូវគោរពឪពុកម្ដាយ ព្រោះគាត់ជាអ្នកមានគុណ ។

ខ. ចូរសរសេររៀបរាប់ពីមនុស្សក្នុងគ្រួសាររបស់ប្អូនឱ្យបានត្រឹមត្រូវ ។

មនុស្សក្នុងគ្រួសាររបស់ខ្ញុំមាន ...............នាក់ គឺឪពុក .................

...................................................... ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ "អាហារ" ។



www.elibraryofcambodia.org

មេរៀនទី
៤២

# ពេលភ្ញៀវមកលេងផ្ទះ

## អំណាន



ថ្ងៃមួយ មានភ្ញៀវមកលេងផ្ទះម៉ានី ។

ក្រោយពីរាក់ទាក់ជាមួយភ្ញៀវរួច ម្ដាយម៉ានីក៏ហៅ ៖ "អីកូន! លោកពូឯងអញ្ជើញមកលេង" ។ ម៉ានីស្ទុះស្ទាចេញពីក្នុងផ្ទះមកដោយត្រេកអរ ។ ម៉ានី ៖ "ជម្រាបសួរលោកពូ! ខ្ញុំនឹកលោកពូណាស់! តើលោកពូសុខសប្បាយឬទេ ? "

ពូរបស់ម៉ានីញញឹមហើយតបវិញ ៖ "ក្មួយពូចេះណាស់ ! ពូក៏នឹកក្មួយណាស់ដែរ ។ ពូសុខសប្បាយជាធម្មតាទេ ។ នេះជារបស់ដែលពូយកមកផ្ញើក្មួយ!" ។ ម៉ានីសំពះទទួលដោយដៃពីរ រួចឆ្លើយថា អរគុណ ។ ពេលភ្ញៀវកំពុងនិយាយគ្នាជាមួយម្ដាយ ម៉ានីបានទៅចាក់ទឹកដាក់កែវកាន់ដើរមកជិត រួចជូនទឹកទៅភ្ញៀវដោយដៃទាំងពីរ ព្រមទាំងពោលតិចៗ ៖ "អញ្ជើញពិសាទឹកលោកពូ" ។ ពូរបស់ម៉ានីទទួលយកទឹករួចតប ៖ "អរគុណក្មួយ!" ។

មុនពេលត្រឡប់ទៅវិញ ពូរបស់ម៉ានីសរសើរម៉ានីថា ជាក្មេងល្អ ចេះគួរសម ។



www.elibraryofcambodia.org

## ការរៀនពាក្យ

ក. អំណានពាក្យ

ជម្រាប អានថា ជំ-រាប

ខ. ពន្យល់ពាក្យ

ភ្ញៀវ : អ្នកដទៃដែលមកលេង មករក មកសួរនាំ ។

អញ្ជើញ : ជូនដំណឹង ឬហៅរកដោយគោរព ។

គួរសម : ការសម្ដែងឬកពាសុភាពរៀបរយ ត្រូវបែបបទ ។

ស្ទុះស្ទា : ការប្រញាប់ ។

គ. ពាក្យន័យដូចនឹងពាក្យ "ដៃ"

ដៃ ហត្ថា ព្រះហស្ត

ឃ. ពាក្យផ្ទុយ

ញញឹម ≠ ក្រៀមក្រំ សរសើរ ≠ បង្អាប់

## សំណួរ

១. តើអ្នកណាមកលេងផ្ទះម៉ានី ?

២. តើម៉ានីធ្វើដូចម្ដេចខ្លះ ពេលជួបលោកពូដំបូង ?

៣. តើម៉ានីធ្វើដូចម្ដេចខ្លះ ពេលភ្ញៀវកំពុងនិយាយគ្នា ?

៤. តើអ្នកត្រូវធ្វើដូចម្ដេច ពេលមានភ្ញៀវមកលេងផ្ទះ ?

## លំហាត់

ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្ទាំនិងប្រកបឱ្យបានត្រឹមត្រូវ ។

ភ្ញៀវ ឯង អញ្ជើញ ស្ទុះស្ទា ត្រេកអរ

ជម្រាបសួរ សុខសប្បាយ ក្មួយ ពិសា គួរសម



www.elibraryofcambodia.org

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យ កន្សោមពាក្យ និងល្បះខាងក្រោម ។

> ភ្ញៀវ អញ្ជើញ ស្ទុះស្ទា ជម្រាបសួរ ត្រេកអរ
> មុនពេលត្រឡប់ទៅវិញ ពូរបស់ម៉ានីសរសើរម៉ានីថា ជាក្មេងល្អ ចេះគួរសម ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| | | | |
|---|---|---|---|
| ត្រឡប់ | អរគុណ | គួរសម | អញ្ជើញ |
| ជម្រាប | សប្បាយ | សំពះ | ជាមួយ |

១. ក្រោយពីរាក់ទាក់.......ភ្ញៀវរួច ម្តាយម៉ានីក៏ហៅ "អីកូន! លោកពូឯង ...........មកលេង" ។

២. ម៉ានី ៖ "...........សួរលោកពូ! ខ្ញុំនឹកលោកពូណាស់! តើលោកពូសុខ ..............ឬទេ" ?

៣. ម៉ានី .............ទទួលដោយដៃពីរ រួចឆ្លើយថា ............!

៤. មុនពេល ...ទៅវិញ ពូរបស់ម៉ានីសរសើរម៉ានីថា ជាក្មេងល្អ ចេះ ... ។

គ. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

១. កុមារល្អត្រូវចេះ .............ចាស់ទុំ ។

២. មុនពេលចេញទៅសាលារៀន កូនត្រូវ .........ឪពុកម្តាយ ។

៣. ពេលទទួលអំណោយ រួចកុំភ្លេចនិយាយថា ..............!



www.elibraryofcambodia.org

# មេរៀនទី ៤៣ ការប្រើពាក្យ របស់ខ្ញុំ របស់ឯង របស់យើង

## ការនិយាយ





សំ : នេះជាសៀវភៅអ្វី ?

ស្រីម៉ៅ : នេះជាសៀវភៅភាសាខ្មែរថ្នាក់ទី ២ ។

សំ : តើវាជារបស់ឯងមែនឬទេ ?

ស្រីម៉ៅ : ចាស ! វាជារបស់ខ្ញុំ ។ តើខ្មៅដៃពណ៌មួយប្រអប់នេះជារបស់យើងមែនឬទេ ?

សំ : បាទ ! វាជារបស់យើង ។ អ្នកគ្រូឱ្យយើងប្រើជាមួយគ្នា ។

## សំណួរ

១. តើពាក្យ "របស់ខ្ញុំ" ប្រើចំពោះនរណា ?

២. តើពាក្យ "របស់ឯង" ប្រើចំពោះនរណា ?

៣. តើពាក្យ "របស់យើង" ប្រើចំពោះនរណា ?



www.elibraryofcambodia.org

## ចំណាំ

ពាក្យ "របស់ខ្ញុំ របស់ឯង របស់យើង របស់វា របស់គេ" សម្រាប់សម្គាល់ម្ចាស់វត្ថុ សត្វ រុក្ខជាតិដែលគេមាន ។

## លំហាត់

ចូរសង្កេតរូបភាព រួចជ្រើសរើសពាក្យក្នុងប្រអប់មកនិយាយបំពេញចន្លោះ ខាងក្រោមរូបភាពឱ្យបានត្រឹមត្រូវ ។

របស់ខ្ញុំ　　របស់ឯង　　របស់យើង　　របស់វា



នេះជា .................. ។



នេះជា .................. ។



នេះជា .................. ។



នេះជា .................. ។



www.elibraryofcambodia.org

## សំណេរ

ក. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| | | | |
|---|---|---|---|
| របស់វា | របស់យើង | របស់ខ្ញុំ | របស់ឯង |

១. តើឯងយកសៀវភៅ ..................... ទៅទុកនៅឯណា ? ខ្ញុំរកវាពុំឃើញទេ ។

២. សុខា ! តើបន្ទាត់ .......................... ជ្រុះបាត់ពីកាលណា ?

៣. នេះជាថ្នាក់រៀន .......................... ទាំងអស់គ្នា ។

៤. កុមារីនេះស្រឡាញ់សៀវភៅ .................... ណាស់ ។

ខ. ចូររៀបពាក្យ កន្សោមពាក្យក្នុងប្រអប់ខាងក្រោមឱ្យទៅជាល្បះត្រឹមត្រូវរួចចម្លងឱ្យបានស្អាត ។

| | | | | | |
|---|---|---|---|---|---|
| ១. | មួយប្រអប់ | នេះជា | របស់យើង ។ | ខ្មៅដៃពណ៌ | |
| ២. | ភាសាខ្មែរ | របស់ខ្ញុំ ។ | នេះជា | ថ្នាក់ទី ២ | សៀវភៅ |

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ "យើង" ។



www.elibraryofcambodia.org

# មេរៀនទី ៤៤ រឿងឪពុកនិងកូនដឹកលាទៅលក់

## អំណាន



កាលយូរលង់ណាស់មកហើយ មានបុរសម្នាក់និងកូនដឹកលាទៅលក់ឯផ្សារ។ ទៅដល់ភូមិមួយឮគេថា មានលាមិនជិះបែរជាដឹកទៅវិញ។ ឪពុកក៏ឱ្យកូនជិះ ហើយគាត់ជាអ្នកដើរ។ ទៅបានបន្តិចក៏ឮគេថា ខ្លួនចាស់ហើយមិនជិះបែរជាឱ្យកូនជិះទៅវិញ។ ឪពុកក៏ឡើងជិះលា ហើយឱ្យកូនដើរវិញ។ ដើរបានបន្តិចក៏ឮតាចាស់ម្នាក់និយាយថា កូននៅក្មេងមិនឱ្យជិះ បែរជាខ្លួនចាស់ជិះលាទៅវិញ។ ឪពុកនិងកូនក៏ឡើងជិះលាទាំងពីរនាក់។ អ្នកស្រុកឃើញក៏ថា លាមួយជិះគ្នាពីរនាក់ ធ្វើឱ្យលាដើរមិនចង់រួច។ ទាំងពីរនាក់ក៏នាំគ្នាសែងលាវិញម្តង។ លុះសែងដល់ស្ពានមួយ ទម្ងន់ក៏សង្កត់ខាងកូន។ កូនទ្រាំមិនបានក៏ទម្លាក់ស្នែងចោល លាក៏ធ្លាក់របៀលចុះក្នុងទឹកបាត់ទៅ។



www.elibraryofcambodia.org

## ការរៀនពាក្យ

ក. អំណានពាក្យ

ទម្ងន់ អានថា ទំ-ងន់

ទម្លាក់ អានថា ទំ-លាក់

សង្កត់ អានថា សង់-កត់

ខ. ពន្យល់ពាក្យ

ស្នែង : ប្រដាប់សម្រាប់សែង ដងស្នែង គ្រឿងសែង ។

ទ្រាំ : ខំអត់ អត់ធ្មត់ ។

ដឹក : នាំបណ្ដើរដោយកាន់ខ្សែ ។

គ. ពាក្យន័យដូចនឹងពាក្យ "បុរស"

បុរស ប្រុស

ឃ. ពាក្យផ្ទុយ

ចាស់ ≠ ក្មេង បាត់ ≠ ឃើញ

## សំណួរ

១. តើឪពុក និងកូនដឹកលាទៅណា ?

២. តើឪពុក និងកូនធ្វើដូចម្ដេច ពេលឮអ្នកស្រុកនិយាយ ?

៣. តើឪពុក និងកូនធ្វើដូចម្ដេច ពេលឮតាចាស់និយាយ ?

៤. ហេតុអ្វីបានជាឪពុក និងកូននាំគ្នាសែងលា ?



www.elibraryofcambodia.org

## លំហាត់

ក. ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្ទំនិងប្រកបឱ្យបានត្រឹមត្រូវ ។

| | | | | | |
|---|---|---|---|---|---|
| ឪពុក | បុរស | បន្តិច | ជិះ | បែរ | ដើរ |
| ស្នែង | ស្ពាន | ទម្លាក់ | ទម្ងន់ | ទ្រាំ | រមៀល |

ខ. ចូររៀបល្បះខាងក្រោមឱ្យត្រូវតាមលំដាប់លំដោយសាច់រឿង ។

១. ទៅបានបន្តិចក៏ឮគេថា ខ្លួនចាស់ហើយមិនជិះ បែរជាឱ្យកូនជិះទៅវិញ ។

២. ទៅដល់ភូមិមួយឮគេថា មានលាមិនជិះបែរជាដឹកដើរទៅវិញ ។

៣. កាលយូរលង់មកហើយ មានបុរសម្នាក់និងកូនដឹកលាទៅលក់ឯផ្សារ ។

៤. កូនទ្រាំមិនបានក៏ទម្លាក់ស្នែងចោល ។

៥. ឪពុក និងកូនក៏ឡើងជិះលាទាំងពីរនាក់ ។

៦. ទាំងពីរនាក់ក៏នាំគ្នាសែងលាវិញម្តង ។



www.elibraryofcambodia.org

## សំណេរ

ក. ចូរសរសេរតាមអានត្រួតពិនិត្យពាក្យនិងល្បះខាងក្រោម ។

> បុរស ស្អែង ជិះ ទម្ងន់ ទម្លាក់
>
> កាលយូរលង់ណាស់មកហើយ មានបុរសម្នាក់និងកូនដឹកលាទៅលក់ឯផ្សារ ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| ដឹក | បន្តិច | ទម្ងន់ | គាត់ | ពីរ | រួច | មកហើយ | ជិះ |
|---|---|---|---|---|---|---|---|

១. កាលយូរលង់ណាស់ .......... មានបុរសម្នាក់និងកូន ......... លាទៅលក់ឯផ្សារ ។

២. ឪពុកក៏ឱ្យកូនជិះ ហើយ ............. ជាអ្នកដើរ ។

៣. ទៅបាន ......... ក៏ឮគេថា ខ្លួនចាស់ហើយមិនជិះបែរជាឱ្យកូន ........ ទៅវិញ ។

៤. អ្នកស្រុកឃើញក៏ថា លាមួយជិះគ្នា ... នាក់ ធ្វើឱ្យលាដើរមិនចង់ ... ។

៥. លុះសែងដល់ស្ពានមួយ ............. ក៏សង្កត់ខាងកូន ។

គ. ចូររកពាក្យមកបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

១. ម្ដាយខ្ញុំ .......... ត្រីនៅឯផ្សារ ។

២. កុមារនាំគ្នា ............ សៀវភៅក្នុងបណ្ណាល័យ ។

៣. តើ .............. នៅឯណា ?

៤. គាត់ជិះ ............... ទៅសាលារៀន ។



www.elibraryofcambodia.org

# មេរៀនទី ៤៥ មិត្តល្អរបស់កូនឆ្មាបូបូ

## អំណាន




ថ្ងៃនេះ ជាថ្ងៃចូលរៀនដំបូង។ ពេលទៅជិតដល់សាលារៀន កូនទន្សាយតូនីឃើញបូបូកំពុងឈរយំ។ តូនីក៏រត់មកសួរ ៖ "ហេតុអ្វីបានជាមិត្តយំ ?" បូបូឆ្លើយ ៖ "ខ្មៅដៃរបស់ខ្ញុំជ្រុះបាត់ហើយ! ខ្ញុំមិនហ៊ានចូលរៀនទេ ព្រោះគ្មានអ្វីសរសេរ"។

តូនីនិយាយ ៖"ឈប់យំទៅ! ខ្ញុំមានខ្មៅដៃពីរដើម ខ្ញុំនឹងឱ្យមិត្តមួយ។ លើកក្រោយឯងត្រូវដាក់សៀវភៅ ខ្មៅដៃ បន្ទាត់ ក្នុងកាតាប ឬថង់ឱ្យបានល្អ ទើបវាមិនជ្រុះ"។ បូបូឆ្លើយ ៖ "អរគុណ តែខ្ញុំគ្មានកាតាបទេ"។ តូនីនិយាយ ៖ "ខ្ញុំមានកាតាបមួយទៀត! ស្អែកខ្ញុំនឹងយកមកឱ្យឯង"។

បូបូញញឹមហើយនិយាយ ៖ "អរគុណតូនី! មិត្តមានចិត្តល្អណាស់!"។



www.elibraryofcambodia.org

## ការរៀនពាក្យ

ក. អំណានពាក្យ

ទន្សាយ អានថា ទន់-សាយ

ខ. ពន្យល់ពាក្យ

ស្អែក : ថ្ងៃបន្ទាប់ពីថ្ងៃនេះ ។

គ. ពាក្យន័យដូចនឹងពាក្យ "មិត្ត"

មិត្ត សម្លាញ់ ពួកម៉ាក ភ្លើ

ឃ. ពាក្យផ្ទុយ

បាត់ ≠ គង់ ឃើញ ដំបូង ≠ ចុងក្រោយ

## សំណួរ

១. ហេតុអ្វីបានជាបូបូយំ ?

២. តើនរណាជាអ្នកឱ្យខ្មៅដៃទៅបូបូ ? តើគេសន្យាឱ្យអ្វីទៀត ?

៣. តើបូបូនិយាយដូចម្ដេចនៅពេលទទួលបានខ្មៅដៃ ?

៤. តើពាក្យ "របស់ខ្ញុំ" ប្រើចំពោះនរណា ?

## លំហាត់

ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្ទាំ និងប្រកបឱ្យបានត្រឹមត្រូវ ។

| | | | | | |
|---|---|---|---|---|---|
| មិត្ត | ចិត្ត | ដំបូង | ទន្សាយ | ខ្មៅដៃ | ហ៊ាន |
| ញញឹម | សៀវភៅ | អរគុណ | ល្អ | | |



www.elibraryofcambodia.org

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យក្នុងប្រអប់ខាងក្រោម ។

> កន្លែង សរសេរ ខ្មៅដៃ សួរ ដំណើរ
>
> បូបូញញឹមហើយនិយាយ ៖ "អរគុណតូនី ! មិត្តមានចិត្តល្អណាស់ !" ។

ខ. ចូរបំពេញពាក្យក្នុងចន្លោះល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

ថ្ងៃនេះជាថ្ងៃចូលរៀនដំបូង ។ បូបូ .... សាលារៀន ។ លុះទៅដល់ជិតរបងសាលារៀនស្រាប់តែបូបូឈរយំ ។ កូនទន្សាយតូនីឃើញបូបូយំ ក៏រត់មកសួរ ៖ "ហេតុអ្វីបានជាមិត្ត ...... ?" បូបូឆ្លើយ ៖ "ខ្មៅដៃរបស់ខ្ញុំជ្រុះបាត់ហើយ" ។ ខ្ញុំគ្មានអ្វី .... ទេ ។ តូនីនិយាយ ៖ "ឈប់យំទៅ ខ្ញុំមាន ..............ពីរដើម ខ្ញុំឱ្យមិត្តមួយដើម" ។ បូបូញញឹមហើយ និយាយ ៖ "ខ្ញុំ ..........មិត្ត! មិត្តមាន .......... ល្អណាស់ !" ។

គ. ចូរតែងល្បះតាមន័យរបស់រូបភាពខាងក្រោមឱ្យបានសមស្រប ។




.................. ។ .................. ។ .................. ។



www.elibraryofcambodia.org

មេរៀនទី ៤៦

# ការរៀនអក្សរផ្ចង់

## អំណាន




ពេលរៀនសរសេរអក្សរ យើងខំប្រឹងផ្ចិតផ្ចង់សរសេរឱ្យបានត្រឹមត្រូវល្អ ។ ដំបូងអ្នកគ្រូបានប្រាប់ពីរបៀបដាក់សៀវភៅលើតុ របៀបកាន់ខ្មៅដៃ និងរបៀបសរសេរ ។ យើងគូសបន្ទាត់តាមគាត់ក្នុងសៀវភៅសរសេររបស់យើង ។ យើងចាប់គូសតាមរាងអក្សរ ដោយយឺតៗតាមក្បួនខ្នាត ។ អ្នកគ្រូដើរជួយកែលម្អសំណេររបស់យើង ។ អ្នកគ្រូបានលើកកិច្ចការអក្សរផ្ចង់របស់សិស្ស ដែលសរសេរបានត្រឹមត្រូវល្អបង្ហាញសិស្សដទៃទៀតឱ្យយកគំរូតាម ។

យើងទាំងអស់គ្នាសប្បាយចិត្តនឹងសរសេរអក្សរបានស្មើស្អាតនិងត្រឹមត្រូវ ។



www.elibraryofcambodia.org

## ការរៀនពាក្យ

ក. អំណានពាក្យ

បង្ហាញ អានថា បង់-ហាញ

ខ. ពន្យល់ពាក្យ

ផ្ចិតផ្ចង់ : យកចិត្តទុកដាក់ ប្រិតប្រៀន ។

ក្បួនខ្នាត : ការកំណត់ជាគោលសម្រាប់ធ្វើតាម ។

បង្ហាញ : ធ្វើឱ្យឃើញ ។

គ. ពាក្យផ្ទុយ

ផ្ចិតផ្ចង់ ≠ ខ្ជីខ្ជា

សប្បាយ ≠ ទុក្ខ

## សំណួរ

១. តើពេលរៀនអក្សរផ្ចង់ ដំបូងអ្នកគ្រូបានប្រាប់ពីអ្វីខ្លះ ?

២. បន្ទាប់ពីអ្នកគ្រូណែនាំរួចហើយ តើយើងត្រូវធ្វើដូចម្ដេចខ្លះ ?

៣. ពេលកែលម្អសំណេរយើងហើយ តើអ្នកគ្រូធ្វើដូចម្ដេចទៀត ?

៤. ហេតុអ្វីបានជាប្អូនចូលចិត្តរៀនសរសេរអក្សរផ្ចង់ ?

## លំហាត់

ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្ទៀងនិងប្រកបឱ្យបានត្រឹមត្រូវ ។

អក្សរផ្ចង់ ផ្ចិតផ្ចង់ គូសបន្ទាត់ ក្បួនខ្នាត បង្ហាញ គំរូ សប្បាយ ស្មើ ស្អាត



www.elibraryofcambodia.org

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យនិងល្បះខាងក្រោម ។

ស្មើ បន្ទាត់ កិច្ចការ បង្ហាញ សប្បាយ

ពេលរៀនសរសេរអក្សរ យើងខំប្រឹងផ្ចិតផ្ចង់សរសេរឱ្យបានត្រឹមត្រូវ ។

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| | | | | |
|---|---|---|---|---|
| ប្រាប់ | ខ្មៅដៃ | ផ្ចិតផ្ចង់ | សៀវភៅ | សរសេរ |
| ត្រឹមត្រូវ | បន្ទាត់ | ក្នុង | សប្បាយ | |

១. ពេលរៀនអក្សរផ្ចង់ យើងខំប្រឹង ......សរសេរឱ្យបាន ......ល្អ ។

២. ដំបូងអ្នកគ្រូបាន ..........ពីរបៀបដាក់ ........លើតុ របៀបកាន់ .......និងរបៀប ........ ។

៣. យើងគូស .........តាមគាត់ .........សៀវភៅយើង ។

៤. យើងទាំងអស់គ្នា .............ចិត្តនឹងសរសេរ ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ "សរសេរ" ។



www.elibraryofcambodia.org

# មេរៀនទី ៤៧ ការរៀបរាប់សមាជិកក្នុងគ្រួសារ

## ការនិយាយ

ចូរអានសម្ដីរបស់ស្រីម៉ៅ ។ តើស្រីម៉ៅនិយាយពីនរណាខ្លះ ?



ខ្ញុំឈ្មោះស្រីម៉ៅ ។
ខ្ញុំរៀននៅថ្នាក់ទី ២ ។



ម្ដាយខ្ញុំឈ្មោះណារី ។
គាត់ជាអ្នកតម្បាញ ។



ឪពុកខ្ញុំឈ្មោះសុខខេង ។
គាត់ជា គ្រូបង្រៀន ។



គ្រួសារខ្ញុំមានមនុស្សប្រាំមួយនាក់ គឺជីដូន ជីតា ម្ដាយ ឪពុក ខ្ញុំ និងប្អូនប្រុសខ្ញុំ ។

## សំណួរ

១. តើឪពុកស្រីម៉ៅឈ្មោះអ្វី ?
២. តើគាត់ធ្វើការអ្វី ?
៣. តើម្ដាយស្រីម៉ៅឈ្មោះអ្វី ?
៤. តើគាត់ធ្វើការអ្វី ?



www.elibraryofcambodia.org

## សំណេរ

ក. ចូរមើលរូបភាព រួចសរសេរបំពេញល្បះខាងក្រោម ។



ម្ដាយខ្ញុំជា ............. ។



ឪពុកខ្ញុំជា ............. ។



បងស្រីខ្ញុំជា ............. ។



បងប្រុសខ្ញុំជា ............. ។

ខ. ចូរសរសេរឈ្មោះ និងមុខរបរសមាជិកក្នុងគ្រួសារអ្នក ឱ្យបានត្រឹមត្រូវ ។

១. គ្រួសារខ្ញុំមានមនុស្សចំនួន ........ នាក់ ។

២. ម្ដាយខ្ញុំឈ្មោះ ................ ។ គាត់ជា ................ ។

៣. ឪពុកខ្ញុំឈ្មោះ ................ ។ គាត់ជា ................ ។

៤. បងប្រុសខ្ញុំឈ្មោះ ............ ។ គាត់ជា ................ ។

៥. ជីតាខ្ញុំឈ្មោះ ................ ។ គាត់ជា ................ ។

៦. ជីដូនខ្ញុំឈ្មោះ ................ ។ គាត់ជា ................ ។

៧. ខ្ញុំឈ្មោះ ...................... ។ ខ្ញុំជា ................ ។



www.elibraryofcambodia.org

មេរៀនទី ៤៨

# រឿងកញ្ជ្រោងនិងកូនពពែ

## ការស្តាប់

ចូរស្តាប់គ្រូរបស់អ្នកនិទានរឿង រួចឆ្លើយនឹងសំណួរ ។



## សំណួរ

១. តើមេពពែនិងកូននៅឯណា ?

២. មុននឹងចេញទៅរកចំណី តើមេពពែផ្តាំកូនដូចម្តេចខ្លះ ?

៣. តើនរណាមកគោះទ្វារហៅកូនពពែ ?

៤. តើកូនពពែបើកទ្វារឱ្យឬទេ ? តើរូបភាពណាជាចម្លើយសមស្រប ?



កូនពពែបើកទ្វារឱ្យកញ្ជ្រោង ។



កូនពពែមិនបើកទ្វារឱ្យកញ្ជ្រោងទេ ។



www.elibraryofcambodia.org

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យនិងល្បះខាងក្រោម ។

> កញ្ជ្រោង ផ្តែផ្តាំ សាហាវ ទ្វារ បង្ហាញ
>
> រាល់ថ្ងៃ មុននឹងចេញទៅរកចំណី មេពពែតែងតែផ្តាំកូនថា នៅពេលដែលម៉ែមិននៅផ្ទះ កូនកុំដើរលេងផ្តេសផ្តាសឱ្យសោះ ។

ខ. តើរូបភាពខាងក្រោមបង្ហាញពីអ្វី ? ចូរសរសេរបំពេញល្បះក្រោមរូបភាពឱ្យបានត្រឹមត្រូវ ។



មេពពែនិងកូននៅក្នុង ..... នេះ ។



កូនពពែបិទ ..... ផ្ទះ ។



កញ្ជ្រោង ..... ទ្វារផ្ទះពពែ ។

គ. ចូរសរសេរអក្សរផ្ចង់អំពីពាក្យ "ពពែ" ។



www.elibraryofcambodia.org

# មេរៀនទី ៤៩ រឿងកូនទន្សាយនិងកូនឆ្មា

## អំណាន



ថ្ងៃអាទិត្យមួយ កូនទន្សាយតូនីបានទៅលេងផ្ទះឆ្មាបូបូ ។ តូនីឃើញបូបូកំពុងគូររូបលេងយ៉ាងសប្បាយជាមួយប្អូនរបស់គេ ។ តូនីក៏រត់សំដៅទៅរកពួកគេទាំងពីរនាក់ ។ បូបូទទួលរាក់ទាក់មិត្តយ៉ាងរីករាយ ។ ពេលនោះតូនីឮសំឡេងស្រែកហៅ ៖ "អើយបូបូ! មកនេះមួយភ្លែត" ។ តូនីសួរបូបូ ៖ "តើនរណាហៅឯង ?" បូបូឆ្លើយ ៖ "គឺម្ដាយខ្ញុំ! គាត់កំពុងដាក់ក្របសៀវភៅឱ្យពួកខ្ញុំ ។ ប្រហែលជាគាត់មានការអ្វីហើយ! ប៉ុន្តែយើងគូររូបបន្តិចទៀតសិន!" ។ តូនីនិយាយ ៖ "មិនល្អទេ! គាត់ប្រាកដជាមានការអ្វីហើយ! អីចឹង! យើងប្រញាប់ទៅជួបគាត់" ។

## ការរៀនពាក្យ

ក. អំណានពាក្យ

ប្រាកដ អានថា ប្រា-កត់

សប្បាយ អានថា ស័ប-បាយ ឬ សៈបាយ



www.elibraryofcambodia.org

ខ. ពន្យល់ពាក្យ

ប្រាកដ : ជាក់ច្បាស់មែន ។

សប្បាយ : ដំណើរនៅជាសុខរីករាយ ។

គ. ពាក្យន័យដូចនឹងពាក្យ "និទាន"

និទាន និយាយ រៀបរាប់

ឃ. ពាក្យផ្ទុយ

មិត្ត ≠ សត្រូវ

ល្អ ≠ អាក្រក់

**សំណួរ**

១. នៅថ្ងៃអាទិត្យ តើតូនីទៅលេងផ្ទះនរណា ?

២. តើបូបូកំពុងធ្វើអ្វី ?

៣. តើម្ដាយរបស់បូបូកំពុងធ្វើអ្វី ?

៤. តើតូនីនិយាយដូចម្ដេចជាមួយបូបូ ?

**លំហាត់**

ក. ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្សំនិងប្រកបឱ្យបានត្រឹមត្រូវ ។

អាទិត្យ មិត្ត ដើរ គួរ បន្តិច កំពុង ប្រញាប់ ដំណើរ ប្រាកដ

ខ. តើតូនីជាកូនទន្សាយដូចម្ដេច ? ចូរជ្រើសរើសចម្លើយសមស្រប ។

១. តូនីជាកូនទន្សាយខ្ជិល ។

២. តូនីជាកូនទន្សាយល្អ ។

៣. តូនីជាកូនទន្សាយខិលខូច ។



www.elibraryofcambodia.org

គ. តើឃ្លាមសារនិងរូបភាពណាត្រូវគ្នា ?







តូនីនិងបូបូកំពុងអានសៀវភៅ ។ តូនីនិងបូបូច្រៀងលេង ។ ពួកគេលេងលោតអន្ទាក់ ។

## សំណេរ

ក. ចូរសរសេរតាមអានចម្លងពាក្យនិងល្បះខាងក្រោម ។

អាទិត្យ ទន្សាយ សប្បាយ មិត្ត ជីតា ប្រាកដ បន្តិច

គាត់ប្រាកដជាមានការអ្វីហើយ ! អីចឹងយើងប្រញាប់ទៅជួបគាត់ !

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញល្បះខាងក្រោមរូបភាព ។

កាត់ បោស ដាំ បេះ



១. ជីតាខ្ញុំកំពុង ..... ស្មៅ ។ ម្ដាយខ្ញុំ .............. ផ្លែប៉េងប៉ោះ ។

២. ឪពុកខ្ញុំកំពុង ........... កូនឈើ ។ ជីដូនខ្ញុំ ........... សំរាម ។



www.elibraryofcambodia.org

មេរៀនទី
៥០

# គ្រួសាររីករាយ

## ចម្រៀង



(លំនាំបទឪស្វាយចន្ទី)

ឪស្វាយចន្ទី កូនចៅសាមគ្គី ជួបជុំរីករាយ
ពុកម៉ែតាយាយ លោកមិនវាយមាយ ចិញ្ចឹមមើលថែ ។(ពីរដង)
ពុកម៉ែធ្វើការ កូនទៅសាលា សិក្សាពូកែ
មកផ្ទះជួយថែ មិនឱ្យពុកម៉ែ ពិបាកទូន្មាន ។(ពីរដង)
ទំនេរការងារ ព្រលប់ជុំគ្នា ស្តាប់តានិទាន
យាយប្រដៅប្រៀន ចៅៗខំរៀន គ្រួសាររីករាយ ។(ពីរដង)


www.elibraryofcambodia.org

## ការរៀនពាក្យ

ក. អំណានពាក្យ

សាមគ្គី អានថា សាម-ម៉ុក-គី

ទូន្មាន អានថា ទូន-មាន

ខ. ពន្យល់ពាក្យ

សាមគ្គី : សេចក្តីព្រមព្រៀង ដំណើរស្រុះគ្នា ។

ទូន្មាន : ប្រៀនប្រដៅ អប់រំណែនាំ ។

រាយមាយ : ចាប់នេះចាប់នោះ មិនឆ្ពោះត្រង់ណា ។

គ. ពាក្យន័យដូចនឹងពាក្យ "សិក្សា"

សិក្សា រៀនសូត្រ រៀន

ឃ. ពាក្យផ្ទុយ

ទំនេរ ≠ រវល់ ពូកែ ≠ ខ្សោយ

## សំណួរ

១. តើនរណាខ្លះជាអ្នកចិញ្ចឹមគ្រួសារ ?

២. តើនរណាជាអ្នកនិទានរឿង ?

៣. តើយាយប្រដៅចៅៗឱ្យធ្វើអ្វី ?

## លំហាត់

ក. ចូរប្រាប់ពាក្យចួនក្នុងចម្រៀង ។

១. តើពាក្យ "ចន្ទី" ចួននឹងពាក្យអ្វី ?

២. តើពាក្យ "រីករាយ" ចួននឹងពាក្យអ្វី ?

៣. តើពាក្យ "ធ្វើការ" ចួននឹងពាក្យអ្វី ?

ខ. ចូរអានទំនុកច្រៀងខាងលើឡើងវិញ រួចច្រៀងតាមគ្រូ ។



www.elibraryofcambodia.org

## សំណេរ

ក. ចូរសរសេរតាមអានគ្រូតពិនិត្យវគ្គចម្រៀងខាងក្រោម ។

| | | |
|---|---|---|
| ឱស្វាយចន្ទី | កូនចៅសាមគ្គី | ជួបជុំរីករាយ |
| ពុកម៉ែតាយាយ | លោកមិនរាយមាយ | ចិញ្ចឹមមើលថែ ។ |

ខ. ចូរជ្រើសរើសពាក្យចួនក្នុងប្រអប់ ទៅបំពេញបទចម្រៀងខាងក្រោម ។

យាយ | សាលា | ម៉ែ | គ្នា | ប្រៀន

| | | |
|---|---|---|
| ឱស្វាយចន្ទី | កូនចៅសាមគ្គី | ជួបជុំរីករាយ |
| ពុកម៉ែតា ....... | លោកមិនរាយមាយ | ចិញ្ចឹមមើលថែ ។ (ពីរដង) |
| ពុកម៉ែធ្វើការ | កូនទៅ...... | សិក្សាពូកែ |
| មកផ្ទះជួយថែ | មិនឱ្យពុក... | ពិបាកទូន្មាន ។ (ពីរដង) |
| ទំនេរការងារ | ព្រលប់ជុំ.... | ស្ដាប់តានិទាន |
| យាយប្រដៅ..... | ចៅៗខំរៀន | គ្រូសាររីករាយ ។(ពីរដង) |

គ. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

១. កូនចៅត្រូវស្ដាប់ ............ចាស់ទុំ ។

២. សុខកំពុងធ្វើ ............. ផ្ទះដែលគ្រូដាក់ឱ្យ ។

៣. ជីតាខ្ញុំតែង ............. រឿងឱ្យខ្ញុំស្ដាប់រៀងរាល់យប់ ។



www.elibraryofcambodia.org

មេរៀនទី
៥១

# ចម្ការរបស់ជីតាខ្ញុំ

## អំណាន



ជីតាខ្ញុំមានចម្ការមួយនៅក្រោយផ្ទះ ។

គាត់ដាំដំណាំហូបផ្លែនិងបន្លែគ្រប់មុខដូចជាឪឡឹក ត្រសក់ ល្ពៅ ជីរ ស្លឹកគ្រៃជាដើម ។ ពេលទំនេរ ខ្ញុំជួយដកស្មៅ ពូនគល់ និងស្រោចទឹកដំណាំ ។ ជីដូនខ្ញុំសប្បាយចិត្តណាស់ ព្រោះឃើញខ្ញុំចូលចិត្តធ្វើការងារ ។ គាត់មានប្រសាសន៍ថា ខ្ញុំឧស្សាហ៍ដូចជីតាខ្ញុំដែរ ។

ខ្ញុំពេញចិត្តនឹងចម្ការជីតាខ្ញុំណាស់ ព្រោះវាផ្ដល់ផលប្រយោជន៍ដល់គ្រួសារខ្ញុំហូបចុកបានគ្រប់គ្រាន់ ។

## ការរៀនពាក្យ

ក. អំណានពាក្យ

ឧស្សាហ៍ អានថា អ៊ុស-សា

ប្រសាសន៍ អានថា ប្រ-សាស



www.elibraryofcambodia.org

ខ. ពន្យល់ពាក្យ

ឧស្សាហ៍ : ការខំប្រឹងមិនខ្ជិល ។

ប្រសាសន៍ : ពាក្យបង្គាប់ ពាក្យផ្ដាំផ្ញើ ។

គ. ពាក្យន័យដូចនឹងពាក្យ "ប្រសាសន៍"

ប្រសាសន៍ សម្ដី ភាសា និយាយ សង្ឃដីកា ពុទ្ធដីកា

ឃ. ពាក្យផ្ទុយ

ឧស្សាហ៍ ≠ ខ្ជិល

## សំណួរ

១. តើចម្ការជីតារបស់គេស្ថិតនៅឯណា ?

២. តើចម្ការនេះមានដំណាំអ្វីខ្លះ ?

៣. តើពេលទំនេរ គេជួយធ្វើអ្វីខ្លះ ?

៤. តើជីដូនរបស់គេសរសើរគេដូចម្ដេច ?

## លំហាត់

ក. ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្ទៀងនិងប្រកបឱ្យបានត្រឹមត្រូវ ។

ជីវ ផលប្រយោជន៍ ចម្ការ ទំនេរ ឪឡឹក ស្លឹកគ្រៃ ឧស្សាហ៍ ប្រសាសន៍

ខ. ចូរតម្រូវល្បះជាមួយនឹងរូបភាពខាងក្រោម ដោយចុះលេខល្បះនៅក្នុង
ប្រអប់រូបឱ្យបានត្រឹមត្រូវ ។

១. បងស្រីខ្ញុំជាគ្រូពេទ្យ ។

២. ម្ដាយខ្ញុំជាគ្រូបង្រៀន ។



www.elibraryofcambodia.org

៣. ជីតាខ្ញុំតែងនិទានរឿងឱ្យខ្ញុំស្ដាប់ ។

៤. សែយ៉ាធ្វើលំហាត់នៅផ្ទះ ។

៥. ជីដូនយោលអង្រឹងចៅ ។

៦. ម៉ុកបោសសំរាម ។



## សំណេរ

ក. ចូរសរសេរតាមអានត្រួតពិនិត្យពាក្យនិងល្បះខាងក្រោម ។

ចម្ការ    ផ្ទះ    ប្រសាសន៍    ទំនេរ    ឱឡឹក

ខ្ញុំពេញចិត្តនឹងចម្ការជីតាខ្ញុំណាស់ ព្រោះវាផ្ដល់ប្រយោជន៍ដល់គ្រួសារខ្ញុំ ។



www.elibraryofcambodia.org

ខ. ចូរបំពេញល្បះតាមរូបភាពខាងក្រោមឱ្យបានត្រឹមត្រូវ ។





ឪពុកខ្ញុំកំពុង ..... ។ ម្ដាយខ្ញុំជា ..... ។ បងស្រីខ្ញុំជា ..... ។

គ. ចូរមើលរូបភាពខាងក្រោម រួចតែងល្បះអំពីរូបភាពនោះឱ្យបានសមស្រប ។





........................ ។ ........................ ។ ........................ ។





........................ ។ ........................ ។ ........................ ។



www.elibraryofcambodia.org

មេរៀនទី ៥២

# មេមាន់និងកូន

## អំណាន



មានមេមាន់មួយ បណ្ដើរកូនរកចំណីនៅក្រោយផ្ទះ ។

ពេលមកដល់គុម្ពោតព្រៃមួយ កូនមាន់បានដើរឃ្លាតឆ្ងាយពីមេវា ។ ពេលនោះ មេមាន់ភ័យណាស់ ព្រោះខ្លាចកូនមានគ្រោះថ្នាក់ ។ វារត់ឆ្វេឆ្វា ស្រែកហៅកូនៗឱ្យមកជិត ។ ក្រោយពេលកូនមកជុំគ្នា មេមាន់បានត្រដាងស្លាបគ្របកូនទាំងអស់ ។ មេមាន់បាននិយាយប្រដៅកូនកុំឱ្យដើររកចំណីឆ្ងាយពីខ្លួន ខ្លាចជួបនឹងសត្វសាហាវ ។ តាំងពីពេលនោះមក កូនមាន់មិនដែលដើររកចំណីឆ្ងាយពីមេរបស់វាឡើយ ។

ដោយសារការស្ដាប់តាមដំបូន្មានរបស់មេ កូនមាន់ទាំងអស់រស់នៅជាមួយមេវាប្រកបដោយភាពសុខសាន្ត ។



www.elibraryofcambodia.org

## ការរៀនពាក្យ

ក. អំណានពាក្យ

គុម្ពោត អានថា គុំ-ពោត

ភ័យ អានថា ភៃ

សុខសាន្ត អានថា សុក-សាន

ខ. ពន្យល់ពាក្យ

គ្រោះថ្នាក់ : គ្រោះកាច មានគ្រោះ ។

សុខសាន្ត : សេចក្ដីស្រណុក ដំណើរស្រួល ។

គ. ពាក្យន័យដូចនឹងពាក្យ "សាហាវ"

សាហាវ កាច ឃោរឃៅ

ឃ. ពាក្យផ្ទុយ

ខ្លាច ≠ ហ៊ាន រស់ ≠ ស្លាប់

## សំណួរ

១. តើមេមាន់បណ្ដើរកូនរកចំណីនៅឯណា ?

២. តើមេមាន់ប្រដៅកូនដូចម្ដេច ?

៣. នៅពេលស្ដាប់តាមដំបូន្មានរបស់មេ តើកូនមាន់រស់នៅដូចម្ដេច ?

## លំហាត់

ក. ចូរអានពាក្យខាងក្រោមដោយមិនបាច់ផ្សំនិងប្រកបឱ្យបានត្រឹមត្រូវ ។

| | | | | |
|---|---|---|---|---|
| បណ្ដើរ | ផ្ទះ | ឃ្លាត | ភ័យ | ឆ្លេឆ្លា |
| សាហាវ | ត្រដាង | គុម្ពោត | ភាពសុខសាន្ត | |



www.elibraryofcambodia.org

ខ. តើកូនមាន់ទាំងអស់ធ្វើអ្វី នៅពេលឮម្ដាយហៅ ? តើរូបភាពណាដែល

មានចំណងជើងត្រឹមត្រូវ ?



កូនមាន់រត់ចេញពីមេ ។ កូនមាន់រត់មករកមេវា ។ កូនមាន់ក្រាបក្នុងស្មៅពួនមេវា ។

គ. តើកូនមាន់ទាំងអស់ជាសត្វដូចម្ដេច ? ចូរជ្រើសរើសចម្លើយ

សមស្រប ។

១. កូនមាន់ទាំងអស់ជាសត្វដើរច្រើន ។

២. កូនមាន់ទាំងអស់ជាសត្វបំផ្លាញដំណាំ ។

៣. កូនមាន់ទាំងអស់ជាសត្វស្ដាប់ដំបូន្មាន ។

## សំណេរ

ក. ចូរសរសេរតាមអានត្រួតពិនិត្យអត្ថបទខាងក្រោម ។

### មេមាន់

មេមាន់បាននិយាយប្រដៅកូនកុំឱ្យដើររកចំណីឆ្ងាយពីខ្លួន ខ្លាចជួបនឹងសត្វសាហាវ ។ តាំងពីពេលនោះមក កូនមាន់មិនដែលដើររកចំណីឆ្ងាយពីមេរបស់វាឡើយ ។

ដោយសារការស្ដាប់តាមដំបូន្មានរបស់មេ កូនមាន់ទាំងអស់រស់នៅជាមួយមេវាប្រកបដោយភាពសុខសាន្ត ។



www.elibraryofcambodia.org